■ គ្រូអប់រំជំនឿទទួលព្រះពរ និងបេសកកម្ម សម្រាប់ដំណាក់កាលថ្មីក្នុងរដូវកាលកូវីដ១៩ <ទំព័រ១៦

■ ព្រះសហគមន៍ភូមិភាគភ្នំពេញ យកចិត្តទុកដាក់លើសិល្បៈ <ទំព័រ២០



កាសែតចេញផ្សាយ
ប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ
# the messenger

ខែ តុលា | ឆ្នាំ ២០២០ | លេខទី ១៣២

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/ October, 2020 | #132







គ្រោះទឹកជំនន់នាពេលកន្លងមកនេះបានធ្វើឱ្យប្រជាពលរដ្ឋស្លាប់ចំនួន២៥នាក់ក្នុងនោះមានក្មេងចំនួន៧នាក់ នៅក្នុងខេត្តចំនួន៥ ខេត្តបន្ទាយមានជ័យដែលមានអ្នកស្លាប់ច្រើនជាងគេរហូតដល់១៥នាក់ និង១០នាក់ទៀត រស់នៅក្នុងខេត្តព្រះសីហនុ ពោធិ៍សាត់ ប៉ៃលិន និងខេត្តកំពង់ធំ។ *រូបភាពៈ ហ្វេសប៊ុកនាយករដ្ឋមន្ត្រី*

អានរឿងពេញទំព័រ-១២-១៣

■ កំណត់ត្រាថ្មីនៃការរកឃើញសម្បុកសត្វចង្កៀលខ្យងជាងពីរពាន់ជាលើកដំបូងក្នុងបឹងព្រែកល្ពៅ

ទំព័រ-៣



■ កម្ពុជានឹងមានមជ្ឈមណ្ឌលសូត្រទី២នៅចុងឆ្នាំ២០២០

ទំព័រ-៤

■ រដ្ឋាភិបាលកូនកាត់យោធានៅថៃកំពុងតែស្រអាប់ដោយសារតែកម្លាំងយុវជន

ទំព័រ-៩

■ លោក សែ សាត ទទួលបន្ទុកលើព្រះវិហារចំនួន៨ ទំព័រ-១៧

■ ព្រះសហគមន៍មណ្ឌលគីរី លើកផែនការធំៗសម្រាប់ឆ្នាំ២០២១ ទំព័រ-១៩



# ឡៅដាតូស៊ី នៅកម្ពុជា
# (LAUDATO SI IN CAMBODIA)

*ដោយៈ លោកពុក ខុងហ្គី វីល*
*(Fr. Will Conquer)*



"គ្មានអ្វីនៅក្នុងលោកនេះ ដែលព្រងើយកន្តើយជាមួយយើងនោះទេ" (Laudato si, ២)

ប្រទេសកម្ពុជាពិតជាមានធម្មជាតិ ដ៏ស្រស់ត្រកាល និងសំបូរបែប។ ខ្ញុំបានមកដល់ប្រទេសកម្ពុជាគឺរយៈពេលមួយឆ្នាំ ហើយខ្ញុំកោតសរសើរចំពោះសម្រស់ធម្មជាតិដ៏វិសេសវិសាលនៅក្នុងប្រទេសនេះ។ ខ្ញុំបារម្ភដូចមនុស្សជាច្រើនទៀតដែរ ចំពោះអនាគតនៃបរិស្ថានដ៏ស្រស់ស្អាតនេះ។

តើយើងត្រូវធ្វើដូចម្តេច ដើម្បីធានាឱ្យបាននូវគុណភាព និងនិរន្តរភាពបរិស្ថាន ព្រមទាំងការពារធនធានធម្មជាតិ ដើម្បីជាប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់?

ក្រសួងបរិស្ថានបានសម្ពោធជាផ្លូវការនូវ «យុទ្ធនាការការពារព្រៃឡង់ តាមរយៈការទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថសង្គម» នាព្រឹកថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ក្រោមអធិបតីភាពលោក សៅ សុភាព រដ្ឋលេខាធិការក្រសួងបរិស្ថាន ថ្នាក់ដឹកនាំក្រសួង និងស្ថាប័នពាក់ព័ន្ធជាច្រើនទៀត។ ខ្ញុំមានកិត្តិយសដែលបានចូលរួមក្នុងកម្មវិធីគួរឱ្យចាប់អារម្មណ៍នេះ។

មានគេនិយាយថា ប្រជាជនកម្ពុជាមិនខ្វល់ពីបរិស្ថានទេ។ មិនពិតទេ! ការបំពុលបរិស្ថានកាកសំណល់ប្លាស្ទិក ការកាប់បំផ្លាញព្រៃឈើ បានជះឥទ្ធិពលអវិជ្ជមានដល់បរិស្ថានរបស់យើង។ ក្នុងស្មារតីសារលិខិតរបស់សម្តេចបាបហ្វ្រង់ស៊ីស្កូ មានចំណងជើងថា Laudato Si បានបង្ហាញថា ព្រះសហគមន៍កាតូលិកបានធ្វើការអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីកែលម្អស្ថានភាពនេះ។ យើងមានតួនាទីក្នុងការផ្លាស់ប្តូរនេះដែរ។

### មនុស្សទាំងអស់ជាបងប្អូន
### ក្នុងសកម្មភាពជាក់ស្តែង
### (Fratelli tutti in action)

កាលពីថ្ងៃទី ២៨-២៩ ខែកញ្ញា ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងក្រសួងបរិស្ថានបានដឹកនាំព្រះសង្ឃ និងយុវជន ព្រមទាំងអ្នកពាក់ព័ន្ធខាងលើទៅធ្វើទស្សនកិច្ចសិក្សា។ ក្រុមប្រតិភូ បានទៅមើលការអនុវត្ត ថែរក្សា ការពារព្រៃឡង់ដោយផ្ទាល់របស់មន្ត្រីឧទ្យានុរក្សក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ភូមិសាស្រ្ត ខេត្តកំពង់ធំ។

ពិធីសម្ពោធយុទ្ធនាការការពារព្រៃឡង់ តាមរយៈការទំនាក់ទំនងផ្លាស់ប្តូរឥរិយាបទសង្គម បានប្រព្រឹត្តឡើងនៅតំបន់ព្រះអាទិត្យ ទីស្នាក់ការដែនជម្រកសត្វព្រៃព្រៃឡង់ ក្នុងភូមិសាស្រ្តខេត្តកំពង់ធំ ដែលមានវត្តមានចូលរួមរបស់ភិក្ខុវជិរប្បញ្ញោ គូ សុភាព លោក សៅ សុភាព រដ្ឋលេខាធិការក្រសួងបរិស្ថាន លោក ព្រឹម រដ្ឋា អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ធំ និង លោកស្រី សេង សុទ្ធីរ៉ា តំណាង USAID។ យុទ្ធនាការនេះមានគោលបំណងលើកកម្ពស់កិច្ចការពារព្រៃឈើ ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិ។

ព្រះតេជព្រះគុណគូសុភាពបានដឹកនាំព្រះសង្ឃជាង១០អង្គ ចូលរួមដំណើរទស្សនកិច្ចដោយផ្ទាល់នៅដែនជម្រកសត្វព្រៃព្រៃឡង់ ជាលើកដំបូងមានសង្ឃដីកាថា ក្នុងនាមព្រះសង្ឃពិតជាមានការរីករាយ ដោយឃើញក្រសួងបរិស្ថានសហការជាមួយUSAID ដឹកនាំយុវជនមកការពារព្រៃឡង់ដែលនៅសេសសល់នេះ។ ប្រជាពលរដ្ឋសហគមន៍មានការរំភើបសប្បាយរីករាយដោយបានឃើញ ពលរដ្ឋមកពីមជ្ឈដ្ឋានផ្សេងរួមគ្នាការពារព្រៃឡង់បែបនេះ។

ខ្ញុំក៏មានសេចក្តីរីករាយណាស់ដែរ ដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សានៅព្រៃឡង់ ដែលមានព្រះសង្ឃ និងយុវជន ព្រមទាំងអ្នកពាក់ព័ន្ធប្រមាណ ៥០នាក់។ សម្រាប់ខ្ញុំ នេះគឺជាបទពិសោធន៍អស្ចារ្យ។ ខ្ញុំមិនដែលរំពឹងថា នឹងទៅបោះជំរំនៅក្នុងព្រៃនៃប្រទេសកម្ពុជាទេ!

ខ្ញុំមិនដែលរំពឹងទៅដើរលេងក្រោមភ្លៀងជាមួយព្រះតេជព្រះគុណ គូ សុភាព ទេ!

ខ្ញុំមិនដែលរំពឹងនឹងអង្គុយលេង និងពិភាក្សាអំពីអត្ថន័យនៃជីវិត ជាមួយព្រះសង្ឃ១០ អង្គនោះទេ។

តើនេះជាភាតរភាពនិងការសន្ទនាដែលសម្តេចប៉ាបហ្វ្រង់ស៊ីស្កូបានបង្ហាញនៅក្នុងសាមនលិខិតភាពជាបងប្អូន (Fratelli tutti)? ខ្ញុំជឿថាអីចឹង។

### អំណរសប្បាយពីការ
### ប្រកាសដំណឹងល្អ ក្នុងសេចក្តីសង្ឃឹម
### (Evangelii Gaudium in hope)

ខ្ញុំឆ្ងល់! ហេតុអ្វីបានជាអ្នករៀបចំកម្មវិធីនេះចង់អញ្ជើញអ្នកដឹកនាំសាសនាដូចជា ព្រះសង្ឃគូ សុភាព និងខ្ញុំ? ជាការពិតណាស់ ព្រះតេជព្រះគុណ គូ សុភាព ពិតជាល្បីល្បាញណាស់។ ប៉ុន្តែហេតុអ្វីបានជា ព្រះតេជព្រះគុណ គូ សុភាព ចង់ចែករំលែករូបភាពរបស់យើងទាំងពីរនាក់នៅក្នុងព្រឹត្តិការណ៍នេះ ដើម្បីការពារបរិស្ថានរបស់យើង? ហេតុអ្វីបានជាមនុស្ស ៦០០០០ នាក់ចូលចិត្ត (Like) រូបភាពនេះនៅលើហ្វេសប៊ុក? ដំបូងខ្ញុំជឿថា សាសនាមានអ្វីត្រូវនិយាយអំពីការការពារបរិស្ថាន។

ព្រះតេជព្រះគុណ គូ សុភាព បន្តថា៖ «កាលណាមានព្រៃច្រើនទៅយើងមិនសូវក្តៅ។ កាលពីសម័យពុទ្ធកាល ព្រះពុទ្ធក៏ប្រសូតនៅក្នុងព្រៃ ត្រាស់ដឹងក៏នៅក្នុងព្រៃ បរិនិព្វានក៏នៅក្នុងព្រៃ ហើយនៅពេលដែលព្រះពុទ្ធណែនាំភិក្ខុសង្ឃ ក៏តែងតែណែនាំនៅក្នុងព្រៃដែរ ព្រោះព្រៃឈើគឺជាធម្មជាតិមួយធ្វើឱ្យសារពាង្គកាយស្រស់បំព្រង និងជួយឱ្យចិត្តស្ងប់ល្អ»។ ខ្ញុំយល់ស្របទាំងស្រុងផង!

ទីពីរខ្ញុំជឿថាយើងជាគ្រីស្តបរិស័ទមានអ្វីដែលត្រូវនិយាយដែរ។ នៅពេលនេះមនុស្សជាច្រើនមានការព្រួយបារម្ភ ឬអស់សង្ឃឹម និងធ្លាក់ទឹកចិត្ត។ បេសកកម្មរបស់យើង គឺប្រកាសដំណឹងល្អនៃស្ថានព្រះហស្ត។ ព្រះជាម្ចាស់មិនបានបង្កើតយើងសម្រាប់ការភ័យខ្លាចទេ ប៉ុន្តែសម្រាប់សុភមង្គលដ៏អស់កល្បជានិច្ច។ នេះគឺជាឧទាហរណ៍មួយដែលបងប្អូនប្រហែលមិនធ្លាប់ឮទេ។

លោក ហ្សង់ - អាន់ឌ្រេសូសៀ (Jean-André Soulié) គឺជាបូជាចារ្យមួយអង្គ និងជាសាសនទូតជាតិបារាំងនៅសតវត្សរ៍ទី១។ នៅក្នុងស្មារតីរបស់សន្តហ្វ្រង់ស៊ីស្កូនៃអាស៊ីស៊ី គាត់ស្រឡាញ់ធម្មជាតិ។ គាត់គឺជាអ្នកជំនាញខាងរុក្ខសាស្រ្ត! គាត់យកចិត្តទុកដាក់ការពារបរិស្ថាន! ហើយសូម្បីតែឈ្មោះផ្កាខ្លះក៏មានដាក់ឈ្មោះរបស់គាត់ផងដែរ ហើយគាត់ក៏ជាអ្នកប្រកាសសេចក្តីស្រឡាញ់របស់ព្រះយេស៊ូគ្រីស្តដែរ។ នៅទីបញ្ចប់ លោកឪពុកហ្សង់-អាន់ឌ្រេសូសៀ បានទទួលមរណភាព ក្លាយជាមរណសាក្សីនៅប្រទេសចិនក្នុងឆ្នាំ១៩០៥។ គាត់អាចធ្វើជាគំរូដល់ពួកយើង។ នៅសតវត្សរ៍ទី ១៩ សាសនទូតខ្លះ និយមរុក្ខសាស្រ្ត។ នៅសតវត្សរ៍ទី ២១ បងប្អូនទាំងឡាយក៏គួរតែជាអ្នកបរិស្ថានវិទូផងដែរ។

តើបងប្អូនត្រូវចូលរួមស្រឡាញ់បរិស្ថានដោយរបៀបណា? ព្រមទាំងត្រៀមខ្លួនក្លាយជា រុក្ខវិទូដោយរបៀបណា?

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh



# កំណត់ត្រាថ្មីនៃការរកឃើញសម្បុកសត្វចង្កៀលខ្យង ជាងពីរពាន់ជាលើកដំបូងក្នុងបឹងព្រែកល្ពៅ

*អត្ថបទ៖ អមរិន្ទ ដានុត*

មន្ត្រីឧទ្យានុរក្ស និងមន្ត្រីជីវចម្រុះនៅឆ្នាំ២០២០នេះ បានរកឃើញថាចំនួនសត្វចង្កៀលខ្យងបានកើនឡើងរាប់ពាន់ក្បាល និងមានសម្បុកពងកូនយ៉ាងតិចចំនួន២១៨៦ នៅលើដើមរាំងចំនួន២៧០ដើមក្នុងតំបន់បឹងព្រែកល្ពៅ ក្នុងស្រុកបូរីជលសារ និងស្រុកកោះអណ្តែត ខេត្តតាកែវ។



*សត្វចង្កៀលខ្យងកំពុងរកចំណី។ រូបភាព៖ សហការី*



ការធ្វើសម្បុកនេះ ជាកំណត់ត្រាថ្មីដែលពុំធ្លាប់មាននៅក្នុងរយៈពេលប្រមាណជាង១៥ឆ្នាំចុងក្រោយនេះ។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរួម របស់ក្រសួងបរិស្ថាន អង្គការ BirdLife អង្គការ WWT និងអង្គការជីវិតធម្មជាតិនៅកម្ពុជា នៅថ្ងៃសុក្រ ទី២៣ ខែតុលា ឆ្នាំ២០២០នេះ។

លោក លឹម វ៉ាត នាយករងតំបន់ការពារទេសភាពបឹងព្រែកល្ពៅ បានឱ្យដឹងថា ក្នុងរយៈពេល៤ឆ្នាំដែលក្រសួងបរិស្ថានបានគ្រប់គ្រងតំបន់នេះ លោកសង្កេតឃើញថា ចំនួនសត្វស្លាបព្រៃមានការកើនឡើងជាលំដាប់។

លោកបានបន្តថា ៖ «ជាក់ស្តែងដូចជាវត្តមានពងកូនសត្វចង្កៀលខ្យងដែលទើបនឹងរកឃើញជាលើកទី១នាពេលថ្មីៗនេះ។ ទិន្នន័យនេះ បានបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់នូវលទ្ធផលជាវិជ្ជមាននៃការខិតខំប្រឹងប្រែងរបស់ក្រុមការងារយើងកន្លងមក ក្នុងការការពារ និងអភិរក្សធនធានជីវៈចម្រុះនៅតំបន់ដីសើមនេះ»

លោក លឹម វ៉ាតបានប្តេជ្ញាបន្តដឹកនាំមន្ត្រីឧទ្យានុរក្សថែរក្សាការពារ និងអភិរក្សធនធានធម្មជាតិនៅតំបន់នេះឱ្យបានគង់វង្ស ដើម្បីបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយ។

ប្រធានមន្ទីរបរិស្ថានខេត្តតាកែវ លោក ឆយ ម៉ុនលី បានថ្លែងផងដែរថា មន្ទីរបរិស្ថានខេត្តដែលជាអង្គភាពគ្រប់គ្រងតំបន់ការពារទេសភាពនេះដោយផ្ទាល់ មានសេចក្តីសោមនស្សរីករាយជាខ្លាំងចំពោះកំណើនសត្វ និងកំណត់ត្រាថ្មីនេះ។

លោកបានបន្តថា ៖ «ការសម្រេចចិត្តធ្វើសម្បុកពងកូនរបស់សត្វចង្កៀលខ្យងនៅតំបន់នេះមានន័យថា យើងបានផ្តល់ទីជម្រកសុវត្ថិភាពដល់ពួកវា។ ហេតុដូនេះ ក្នុងនាមមន្ទីរបរិស្ថាននឹងបន្តខិតខំប្រឹងប្រែងកាន់តែខ្លាំងថែមទៀត ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ សហគមន៍ និងអង្គការដៃគូដើម្បីការងារពារទីជម្រកព្រៃលិចទឹកនេះមិនឱ្យបាត់បង់ឡើយ»។



*ពងសត្វចេង្កៀលខ្យង។ រូបភាព៖ សហការី*

លោក Saber Masoomi អ្នកសម្របសម្រួលប្រចាំប្រទេសកម្ពុជានៃអង្គការ WWT បានលើកឡើងផងដែរថា បឹងព្រែកល្ពៅជាផ្នែកមួយនៃធនធានធម្មជាតិដ៏ធំបំផុតដែលមានក្នុងប្រព័ន្ធអេកូឡូស៊ីដីសណ្តទន្លេមេគង្គក្រោមនៃប្រទេសកម្ពុជា។

លោកបន្តទៀតថា តំបន់ដីសើមនេះ មានតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនជា៥០០០គ្រួសារមកពី២២ ភូមិជុំវិញ តាមរយៈការផ្តល់ជាទឹកសាប ត្រី និងរុក្ខជាតិឱសថ។

គួរបញ្ជាក់ផងដែរថា បឹងព្រែកល្ពៅ គឺជាតំបន់ដីសើមដ៏ធំមួយដែលស្ថិតនៅក្នុងតំបន់ដីសណ្តទន្លេមេគង្គក្រោម និងត្រូវបានកំណត់ជាតំបន់ការពារទេសភាពបឹងព្រែកល្ពៅតាមរយៈអនុក្រឹត្យចុះថ្ងៃទី ខែសីហា ឆ្នាំ២០១៦ ដែលមានទីតាំងភូមិសាស្តស្រ្ថិតនៅស្រុកបូរីជលសា និងស្រុកកោះអណ្តែត ខេត្តតាកែវ៕

# កម្ពុជាប្រកាសបិទព្រឹត្តិការណ៍៣វិច្ឆិកា ប៉ុន្តែត្រូវបន្តការការពារពីកូវីដ១៩

*អត្ថបទ៖ អមរិន្ទ ដានុត*

សម្តេចនាយករដ្ឋមន្ត្រីបានប្រកាសបិទព្រឹត្តិការណ៍៣វិច្ឆិកាកាលពីថ្ងៃទី១៨ ខែវិច្ឆិកា បន្ទាប់ពីរូបលោក ភរិយា មន្ត្រីរាជរដ្ឋាភិបាលមួយចំនួន រួមនឹងអ្នកសារព័ត៌មានដែលបានពាក់ព័ន្ធផ្ទាល់និងដោយប្រយោលក្នុងព្រឹត្តិការណ៍៣វិច្ឆិកាមានលទ្ធផលតេស្តអវិជ្ជមានកូវីដ១៩។

សម្តេចតេជោហ៊ុន សែនបានប្រកាសផងដែរថា ព្រឹត្តិការណ៍៣វិច្ឆិកានឹងត្រូវបិទបញ្ចប់ការធ្វើចត្តាឡីស័កទៅតាមពេលវេលាកំណត់របស់ក្រសួងសុខាភិបាល។

សម្រាប់រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តពោធិ៍សាត់ ខេត្តព្រៃវែង និងខេត្តកំពង់ធំ ដែលមានអ្នកប៉ះពាល់ផ្ទាល់និងប្រយោលចំនួន១៧០២នាក់ (ជនជាតិហុងគ្រីចំនួន៥នាក់) នឹងត្រូវបិទបញ្ចប់ព្រឹត្តិការណ៍៣វិច្ឆិកានៅថ្ងៃទី១៩ ខែវិច្ឆិកានេះ។ ខេត្តកំពង់ឆ្នាំង (១១នាក់) នឹងបិទបញ្ចប់ថ្ងៃ២១ ខែវិច្ឆិកា ខេត្តកែប (១៨នាក់) ខេត្តព្រះសីហនុ (៤០នាក់)និងខេត្តកំពង់ចាម (១នាក់) នឹងបិទបញ្ចប់ថ្ងៃ២៣ ខែវិច្ឆិកា និងខេត្តចុងក្រោយគេដែលនឹងបិទបញ្ចប់គឺខេត្តព្រះវិហារ (២០នាក់) និងខេត្តរតនគិរី(១០នាក់)នៅថ្ងៃទី២៥ ខែវិច្ឆិកា។

លោកហ៊ុន សែនថ្លែងថា ៖ «សូមរំលឹកចំពោះអាជ្ញាធរមូលដ្ឋានដែលមានបងប្អូនកំពុងធ្វើចត្តាឡីស័កដែលមិនទាន់ដល់ថ្ងៃត្រូវបញ្ចប់ ត្រូវណែនាំឱ្យបន្តធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ បើមិនដូច្នេះទេនឹងត្រូវប្រឈមនឹងការតម្រូវឱ្យធ្វើចត្តាឡីស័ក១៤ថ្ងៃឡើងវិញ ព្រោះផ្នែកសុខាភិបាលកំណត់រយៈពេល១៤ថ្ងៃគឺចាប់ពីថ្ងៃយកសំណាកដំបូងមកធ្វើតេស្ត»។

សម្តេចបានបញ្ជាក់ថា ៖ «ត្រូវចងចាំថាប្រជាជនកម្ពុជា រួមទាំងប្រជាជនលើពិភពលោកស្អប់កូវីដ១៩ខ្លាំងណាស់ តែកូវីដ១៩មិនត្រឹមតែមិនស្អប់យើងវិញនោះទេ តែវាថែមទាំងស្រឡាញ់យើងទៀតផង ដែលការស្រឡាញ់របស់វាមកលើយើងនឹងធ្វើឱ្យយើងស្លាប់ឬខូចខាតសុខភាពតែប៉ុណ្ណោះ»៕

# ផលិតផលក្លែងក្លាយជិត៦០០តោនត្រូវបានបង្ក្រាបក្នុងរយៈពេល៩ខែ ឆ្នាំ២០២០នេះ

*អត្ថបទ៖ អមរិន្ទ ដានុត*

ឱសថខុសច្បាប់ ផលិតផលវេជ្ជសាស្រ្ត និងផលិតផលក្លែងក្លាយខុសច្បាប់ទូទៅបានជិត ៦០០តោនត្រូវបានបង្ក្រាបក្នុងរយៈពេល៩ខែ ដើមឆ្នាំ២០២០នេះ។ បើយោងតាមរបាយការណ៍របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ (គ.ប.ផ.ក)។

នាថ្ងៃអង្គារ ទី២០ ខែតុលា ឆ្នាំ២០២០នេះ លោក មៀច សុផាន់ណា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ (គ.ប.ផ.ក) បានដឹកនាំបើកកិច្ចប្រជុំស្តីពី «យន្តការអនុវត្តន៍ការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ និងទិសដៅអនុវត្តន៍បន្ត» នាទីស្តីការក្រសួងមហាផ្ទៃ។

លោក តាន់ សុខវិជ្ជា ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ បានឡើងអានរបាយការណ៍ឱ្យដឹងថា រយៈពេល ៩ខែ ឆ្នាំ២០២០ គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ (គ.ប.ផ.ក) បានចុះបង្ក្រាបឱសថខុសច្បាប់ ផលិតផលវេជ្ជសាស្រ្ត និងផលិតផល ដែលក្លែងក្លាយខុសច្បាប់ទូទៅ សរុបចំនួន ១៣៤ករណី ស្មើនឹងចំនួន ៥៩៤.៦៥តោន។

លោកបានលើកឡើងទៀតថា ក្នុងចំណោមការបង្ក្រាបនោះ រួមមាន ឱសថ១៩ករណី ផលិតផលវេជ្ជសាស្រ្តប្រឆាំងនឹងមេរោគកូវីដ១៩ ចំនួន១២ករណី ផលិតផលឧបភោគ និងបរិភោគ ៣៥ករណី ផលិតផលគ្រឿងសម្អាង ២៩ករណី ផលិតផលប្រើប្រាស់ ២០ករណី និងផលិតផលថ្នាំជក់ ១៩ករណី។

ករណីបង្ក្រាបនេះធ្វើឡើងនៅរាជធានីភ្នំពេញបាន ១១១ករណី ខេត្តកណ្តាលបាន១១ករណី ខេត្តកំពង់ស្ពឺបាន២ករណី ខេត្តតាកែវបាន ១ករណី ខេត្តព្រះសីហនុបាន២ករណី ខេត្តបាត់ដំបងបាន ១ករណី ខេត្តកំពង់ចាមបាន១ករណី ខេត្តត្បូងឃ្មុំបាន៤ករណី និងខេត្តស្វាយរៀងបាន១ករណី។ ក្នុងនោះដែរ ក្នុងខែមករាបង្ក្រាបបាន៣ករណី ខែកុម្ភៈបាន៣ករណី ខែមីនាបាន១៣ករណី ខែមេសាបាន៣២ករណី ខែឧសភាបាន ២០ករណី ខែមិថុនាបាន២២ករណី ខែកក្កដាបាន ២០ករណី ខែសីហាបាន១១ករណី និងខែកញ្ញា បាន១០ករណី។

លោក តាន់ សុខវិជ្ជា បានឱ្យដឹងបន្ថែមថា អាជីវកម្មអនុលោមតាមច្បាប់មាន៩ករណី កិច្ចសន្យាអប់រំណែនាំ ១០៥ករណី ផាកពិន័យតាមវិធានក្រសួងពាក់ព័ន្ធ១ករណី។ បានបញ្ជូនសំណុំរឿងទៅអយ្យការ/តុលាការ ១៣ករណី ឃាត់ខ្លួនមនុស្ស ២០នាក់ ដោយក្នុងនោះកំពុងបន្តនីតិវិធី ១១ករណី (មនុស្ស ១៨នាក់) និងតុលាការសម្រេច ២ករណី ដែលមានមនុស្ស២នាក់ដាក់ពន្ធនាគារ។

លោក មៀច សុផាន់ណា បានមានប្រសាសន៍ថា គ.ប.ផ.ក គឺធ្វើដើម្បីការធានា និងការពារសុខុមាលភាពប្រជាពលរដ្ឋជាចម្បង ដោយជំរុញការងារផ្សព្វផ្សាយអប់រំបង្កា និងទប់ស្កាត់ ការអនុវត្តកិច្ចប្រតិបត្តិការបង្ក្រាប និងកិច្ចសហប្រតិបត្តិការ សម្របសម្រួលជាមួយបណ្តាអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលករណីនេះមិនមែនជាសមត្ថកិច្ចផ្តាច់មុខ របស់ក្រសួង ឬស្ថាប័នណាមួយតែឯកឯងនោះឡើយ។

លោកបានបន្តលើកឡើងថា ៖ «ទោះបីជាបច្ចុប្បន្ននេះ ការងារប្រយុទ្ធប្រឆាំងបទល្មើសផលិតផលក្លែងក្លាយ ទទួលបានជោគជ័យយ៉ាងណាក៏ដោយ ក៏បទល្មើសនេះកំពុងរីករាលដាលពីមួយថ្ងៃទៅមួយថ្ងៃ និងស្ទើរតែគ្រប់ទីកន្លែង ហើយត្រូវបានសកលលោកចាត់ទុកជាបទល្មើសឧក្រិដ្ឋឆ្លងដែន ដែលមានលក្ខណៈជាអង្គការចាត់តាំង»។

ក្នុងកិច្ចប្រជុំនេះដែរ លោក មៀច សុផាន់ណា បានដឹកនាំអង្គប្រជុំពិភាក្សា ដើម្បីប្រមូលធាតុចូលផ្សេងៗ ដែលតំណាងអន្តរក្រសួង ស្ថាប័ននានា និងមន្ត្រីជំនាញចូលរួមជាមតិយោបល់ ដើម្បីបញ្ចូលក្នុងយន្តការអនុវត្ត ទិសដៅបន្ត និងបញ្ចូលក្នុងការងារផែនការសកម្មភាព ៥ ឆ្នាំ គឺផែនការ ២០២០ ដល់ ២០២៥ របស់ គ.ប.ផ.ក ៕

# កម្ពុជានឹងមានមជ្ឈមណ្ឌលសូត្រទី២នៅចុងឆ្នាំ២០២០

*អត្ថបទ៖ ផល សុផានិត*

មជ្ឈមណ្ឌលសូត្រទី២របស់ប្រទេសកម្ពុជា នឹងលេចជារូបរាងឡើងនៅចុងឆ្នាំ២០២០នេះ ដែលគម្រោងបង្កើតមជ្ឈមណ្ឌលសូត្រទី២នេះ នៅលើផ្ទៃដីប្រមាណជា៣ហិចតា ក្នុងទឹកដីខេត្តភាគឥសាន គឺខេត្តមណ្ឌលគិរី ដើម្បីផលិតពងដង្កូវនាង និងដង្កូវនាងល្អៗ ក៏ដូចជាការដាំដុះដើមមនសម្រាប់ចំណីសត្វដង្កូវនាង។

លោកបណ្ឌិត មុី កល្យាណ ប្រធានក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងជាស្ថាបនិកគម្រោងមជ្ឈមណ្ឌលសូត្របានបញ្ជាក់ថា៖ «បញ្ហាដែលយើងជួបប្រទះនៅកន្លែងនេះ (មជ្ឈមណ្ឌលផលិតសូត្រនៅភ្នំពេញ) ដោយសារសាលាយើងជាសាលានៅភ្នំពេញ យើងមានដី (ដាំដុះមន) មិនច្រើនប៉ុន្មាន។យើងស្រាវជ្រាវ យើងត្រូវការមន។ យើងមានមនគ្រប់កន្លែងដែរតែមិនគ្រប់ទេ។ ទីពីរដោយសារមនយើងមិនសូវមានគុណភាពប៉ុន្មានទេ (ការដាំមននៅភ្នំពេញ)។ ដង្កូវនាង ត្រូវតែជារបស់មួយឥតខ្ចោះដែលត្រូវការអ្វីជាធម្មជាតិមែនទែន»។

បណ្ឌិតជំនាញសេដ្ឋកិច្ច បានបន្ថែមថា៖ «យើងដឹងថាការដាំមននៅមណ្ឌលគិរី គឺល្អ។ មណ្ឌលគិរីជាកន្លែងមួយពិសេសសម្រាប់ប្រទេសខ្មែរយើង ដែល Ecosystem របស់វាល្អដែលវាត្រជាក់ ទឹកដីល្អ អាកាសធាតុអត់សូវក្តៅ វាល្អសម្រាប់មន ដង្កូវនាង»។

គោលបំណងនៃការបង្កើតមជ្ឈមណ្ឌលសូត្រខ្មែរនេះ គឺជួយផ្គត់ផ្គង់ជីវភាពរបស់ប្រជាកសិករពិសេសស្ត្រី លើកស្ទួយវិស័យសូត្រនៅកម្ពុជាឱ្យមានគុណភាព និងកាត់បន្ថយការនាំយកសូត្រពីក្រៅប្រទេស ដើម្បីផលិតនូវផលិតផលសម្រេចដែលមានដូចជាសំពត់ហូល ក្រមាសូត្រដែលជាផលិតផលសម្រាប់ស្លៀកពាក់ ប្រើប្រាស់ និងយកមកធ្វើជាគ្រឿងសម្អាងនិងថ្នាំពេទ្យជាដើម។





(ឆ្វេង) ដង្កូវសូត្រកំពុងស៊ីស្លឹកមន និងដង្កូវនាងរុំខ្លួនក្លាយជាសំបុក (ស្តាំ)។ រូបភាព៖ សហការី

ផលិតចំណីអាហារសិប្បនិម្មិតសម្រាប់ដង្កូវនាង តាមរយៈការលាយស្លឹកមនជាមួយវីតាមីនសំខាន់ៗមួយចំនួន។ តាមរយៈការដាក់របបអាហារសិប្បនិម្មិតនេះម្តង ដង្កូវនាងអាចស៊ីបានក្នុងរយៈពេល ១២ ថ្ងៃ។ ជាធម្មតា ដង្កូវនាងស៊ីចំណីបីដងក្នុងមួយថ្ងៃ។ របបអាហារសិប្បនិម្មិតនេះធ្វើឱ្យដង្កូវនាងរីកធំធាត់និងមានសុខភាពល្អ។

លោកបណ្ឌិតសង្ឃឹមថា កម្ពុជានឹងអាចផលិតសូត្របាន១០០គីឡូក្រាមក្នុងឆ្នាំ២០២០នេះ និងសង្ឃឹមយ៉ាងមុតមាំថា បរិមាណនៃការផលិតនឹងកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

លោកបណ្ឌិត មុី កល្យាណ បានបន្តថា បញ្ហាប្រឈមក្នុងការខាតបង់ទាំងនេះ និងការបង្កើនការផលិតឡើងវិញ នូវសរសៃសូត្រក្នុងស្រុក លោកបណ្ឌិតនិងមន្ត្រីមួយចំនួន ក្នុងសកលវិទ្យាល័យ នាំគ្នាបង្កើតក្រុមការងារ ឈ្មោះថា ខ្សែចង្វាក់ផលិតកម្មសូត្រ។ ក្រុមការងារខាងលើ បានចាប់ផ្តើមពីការស្រាវជ្រាវពូជដង្កូវនាង កាលពីឆ្នាំ២០១៧។

លោកបណ្ឌិត មុី កល្យាណ លើកឡើងថា ប្រសិនបើកម្ពុជាអាចដាំដើមមន ចិញ្ចឹមដង្កូវនាងឡើងវិញនោះកម្ពុជា មិនខាតបង់ថវិកានោះទេ និងផ្តល់ឱកាសការងារ ជាពិសេសស្ត្រី៖ «ភាគច្រើនស្រីៗ គឺគាត់មិនត្រូវចំណាកស្រុកទៀតនោះទេ ការងារនេះជាការងារស្រាលៗ អាចអង្គុយជុំគ្នា ពី១០ទៅ២០នាក់ នេះជាការងារឱ្យគាត់ផង ចំណូលឱ្យគាត់ផង មានរឿងចំណេញច្រើនណាស់។ សូត្រនេះមិនជាប់ទាក់ទងនឹងបរិស្ថានអ្វីច្រើននោះទេ កាន់តែបង្កើនឱ្យបរិស្ថានល្អ ដោយការដាំមន មួយទៀតរឿងល្អដែរ ទាក់ទងនឹងសេដ្ឋកិច្ចផង និងទេសចរណ៍ផង»។





អ្នកស្រី ចេន សុភាព ស្ថាបនិកសហគ្រាសកីតម្បាញខ្មែរ KTK។ រូបភាព៖ សហការី





លោកបណ្ឌិត មុី កល្យាណ ប្រធានក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងជាស្ថាបនិកគម្រោងមជ្ឈមណ្ឌលសូត្រ រូបភាព៖ សហការី

វិស័យសូត្ររបស់កម្ពុជាស្ទើរតែផុតជីវិតទៅហើយ ដោយសារតែវាត្រូវបានគេទុកចោលមិនអភិវឌ្ឍន៍ ហើយមានតែកសិករតិចតួចប៉ុណ្ណោះ ដែលបន្តកិច្ចការដាំដុះមនសម្រាប់សិប្បកម្មជាលក្ខណៈគ្រួសារ។ ជាមួយគ្នានោះ កម្ពុជាបាននាំចូលសូត្រយ៉ាងហោចណាស់ ៤០០ តោនក្នុងមួយឆ្នាំដែលមានតម្លៃ ៣០ លានដុល្លារ។

លោកបណ្ឌិត មុី កល្យាណ នៅពេលបច្ចុប្បន្ននេះ មជ្ឈមណ្ឌលសូត្រខ្មែរ ក៏បានជោគជ័យក្នុងការ

សារព័ត៌មានក្នុងស្រុក បានស្រង់សម្តី អ្នកស្រី ចេន សុភាព ស្ថាបនិកសហគ្រាសកីតម្បាញខ្មែរ KTK បានបង្ហាញនូវការពេញចិត្តនិងគាំទ្រនៅពេលដែលកម្ពុជាមានមជ្ឈមណ្ឌលស្រាវជ្រាវសូត្រ ដែលជាវត្ថុធាតុដើមសំខាន់ក្នុងការផលិតសូត្រដោយមានប្រសាសន៍ថា៖ «នៅពេលដែលគាត់មានការផលិតបន្ថែម ចិញ្ចឹមដង្កូវនាងបានច្រើនហើយអាចផលិតសរសៃសូត្របានច្រើន យើងនឹងសហការគ្នាថា យើងអាចធ្វើអ្វីបន្តទៀតដើម្បីយើងយកវត្ថុធាតុដើមដែលល្អយកមកផលិតជាផលិតផល ជាក្រណាត់តម្បាញ មានជាក្រមា ផាមួង ហូល និងក្រណាត់ធ្វើពីសូត្រតែម្តង»។

អ្នកស្រី ចេន សុភាព ក៏បានបញ្ជាក់ថា ផលិតផលធ្វើពីសូត្រ គឺមានតម្លៃថ្លៃបន្តិចធៀបទៅនឹងផលិតផលស្រដៀងគ្នាដែលមិនមែនមានវត្ថុធាតុដើមជាសូត្រ ដោយលើកឧទាហរណ៍ពីសំពត់ហូលដែលធ្វើពីសូត្រថា៖ «អ្វីដែលថ្លៃគឺទាក់ទងការធ្វើ។ យើងស្មោរហើយស្រាវវា ជ្រលក់ពណ៌ហើយហាល ហាលហើយស្រាវទៀតហើយនៅចងក្បាច់ទៀត»។

ម្ចាស់រមណីដ្ឋានចំការស្នេហ៍ និងជាប្រធានសហគមន៍ផ្ទាល់ លោក រិន ណារ៉ាន់ បានបញ្ជាក់កាលពីពេលកន្លងមកថា ក្នុង១ខែសហគមន៍នេះអាចផលិតសូត្របានត្រឹមតែជាង១គីឡូក្រាម ដូច្នេះយើងតែងតែត្រូវការសូត្រដែលនាំចូលពីប្រទេសជិតខាងបន្ថែមទៀត។ ក្នុងរង្វង់មធ្យម ៥០០គីឡូក្រាមសម្រាប់រយៈពេល១ឆ្នាំ។

លោក រិន ណារ៉ាន់ បានរៀបរាប់អំពីមូលហេតុចម្បងមួយដែលធ្វើឱ្យសហគមន៍មិនអាចផលិតសូត្របានច្រើន ដើម្បីសមស្របទៅនឹងតម្រូវការក្នុងសហគមន៍ថា៖ «ចិត្តខ្ញុំចង់ថា ពង្រីកមុខរបរនេះ មិនចង់ឱ្យទៅទិញ ពីប្រទេសជិតខាងនោះទេ។ អ៊ីចឹង! បរិវេនដីយើងតូច យើងមិនអាចផលិតជាសូត្រឱ្យបានច្រើនទេ ដូច្នេះទាមទារឱ្យមានដីឱ្យបានធំ ដាំមនឱ្យបានច្រើន ពូជចាប់ពី៣ទៅ៥លានកូន ដែលទាមទារឱ្យមានការដាំដើមមន ២ទៅ៣ហិចតា តែសព្វថ្ងៃដាំបានតែ ១ហិចតាទេ»។

លោក រិន ណារ៉ាន់ បន្តថាការបាញ់ថ្នាំគីមីលើចម្ការ ក៏ជាបញ្ហាចម្បងធ្វើឱ្យដង្កូវនាងងាប់។ បញ្ហាផ្សេងទៀតគឺខ្វះខាតវត្ថុធាតុដើម សម្រាប់យកមកត្បាញ ជាហូល ផាមួង ក្រម៉ានេះ មិនមែនតែជាបញ្ហាសម្រាប់ លោកម្នាក់នោះទេ តែសម្រាប់ការផលិតសូត្រនៅកម្ពុជាផងដែរ។

នៅក្នុងមហោស្រព សិល្បៈជាតិតម្បាញសូត្រ កាលពីពេលកន្លងទៅនេះ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លោកស្រី ភឿង សកុណា បានអះអាងថា ផ្អែកតាមឯកសារកាទូតចិន ពលរដ្ឋខ្មែរចេះត្បាញសូត្រ មានក្បាច់ផ្កាភ្ញី មានភាពភ្លឺរលោងរួមទាំងតម្លៃខ្ពស់ក្នុងសតវត្សទី១៣។

លោកស្រីរដ្ឋមន្ត្រីវប្បធម៌បានបន្តថា រាជរដ្ឋាភិបាល បានបន្តការលើកទឹកចិត្ត ការដាំដើមមន ចិញ្ចឹមដង្កូវនាង និងបង្កើនការផលិតក្នុងស្រុក សម្រាប់ផ្គត់ផ្គង់ផលិតកម្មសូត្រ និងការកាត់បន្ថយការនាំចូលសរសៃសូត្រពីបរទេស។

មជ្ឈមណ្ឌលសូត្រខ្មែរទី១ មានទីតាំងនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ត្រូវបានដាក់ដំណើរការជាផ្លូវការនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ បន្ទាប់ពីចាប់ផ្តើមកសាងឡើងនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៨ ដោយចំណាយទឹកប្រាក់ចំនួន ៨ម៉ឺនដុល្លារសម្រាប់កសាង និងជាង១ម៉ឺនដុល្លារទៀតសម្រាប់ចំណាយលើការផលិតសូត្រ ដែលជាជំនួយឥតសំណងពីជប៉ុន។ មជ្ឈមណ្ឌលសូត្រខ្មែរនេះ ត្រូវបានក្រសួងអប់រំចាត់ទុកថាជាកន្លែងស្តារឡើងវិញនូវសូត្រខ្មែរលើកដំបូង៕





# រយៈពេល៩ខែឆ្នាំនេះ បទល្មើសធនធានធម្មជាតិ៩៥៤ករណី ត្រូវបានបង្ក្រាបក្នុងតំបន់ដែនជម្រកសត្វព្រៃ «ព្រៃឡង់»

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្នុងរយៈពេល៩ ខែដើមឆ្នាំ២០២០នេះ គឺចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២០ មន្ត្រីឧទ្យានុរក្ស និងសហគមន៍តំបន់ការពារធម្មជាតិបានចុះល្បាតបានចំនួន១,៨២៣លើក ដែលក្នុងប្រតិបត្តិការចុះល្បាតនោះ បទល្មើសធនធានធម្មជាតិចំនួន៩៥៤ ករណីត្រូវបានបង្ក្រាប។

លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការ និងជាមន្ត្រីនាំពាក្យក្រសួងបរិស្ថានបានឱ្យដឹងនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ថា ក្រសួងបានកសាង និងបញ្ជូនសំណុំរឿងចំនួន៤០ករណីទៅតុលាការ ធ្វើការអប់រំ និងចុះកិច្ចសន្យាបញ្ឈប់សកម្មភាពបានចំនួន៤២០ករណី និងពិន័យអន្តរការណ៍ចំនួន៤១ករណី។

មន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថាន រួមនឹងសមាជិកនៃសហគមន៍តំបន់ការពារធម្មជាតិបង្កើតឡើងដោយស្របច្បាប់ និងទទួលស្គាល់ដោយក្រសួងបរិស្ថានបានបន្តកិច្ចសហការគ្នាក្នុងការចុះល្បាតទប់ស្កាត់ និងបង្ក្រាបបទល្មើសនិងការពារនិងអភិរក្សធនធានធម្មជាតិនៅក្នុងដែនជម្រកសត្វព្រៃតំបន់ព្រៃឡង់។

បរិស្ថាននៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ នេះដោយសង្កេតឃើញថាបទល្មើសនៅតំបន់មួយចំនួនមានការ ថយចុះ ដោយសារតែមានកិច្ចសហការស្អិតរមួតជាមួយសហគមន៍តំបន់ការពារធម្មជាតិ ការបង្កើតស្នាក់ការល្បាតចល័ត ការរៀបចំផែនការល្បាតបានល្អិតល្អន់ និងមានការចូលរួមពីអាជ្ញាធរពាក់ព័ន្ធ។



ជនសង្ស័យដែលត្រូវបង្ក្រាបបានក្នុងពេលធ្វើសកម្មភាពបរបាញ់។ រូបភាព៖ សហការី

លោក នេត្រ ភក្ត្រា បានថ្លែងឱ្យដឹងបន្ថែមទៀតថា នៅក្នុងរយៈពេល៩ខែនេះ មន្ត្រីឧទ្យានុរក្សបានបង្ក្រាបបទល្មើសនិងរឹបអូសរណាយន្តបានចំនួន៤៣៣គ្រឿង រថយន្ត៩គ្រឿង គោយន្តចំនួន១០៦គ្រឿង និងម៉ូតូ៤៦គ្រឿង។ រឹបអូសឈើចំនួន ៣០៣ ម៉ែត្រគូប ដោះអន្ទាក់បានចំនួន ១,៦៧៧ អន្ទាក់ និងដកហូតនិងរឹបអូសកាំភ្លើងកែច្នៃបានចំនួន១០៣ គ្រឿងផងដែរ។

អ្នកនាំពាក្យរូបនេះបានគូសបញ្ជាក់ថា៖ «នេះគឺជាកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីឧទ្យានុរក្ស និងសហគមន៍នៃតំបន់ការពារធម្មជាតិ ក្នុងការការពារ និងអភិរក្សធនធានធម្មជាតិក្នុងតំបន់ព្រៃឡង់ឱ្យបានគង់វង្សសម្រាប់មនុស្សរាប់ជំនាន់ទៅមុខទៀត»។

ជាមួយគ្នានេះ លោក នេត្រ ភក្ត្រា ក៏បានលើកឡើងថា ទោះបីជាមានការចុះទប់ស្កាត់ និងបង្ក្រាបទាំងយប់ទាំងថ្ងៃពីសំណាក់មន្ត្រីឧទ្យានុរក្ស និងសមាជិកនៃសហគមន៍តំបន់ការពារធម្មជាតិក៏បទល្មើសធនធានធម្មជាតិទ្រង់ទ្រាយតូចដូចជាការលបលួចកាប់ឈើ ការទន្ទ្រានរានយកដី ធ្វើជាកម្មសិទ្ធិការបរបាញ់ និងការដាក់អន្ទាក់សត្វព្រៃនៅតែបន្តកើតមាននៅក្នុងតំបន់ព្រៃឡង់ដែលចាំបាច់ត្រូវចាត់វិធានការទប់ស្កាត់និងបង្ក្រាបបន្តទៀត។

លោកបានគូសបញ្ជាក់ថា មានកត្តាផ្សេងៗដែលជំរុញឱ្យមានបទល្មើសទាំងនេះ ក្នុងនោះរួមមាន កត្តាជីវភាពរបស់ប្រជាសហគមន៍ ដែលធ្លាប់តែពឹងអាស្រ័យទៅលើផលអនុផលព្រៃឈើ និងការទាក់ទាញ និងញុះញង់ពីសំណាក់ក្រុមឈ្មួញទុច្ចរិត គួបផ្សំនឹងចំនួនមន្ត្រីឧទ្យានុរក្សដែលបានឈរជើងនៅក្នុងតំបន់នោះ នៅមានកម្រិតនៅឡើយ។

ទោះយ៉ាងណា លោក នេត្រ ភក្ត្រា ថា កម្លាំងមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជាមានការតាំងចិត្តខ្ពស់ក្នុងការទប់ស្កាត់និងបង្ក្រាបយ៉ាងហ្មឹងម៉ាត់ប្រឆាំងនឹងបទល្មើសធនធានធម្មជាតិដែលកើតឡើងស្របតាមច្បាប់នានា។

លោកថា៖ «រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបរិស្ថាន និងដៃគូអភិវឌ្ឍន៍បានយកចិត្តទុកដាក់ខ្ពស់លើការរៀបចំ និងពង្រឹងយន្តការគ្រប់គ្រង ការផ្តល់មធ្យោបាយ ឧបករណ៍ សម្ភារ ក៏ដូចជាការជួយលើកស្ទួយជីវភាពរបស់ប្រជាសហគមន៍មូលដ្ឋានបន្ថែមទៀតតាមរយៈការបង្កើតមុខរបរថ្មី បង្កើតសេដ្ឋកិច្ចនៅមូលដ្ឋាន បង្កើនចំណូលការជំរុញទេសចរណ៍ធម្មជាតិជាដើម ដើម្បីធានាប្រសិទ្ធភាពនៃការងារគ្រប់គ្រង ការពារ និងអភិរក្សតំបន់ព្រៃឡង់»។

បច្ចុប្បន្ននេះ ក្រសួងបរិស្ថានបាននិងកំពុងសហការអនុវត្តគម្រោងការពារនិងអភិរក្សតំបន់ដែនជម្រកសត្វព្រៃនៃព្រៃឡង់ ជាមួយគម្រោងព្រៃឡង់បៃតងគាំទ្រថវិកាដោយ USAID របស់សហរដ្ឋអាមេរិក សម្រាប់រយៈពេល៥ឆ្នាំ(២០១៨-២០២៣) ក្នុងទំហំទឹកប្រាក់២១លានដុល្លារ។

លោក នេត្រ ភក្ត្រា បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ កំពុងអនុវត្តន៍ផែនការសកម្មភាពនានា ដើម្បីធ្វើប្រសើរឡើងនូវការអភិរក្សជីវៈចម្រុះ និងស្ថានភាពប្រព័ន្ធអេកូឡូស៊ីនៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ព្រមទាំងបង្កើតឱ្យមាននិរន្តរភាព និងសមធម៌នៃកាលានុវត្តភាព ផ្នែកសេដ្ឋកិច្ច ជីវភាពសហគមន៍ និងទុនធម្មជាតិសម្រាប់ការវិនិយោគឡើងវិញ នៅក្នុងដែនជម្រកសត្វព្រៃ «ព្រៃឡង់» និងតំបន់ការពារធម្មជាតិជុំវិញតំបន់ព្រៃឡង់។

គម្រោងនេះ មានកិច្ចសហការជាមួយក្រសួងបរិស្ថាន ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីពង្រឹងការការពារ អភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះ ផ្តោតលើការងារកំណត់ និងបែងចែកតំបន់គ្រប់គ្រង ការបោះបង្គោលព្រំប្រទល់ ការរៀបចំផែនការគ្រប់គ្រង និងការចុះបញ្ជីដីរដ្ឋ នៅដែនជម្រកសត្វព្រៃ «ព្រៃឡង់» និងតំបន់ការពារ ធម្មជាតិមួយចំនួនជុំវិញតំបន់ព្រៃឡង់ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាព មន្ត្រីឧទ្យានុរក្ស ក៏ដូចជាលើកកម្ពស់ជីវភាពប្រជាសហគមន៍អភិរក្សប្រពៃណីជនជាតិដើមភាគតិច។

សូមបញ្ជាក់ថា ដែនជម្រកសត្វព្រៃព្រៃឡង់ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យនៅខែឧសភា ឆ្នាំ ២០១៦ មានផ្ទៃដីជាង ៤៣ម៉ឺនហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តចំនួន ៤ រួមមាន ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។ បច្ចុប្បន្ននេះ មានមន្ត្រីឧទ្យានុរក្សចំនួន ៨៤ នាក់បាននិងកំពុងឈរជើងការពារនៅក្នុងនោះ ខេត្តកំពង់ធំមាន៣៤នាក់ ខេត្តស្ទឹងត្រែងមាន ២៤នាក់ ខេត្តក្រចេះមាន១២នាក់ និងខេត្តព្រះវិហារមានចំនួន១៣នាក់ ហើយសហគមន៍តំបន់ការពារធម្មជាតិមានចំនួន ១៩ នៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ ដែលបានចូលរួមសហការចុះល្បាតជាមួយមន្ត្រីឧទ្យានុរក្ស៕

# កូនឈើជាង៤ម៉ឺនដើម ត្រូវបានដាំស្តារព្រៃឡើងវិញ ក្នុងសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មី

*អត្ថបទ៖ អមរិន្ទ ដានុត*

កូនឈើជាង៤ម៉ឺនដើម ត្រូវបានដាំនៅលើផ្ទៃដីចំនួន៥៦ហិចតា ក្នុងចំណោមផ្ទៃដី ៣០០ហិកតា ដែលបានដកហូតពីជនខិលខូច ដែលបានលួចកាប់ទន្ទ្រានព្រៃខុសច្បាប់ នៅសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មី ក្នុងដែនជំរកសត្វព្រៃភ្នំសំកុស ក្នុងភូមិសាស្ត្រភូមិស្ទឹងថ្មី ឃុំប្រម៉ាយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។

អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន លោក ខៀវ បូរិន បានលើកឡើងក្នុងពិធីដាំដើមឈើកាលពីដើមខែតុលា ឆ្នាំ២០២០ថា ការកំណត់យកសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មីដាំកូនឈើ គឺដើម្បីលើកទឹកចិត្តសហគមន៍តំបន់ការពារធម្មជាតិដាំស្តារព្រៃ និងលើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែងចូលរួមការពារ និងអភិរក្សធនធានធម្មជាតិ។

លោកបានថ្លែងថា៖ «ការដាំកូនឈើព្រៃនេះគឺសំរាប់ការអភិរក្សធនធានធម្មជាតិ ជាពិសេសបង្កើនជីវៈចម្រុះ សម្រាប់កូនចៅជំនាន់ក្រោយ។ ព្រៃឈើនៅទីនេះ មិនអាចផ្តល់ផលទៅដល់គាត់ផ្ទាល់មែន ប៉ុន្តែវាអាចអភិរក្សជីវៈចម្រុះ ហើយអាចរក្សាទឹក និងទាក់ទាញទឹកភ្លៀង តាមរយៈការថែរក្សាព្រៃឈើឱ្យបានល្អនេះ»។

លោក ខៀវ បូរិន បានបញ្ជាក់ទៀតថា ទៅថ្ងៃខាងមុខ ក្រសួងបរិស្ថានមានគម្រោងដាំដើមអាកាស្យា ដែលកំពុងមានតម្រូវការខ្ពស់ និងអាចប្រមូលផលនៅក្នុងរយៈពេល៥ទៅ៦ឆ្នាំខាងមុខ នៅក្នុងដីនៃផ្នែកណាមួយតំបន់សហគមន៍នេះ ជាមួយគ្នានេះក្រសួងនឹងពិនិត្យលើលទ្ធភាពគម្រោងលើកកម្ពស់ជីវភាពសហគមន៍ តាមរយៈការផ្តល់ពូជមាន់ គោ ពពែ ជ្រូក ដែលជួយបង្កើននូវចំណូលរបស់សហគមន៍ ដែលជាអ្នកទទួលផលផ្ទាល់។

ក្នុងឱកាសនោះ លោក វត្ថ វិរៈ អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន បានបញ្ជាក់ថា ការចូលរួមរបស់អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋសហគមន៍ដោយផ្ទាល់ដាំស្តារព្រៃនៅពេលនេះ គឺជាការបង្ហាញពីស្មារតីស្រលាញ់ធនធានធម្មជាតិ ដែលរួមមានព្រៃឈើ សត្វព្រៃជាដើម។ ទាំងអស់នេះគឺជាផ្នែកមួយនៃការទាក់ទាញទឹកភ្លៀង រក្សាលំនឹងធម្មជាតិការពារខ្យល់ព្យុះ និងគ្រោះធម្មជាតិផ្សេងៗ។

លោកបានមានប្រសាសន៍ថា៖ «ព្រៃឈើនៅក្នុងតំបន់នេះគឺជាប្រភេទព្រៃរបោះ ដែលអាចឱ្យសត្វគ្រប់ប្រភេទរស់នៅបាន ហេតុដូច្នេះ ប្រសិនបើយើងការពារព្រៃឈើ សត្វព្រៃ បាននោះយើងនិងបានថវិកាជួយដល់ការអភិវឌ្ឍជីវភាពសហគមន៍»។

លោក វត្ថ វិរៈ បានសង្កត់ធ្ងន់បន្តថា នៅពេលខាងមុខក្រសួងបរិស្ថាននិងចូលរួមអភិវឌ្ឍន៍នៅក្នុងតំបន់នេះ ឱ្យមានប្រភពចំណូលតាមរយៈការ បង្កើតជាតំបន់ទេសចរណ៍ធម្មជាតិ ដែលទេសចរ អាចមកមើលសត្វព្រៃ និងព្រៃឈើ នៅក្នុងតំបន់នេះផងដែរ។

គួរបញ្ជាក់ថា សហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មី បានបង្កើតឡើងនៅឆ្នាំ២០១០ គ្រប់គ្រងនៅលើផ្ទៃដី ចំនួនទំហំ ៧១២ ហិកតា មានការចូលរួមពីប្រជាជនចំនួន ១១០គ្រួសារ។





ការដាំដើមឈើនៅសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មី ក្នុងដែនជំរកសត្វព្រៃភ្នំសំកុស ក្នុងភូមិសាស្ត្រភូមិស្ទឹងថ្មី។ រូបភាព៖ សហការី

កូនឈើព្រៃដែលបានដាំប្រមាណជាង ៤ម៉ឺនដើមនៅពេលនេះ ជាប្រភេទឈើគ្រញូង ធ្នង់ បេង គគីរ ឈើទាលកកោះជាដើម ដែលនាយកដ្ឋានជីវភាពសហគមន៍ បានទទួលថវិកាពី UNDP សម្រាប់ការដាំស្តារព្រៃឈើ និងលើកកម្ពស់ជីវភាពសហគមន៍ (គ្រួសាររងផលប៉ះពាល់ដោយសារជំងឺកូវីដ ១៩០គ្រួសារ) និងមជ្ឈមណ្ឌលសម្រាប់មនុស្សនិងព្រៃឈើ (RECOFTC) បានគាំទ្រថវិកា និងចូលរួមក្នុងសកម្មភាពដាំស្តារកូនឈើនេះផងដែរ៕

# ចំនួនសត្វផ្សោតហាក់នៅថេរ ខណៈ អ្នកស្រាវជ្រាវ និងអភិរក្សកំពុងតាមរកសត្វផ្សោត ចំនួន២៥ក្បាលដែលបានបាត់ខ្លួនពុំដឹងមូលហេតុ

*អត្ថបទៈ អមរិន្ទដានុត*

ចំនួនសត្វផ្សោតទន្លេមេគង្គស្ថិតក្នុងកម្រិតថេរ ប៉ុន្តែចាំបាច់ត្រូវមានវិធានការបន្ទាន់រួមគ្នានិងថ្មីខ្លាំងក្លាជាងមុនដើម្បីការពារសត្វផ្សោតឱ្យជៀសផុតពីការផុតពូជ។ យោងតាមសេចក្តីថ្លែងការណ៍រួមរបស់រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការ WWF។

តាមរបាយការណ៍ឆ្នាំ២០២០ ស្តីពីស្ថានភាពសត្វផ្សោត ដែលបានធ្វើឡើងរួមគ្នាដោយរដ្ឋបាលជលផល និងអង្គការ WWF បានបង្ហាញថា ចំនួនសត្វផ្សោតទន្លេមេគង្គបច្ចុប្បន្នមានត្រឹមតែ ៨៩ក្បាល ប៉ុណ្ណោះ។ អ្នកវិទ្យាសាស្ត្របានពន្យល់ថា ចំនួននេះជាចំនួនស្ថិតក្នុងកម្រិតថេរ ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ។


ត្រីផ្សោតនៅទន្លេមេគង្គក្នុងខេត្តក្រចេះនាពេលកន្លងមក។ **រូបភាពៈ សហការី**

លទ្ធផលសំខាន់ៗនៃការសិក្សាស្រាវជ្រាវនេះក៏បានបង្ហាញឱ្យឃើញពីអត្រាវិជ្ជមាននៃការរស់រានរបស់កូនផ្សោតរហូតដល់ធំពេញវ័យ ដោយក្នុងនោះ ៤,២២% ជាអត្រារាប់ថ្មីខ្ពស់បំផុតដែលមិនធ្លាប់ត្រូវបានកត់ត្រាទុកក្នុងប្រវិត្តសិក្សាអង្កេតចំនួនសត្វផ្សោតក្នុងរយៈកាលមួយទសវត្សរ៍ចុងក្រោយនេះ ដែលជាសញ្ញាបង្ហាញពីទំនោរនៃកំណើនសន្សឹមៗនៃចំនួនសត្វផ្សោតទន្លេមេគង្គ។

សេចក្តីថ្លែងការណ៍រួមនេះបានលើកឡើងថា សត្វផ្សោតទន្លេមេគង្គ (Orcaella brevirostris) រស់នៅតាមទន្លេមេគង្គប្រវែង ១៨០ គីឡូម៉ែត្រ ចន្លោះទីរួមខេត្តក្រចេះ ប្រទេសកម្ពុជា និងល្បាក់ខោនក្នុងខេត្តស្ទឹងត្រែង ជាប់ព្រំដែនប្រទេសឡាវ។ ទោះយ៉ាងណាក៏ដោយ អ្នកវិទ្យាសាស្ត្រក៏សម្តែងការព្រួយបារម្ភចំពោះអវត្តមានរបស់សត្វផ្សោតនៅក្នុងអន្លង់ចំនួនប្រាំមួយដែលពួកវាធ្លាប់រស់នៅពីមុន។ នៅក្នុងការសិក្សាស្រាវជ្រាវឆ្នាំនេះ គេសង្កេតឃើញថាសត្វផ្សោតប្រើប្រាស់អន្លង់តែចំនួនបីប៉ុណ្ណោះ គឺអន្លង់កាំពី កោះកូនសត្វ និងឈើទាល។

> ការបង្កើនការពង្រឹងការអនុវត្តច្បាប់ ការជម្រុញបន្ថែមការអភិវឌ្ឍរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងការកំណត់វិធានអភិរក្សសត្វផ្សោតទន្លេមេគង្គនៅក្នុងតំបន់ព្រំដែនកម្ពុជាឡាវ រាប់បញ្ចូលទាំងលំហូរទឹកទន្លេ និងបម្រែបម្រួលអាកាសធាតុ សុទ្ធសឹងជាកិច្ចការសំខាន់ៗ...

គួរកត់សម្គាល់ផងដែរថាសត្វផ្សោតចំនួន ២៥ ក្បាល ដែលធ្លាប់ត្រូវបានគេកត់ត្រាក្នុងរបាយការណ៍ឆ្នាំ២០១៧ មិនត្រូវបានគេប្រទះឃើញក្នុងអំឡុងពេលនៃការស្រាវជ្រាវឆ្នាំ២០២០ ទេ។ អ្នកវិទ្យាសាស្ត្រសង្ស័យថាសត្វផ្សោតទាំង ២៥ ក្បាល នេះ បានផ្លាស់ទីទៅចេញពីតំបន់នៃទីជម្រកបច្ចុប្បន្នរបស់វាទៅកាន់ទីតាំងដទៃទៀតក្នុងទន្លេ ដែលមិនស្ថិតក្នុងតំបន់ស្រាវជ្រាវសត្វផ្សោតទេ។ តទៅមុខទៀត ក្រុមអ្នកវិទ្យាសាស្ត្រនឹងបន្តតាមដានស្ថានភាពសត្វផ្សោតឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។





លោក ស្រ៊ុន លឹមសុង អគ្គនាយករងនៃរដ្ឋបាលជលផល បានមានប្រសាសន៍ថាៈ «រដ្ឋបាលជលផលសូមទទួលស្គាល់និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឆ្មាំទន្លេក្នុងការពង្រឹងការអនុវត្តច្បាប់ដោយសហការដោយអាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន ក្នុងខេត្តក្រចេះនិងស្ទឹងត្រែង ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កានិងទប់ស្កាត់ការនេសាទខុសច្បាប់ក្នុងតំបន់ការពារជម្រកសត្វផ្សោតទន្លេមេគង្គ»។

ទោះយ៉ាងណាក៏ដោយ សត្វផ្សោតទន្លេមេគង្គនៅតែប្រឈមនឹងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ។ មងនេសាទ ការសាងសង់ទំនប់នៅតាមទន្លេមេគង្គផ្នែកខាងលើ ការនេសាទហួសកម្រិត ការនេសាទខុសច្បាប់ដូចជា ប្រើប្រាស់ឧបករណ៍ឆក់ នុយពុល គ្រាប់បែកកែច្នៃ សុទ្ធសឹងជាកត្តាគម្រាមកំហែងចម្បងៗដល់ការរស់រានមានជីវិតរបស់សត្វផ្សោតទន្លេមេគង្គ។

នាយកអង្គការ WWF-កម្ពុជា លោក សេង ទៀក បានថ្លែងឱ្យដឹងផងដែរថា បើទោះបីជាលទ្ធផលនៃការស្រាវជ្រាវឆ្នាំ២០២០ បញ្ជាក់ថាចំនួនសត្វផ្សោតស្ថិតក្នុងអត្រាថេរក៏ដោយ ចំនួននេះនៅតែជាចំនួនមួយទាប ដែលទាមទារឱ្យមានការដាក់ចេញនូវវិធានការអភិរក្សខ្លាំងក្លាជាងមុនជាចំបាច់។

លោក សេង ទៀក ថាៈ «ដើម្បីធានាបានថាសត្វផ្សោតទន្លេមេគង្គដែលជាប្រភេទជិតផុតពូជអាចកើនឡើងបាន លុះណាតែតំបន់នៃទីជម្រករបស់ពួកវា គ្មានការនេសាទខុសច្បាប់ ហើយមានចំណីគ្រប់គ្រាន់»។

លោកបានបញ្ជាក់ទៀតថា ការបង្កើនការពង្រឹងការអនុវត្តច្បាប់ ការជម្រុញបន្ថែមការអភិវឌ្ឍរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងការកំណត់វិធានអភិរក្សសត្វផ្សោតទន្លេមេគង្គនៅក្នុងតំបន់ព្រំដែនកម្ពុជាឡាវ រាប់បញ្ចូលទាំងលំហូរទឹកទន្លេ និងបម្រែបម្រួលអាកាសធាតុ សុទ្ធសឹងជាកិច្ចការសំខាន់ៗដែលគេចាំបាច់ត្រូវអនុវត្ត៕





# ព្រឹត្តិការណ៍ថ្ងៃ៣វិច្ឆិកាគឺជា បទពិសោធមួយសម្រាប់កម្ពុជា

*អត្ថបទៈ អមរិន្ទដានុត*

ការមើលស្រាល ការធ្វេសប្រហែស និង ការមិនយកចិត្តទុកដាក់របស់យើងទាំងអស់គ្នាអាចជាប្រភពនៃការបាក់អំនួតរបស់កម្ពុជា ក្នុងការបង្ការនិងទប់ស្កាត់នូវការរីករាលដាលនៃមេរោគកូវីដ ១៩ ក្រោយពេលដែលយើងត្រូវបានគេសរសេរអំពីជោគជ័យនៃការទប់ស្កាត់នូវការរីករាលដាលចូលសហគមន៍អស់រយៈពេលជិតមួយឆ្នាំកន្លងមកនេះ។





សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានធ្វើតេស្តិ៍អវិជ្ជមាន និង លោក ភីធើ ស៊ីចាតូ (ស្តាំ) រដ្ឋមន្ត្រីក្រសួងការបរទេស និងពាណិជ្ជកម្មហុងគ្រី បានធ្វើតេស្តវិជ្ជមាន សម្រាប់វីរុស Covid-១៩ បន្ទាប់ពីបានទៅដល់ទីក្រុងបាងកក។ **រូបភាពៈ សហការី**

យោងតាមការសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាលតាំងពីមានករណីឆ្លងដំបូងនៅចុងខែមករា នៅលើខ្លួនអ្នកទេសចរជនជាតិចិននៅខេត្តព្រះសីហនុ។ ករណីនៃការរកឃើញគឺមានជាបន្តបន្ទាប់ រហូតជាង៣០០ ករណី ប៉ុន្តែមុនព្រឹត្តិការណ៍ថ្ងៃ៣វិច្ឆិកា គឺមានតែមួយករណីតែប៉ុណ្ណោះដែលយើងអាច និយាយបានថា ឆ្លងនៅក្នុងសហគមន៍ គឺការរកឃើញលើខ្លួនបុរសខ្មែរនៅខេត្តសៀមរាប ដែលបាន ប៉ះពាល់ជាមួយនឹងអ្នកឆ្លងជនជាតិជប៉ុន ដែលរកឃើញក្រោយពេលចាកចេញពីកម្ពុជា និងខ្មែរមួយរូបមកពីម៉ាឡេស៊ីឆ្លងទៅកាន់ប្រពន្ធ ហើយតាំងពីនោះមកដល់ព្រឹត្តិការណ៍៣ វិច្ឆិកា ទើបបានមាន៤ករណីទៀតដែលគឺខ្មែរបីរូប និងអ្នកការទូតហុងគ្រី។

សូមកុំធ្វេសប្រហែស និងមើលស្រាលបញ្ហាការរីករាលដាលនេះឱ្យសោះ ហើយម្យ៉ាងទៀតសូមកុំផ្ញៀតឱកាស ពីព្រោះនៅក្នុងស្ថានភាពបែបនេះ មានអ្នកខ្លះក្រឡុកសភាពការណ៍ដោយព្យាយាមយកករណីចាស់ៗ ដែលធ្លាប់ចែកចាយតាមបណ្តាញសង្គមយកមកបង្កហេតុជាថ្មី បង្កភាពវឹកវរ ភិតភ័យនិងបន្លាចប្រជាពលរដ្ឋកាន់តែខ្លាំង។

ខណៈដែលពេលនេះ មេរោគកូវីដ១៩បានឆ្លងលើសពី ៥១ លាននាក់ហើយនៅលើពិភពលោក ខណៈនៅសហភាពអឺរ៉ុប គឺកំពុងជជែកគ្នា អំពីច្បាប់ប្រកាសដាក់តំបន់នៅក្នុងគ្រាអាសន្នផ្នែកសុខភាពផងដែរ។



លោក ភីធើ ស៊ីចាតូ រដ្ឋមន្ត្រីក្រសួងការបរទេស និងពាណិជ្ជកម្មហុងគ្រី ជាមួយលោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសក្នុងពិធីសម្ពោធស្ថានទូតហុងគ្រីនៅក្នុងរាជធានីភ្នំពេញនៅថ្ងៃទី ៣ ខែវិច្ឆិកា។ **រូបភាពៈ ខ្មែរថាមស៍/ទីម សុវណ្ណារា**

មកដល់ពេលនេះ ការឆ្លងជាសហគមន៍នៅក្នុងបន្ទាត់ពណ៌លឿងទុំនៅឡើយទេ។ ក្រុមគ្រួសារនិងអ្នកដែលប៉ះពាល់នឹងអ្នកដែលរកឃើញវិជ្ជមានទាំងបួនករណីត្រូវតែធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវដោយឡែក សមាជិកក្រុមគ្រួសារនិងមិត្តភក្តិអ្នកដែលកំពុងតែធ្វើតេស្ត ហើយរង់ចាំលទ្ធផល រយៈពេល ៤ ដង ក៏ត្រូវតែយកចិត្តទុកដាក់ការពារខ្លួន និង បង្ការការឆ្លងទៅដល់អ្នកដទៃផងដែរ។ ក្រោយពេលធ្វើតេស្តបង្ហាញលទ្ធផលអវិជ្ជមាន៤ ដងហើយ ទើបអាចថារួចខ្លួន ប៉ុន្តែការពារខ្លួន ដោយការធ្វើអនាម័យដៃលាងជាមួយនឹងអាកុល សាប៊ូ ឬដែលឱ្យបានញឹកញាប់ ត្រូវពាក់ម៉ាស់ ត្រូវរក្សាគន្លាតសង្គម និង រស់នៅស្អាត។

សរុបមកវិញការមើលស្រាល ការធ្វេសប្រហែស និង ការមិនយកចិត្តទុកដាក់ ចំពោះជំងឺនេះ គឺជាបរាជ័យរបស់យើងទាំងអស់គ្នានៅក្នុងការពារមេរោគនេះ។ សូមភ្ញាក់រលឹកឡើង សភាពការណ៍វាមិនទាន់ហួសពេលនៅឡើយទេ បើយើងទាំងអស់គ្នាអាចការពារការឆ្លងនិងការរីករាលដាលបន្ថែមបាននោះ គឺជាជោគ ជ័យថ្មីមួយ ហើយក៏ជាអំនួតមួយថ្មីសម្រាប់ជាតិយើងផងដែរ៕

## កុលាលភាជន៍ដែលបានពីការស្តារប្រឡាយនៅបរិវេណប្រាសាទព្រះខ័ន ត្រូវបានយកមករក្សា និងជួសជុល

*អត្ថបទៈ អមរិន្ទដានុត*

អាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា កុលាលភាជន៍ចំនួន១៩ ថ្មផុសថ្មាំចំនួន២ អង្រែកិនថ្នាំ១ និងបំណែកលុលាលភាជន៍ចំនួន៣០ ដែលបានរកឃើញពីការស្តារប្រឡាយនៅបរិវេណថ្នាលបណ្តុះកូនឈើប្រាសាទព្រះខ័នកាលពីដើមឆ្នាំ២០២០ ត្រូវបានយកមករក្សាទុកដើម្បីជួសជុល។

លោក ញ៉ែម រស្មី មន្ត្រីនាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថា កុលាលភាជន៍និងថ្មកិនថ្នាំ ដែលរកឃើញដ៏ច្រើននេះ គឺជីកបាននៅខែមីនាឆ្នាំ២០២០ នៅពេលក្រុមការងារស្តារប្រឡាយចំនួន១៧០០ម៉ែត្រនៃបរិវេណប្រាសាទព្រះខ័ន។

ប្រភពដដែលបានបន្តថា វត្ថុបុរាណទាំងអស់នេះ ស្ថិតនៅរាយប៉ាយពីគ្នា ក្នុងជម្រៅ១ម៉ែត្រជាង។ ក្រោយប្រទះឃើញក្រុមការងារក៏បានរក្សាទុកវត្ថុបុរាណទាំងអស់ រហូតដល់បញ្ចប់ការស្តារប្រឡាយ ទើបប្រគល់ជូនមជ្ឈមណ្ឌលស្រាវជ្រាវនិងតម្កល់ឯកសារអង្គរយកទៅអភិរក្ស ដោយមានការដឹងឮពីនគរបាលបេតិកភណ្ឌជាសាក្សី។



កុលាលភាជន៍ដែលបាយកមករក្សា និងជួសជុល។ **រូបភាពៈ សហការី**

ចំពោះកិច្ចអភិរក្សវត្ថុបុរាណទាំងអស់នេះ អាជ្ញាធរជាតិអប្សរានឹងយកទៅរក្សាទុក ដើម្បីចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈ ដុសសម្អាត រួមទាំងជួសជុលឱ្យផុតពីហានិភ័យទុកជាសម្បត្តិជាតិ ពិសេសគឺសម្រាប់សិក្សាស្រាវជ្រាវពីប្រវត្តិបន្ថែមទៀត៕

# ទិវាពិភពលោកលាងសម្អាតដៃ និងទិវាអនាម័យតាមគ្រឹះស្ថានសិក្សាក្នុងបរិបទជំងឺកូវីដ១៩



*លោក ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងពិធីប្រារព្ធទិវាពិភពលោកលាងសម្អាតដៃ។ **រូបភាព៖ សហការី***

*អត្ថបទ៖ អមរិន្ទ្រ ដានុត*

ទិវាពិភពលោកលាងសម្អាតដៃ (Global Hand Washing Day) ត្រូវបានផ្តួចផ្តើមរៀបចំឡើងដំបូងនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៨ នៅទូទាំងពិភពលោក ហើយបច្ចុប្បន្នត្រូវបានគេកំណត់យកថ្ងៃដ៏សំខាន់មួយ ដើម្បីគាំទ្រ និងក្រើនរំលឹកដល់សាធារណៈជន ឱ្យចូលរួមលើកកម្ពស់ផ្សព្វផ្សាយអំពីសារៈសំខាន់នៃអនាម័យដៃ។

នេះជាការលើកឡើងរបស់លោកបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានថ្លែងក្នុងពិធីប្រារព្ធទិវាពិភពលោកលាងសម្អាតដៃដែលធ្វើឡើងក្នុងវិទ្យាល័យពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។

លោករដ្ឋមន្ត្រីបានលើកឡើងថា ការលាងដៃជាមួយនឹងសាប៊ូ ជាវិធីមួយក្នុងចំណោមវិធីនានាដែលមានប្រសិទ្ធិភាព និងសាមញ្ញបំផុត ដើម្បីបញ្ឈប់ការរីករាលដាលនៃវីរុស ពិសេសការរាតត្បាតនៃមេរោគកូវីដ១៩។ ដូចនេះ ការលាងដៃនឹងសាប៊ូត្រូវតែជាអាទិភាពមួយនៅពេលបច្ចុប្បន្ននេះ និងទៅអនាគត។ យើងលាងសម្អាតដៃសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យសង្គមទាំងមូលចូលរួមរក្សាអនាម័យដៃជាសកល។

លោកបន្តថា៖ «ការលាងដៃជាមួយសាប៊ូ កាត់បន្ថយការឆ្លងជំងឺមួយចំនួនដូចជា ជំងឺរាគរូសបាន៥០% ជំងឺផ្លូវដង្ហើមបាន២៣% និងជំងឺរាតត្បាតដែលជាភ្នាក់ងារបង្កជំងឺដូចជា ជំងឺអាសន្នរោគ អេបូឡា ជំងឺស៊ីហ្គែឡូសស៊ីស (shigel-losis) ជំងឺសារ (SARS) និងជំងឺរលាកថ្លើមប្រភេទEទៀតផង»។

ការប្រារព្ធទិវាពិភពលោកលាងសម្អាតដៃ និងអនាម័យនៅតាមគ្រឹះស្ថានសិក្សានាពេលនេះ គឺជាការជួយជំរុញបន្ថែមទៀត សម្រាប់ចូលរួមដើម្បីឈានទៅសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅឆ្នាំ ២០២៥ ព្រោះថាការលាងសំអាតដៃនេះ នឹងកាត់បន្ថយអត្រាឆ្លងជំងឺផ្សេងៗតាមរយៈដៃមិនស្អាត ពិសេសកាត់បន្ថយអត្រាមរណភាពរបស់កុមារទាក់ទងនឹងជំងឺរលាកផ្លូវដង្ហើម និងបញ្ហាកង្វះអាហារូបត្ថម្ភដែលតែងតែកើតឡើងចំពោះកុមារដោយគ្រាន់តែលាងដៃនឹងសាប៊ូ។

លោក ម៉េង គឹមសាន ទីប្រឹក្សាគម្រោងអនាម័យគំរូតាមសាលារៀន អង្គការ GIZ ក៏បានលើកឡើងដែរថា យោងតាមការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រកន្លងមកបានបង្ហាញថា ការលាងសម្អាតដៃជាមួយទឹកស្អាតនិងសាប៊ូអាចជួយកាត់បន្ថយករណីជំងឺរាគរូសជាមធ្យម៣៥% និងកាត់បន្ថយហានិភ័យនៃជំងឺផ្លូវដង្ហើម១៦%។ ដោយឡែក អត្រាលាងសម្អាតដៃក្រោយប្រើប្រាស់បង្គន់ទូទាំងពិភពលោកមានតែ១៩%ឬមានតែម្នាក់ក្នុងចំណោមប្រាំនាក់ប៉ុណ្ណោះ ដែលបានលាងសម្អាតដៃជាមួយសាប៊ូ។

លោក ម៉េង គឹមសាន បានលើកឡើងថា ប្រសិនបើអត្រាលាងសម្អាតដៃទូទាំងពិភពលោកបច្ចុប្បន្ន នៅតែមានកម្រិតទាបបែបនេះ នោះករណីនិងហានិភ័យនៃការចម្លងរោគរាគរូសនិងជំងឺផ្លូវដង្ហើមជាពិសេសការរាតត្បាតនៃជំងឺកូវីដ១៩ នឹងមានសភាពធ្ងន់ធ្ងរទូទាំងពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ។

លោកបានថ្លែងថា៖ «ដូច្នេះដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងជំងឺកូវីដ១៩ និងរោគរាតត្បាតផ្សេងៗ យើងទាំងអស់គ្នាត្រូវតែលាងសម្អាតដៃជាមួយទឹកស្អាត និងសាប៊ូ ឬជាមួយទឹកអាល់កុល ឬអាល់កុលដែលឱ្យបានញឹកញាប់ និងហាមយកដៃដែលពុំទាន់បានលាងសម្អាតទៅប៉ះមាត់ ច្រមុះ និងភ្នែកដាច់ខាត»។

ដើម្បីរួមចំណែកបង្ការទប់ស្កាត់ហានិភ័យនៃការចម្លងជំងឺកូវីដ១៩ និងជំងឺឆ្លងនានាក្នុងសាលារៀននិងសហគមន៍ អង្គការដៃគូពាក់ព័ន្ធនានាបាននិងកំពុងជួយជ្រោមជ្រែងលើកកម្ពស់កម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន។ ជាក់ស្តែងក្រោមកិច្ចសហការយ៉ាងសកម្មនិងជិតស្និទ្ធពីនាយកដ្ឋានសុខភាពសិក្សា និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត គម្រោងអនាម័យគំរូតាមសាលារៀននៃអង្គការ GIZអាល្លឺម៉ង់ បាននិងកំពុងជួយជំរុញសិស្សានុសិស្សឱ្យមានទម្លាប់លាងសម្អាតដៃ ដុសសម្អាតធ្មេញ និងលេបថ្នាំទំលាក់ព្រូនពីរដងក្នុងមួយឆ្នាំតាមសាលារៀន។

លោក ម៉េង គឹមសាន បានមានប្រសាសន៍ថា៖ «ជាងនេះទៅទៀតដើម្បីរួមចំណែកបង្ការទប់ស្កាត់ជំងឺកូវីដ១៩តាមសាលារៀន បច្ចុប្បន្នក្រុមការងារគម្រោងអនាម័យគំរូតាមសាលារៀន កំពុងខ្នះខ្នែងរៀបចំទម្លាក់កញ្ចប់ថវិកាបន្ថែមប្រមាណ ១២៥,០០០ដុល្លារបន្ថែមទៀត ទៅខេត្តគោលដៅទាំង៥របស់ខ្លួនរួមមាន ខេត្តកំពង់ចាម ត្បូងឃ្មុំ ស្ទឹងត្រែង រតនៈគិរី និងមណ្ឌលគិរី តាមរយៈមន្ទីរអប់រំ យុវជន និងកីឡានីមួយៗដើម្បីសាងសង់បរិក្ខារលាងសម្អាតដៃ និងផ្តល់នូវសម្ភារៈអនាម័យនានាសម្រាប់សាលារៀន ដែលពុំទាន់មានសម្ភារៈបរិក្ខារគ្រប់គ្រាន់»។

លោកថា ក្នុងនាមដៃគូអភិវឌ្ឍន៍គម្រោងអនាម័យគំរូតាមសាលារៀននៃអង្គការ GIZ នៅតែប្តេជ្ញាបន្តជួយគាំទ្រទាំងស្មារតី បច្ចេកទេស និងហិរញ្ញវត្ថុតាមលទ្ធភាពរបស់ខ្លួន ដើម្បីលើកកម្ពស់កម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀនរហូតដល់ចុងបញ្ចប់នៃគម្រោង។

យោងតាមទិន្នន័យរវាងឆ្នាំ ២០១៩-២០២០នៃគោលការណ៍អនុវត្តន៍លក្ខខណ្ឌអប្បបរមាស្តីពីទឹកស្អាត និងអនាម័យតាមសាលារៀន គឺសាលារៀនចំនួន៣,៦៣២មានបរិក្ខារលាងសម្អាតដៃទោល (ឬស្ថិតនៅកម្រិតផ្កាយ១) និងសាលារៀនចំនួន២,៣៦៧មានបរិក្ខារលាងសម្អាតដៃជាក្រុម (ឬស្ថិតនៅកម្រិតផ្កាយ២និងផ្កាយ៣)៕

# ក្រសួងអភិវឌ្ឍន៍ជនបទជំរុញឱ្យសង្គមបន្តយកចិត្តទុកដាក់លើបញ្ហាអនាម័យនិងកង្វះទឹកស្អាតនៅក្នុងប្រទេស

*អត្ថបទ៖ អរិយបុត្រ*

មន្ត្រីជាន់ខ្ពស់នៃក្រសួងអភិវឌ្ឍន៍ជនបទ បានជំរុញឱ្យភាគីដែលពាក់ព័ន្ធបន្តយកចិត្តទុកដាក់ លើបញ្ហាអនាម័យ និងបញ្ហាទឹកស្អាតនៅក្នុងសង្គម ហើយអះអាងថា នេះគឺជាបញ្ហាដែលទាំងអស់គ្នាយកចិត្តទុកដាក់។

លោក ជ្រុន ថេរ៉ាវ៉ាត់ រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទបានថ្លែងឱ្យដឹងថា កម្ពុជាកំពុងតែស្ថិតនៅលើផ្លូវក្នុងការឈានទៅសម្រេចឱ្យបានលើបញ្ហាទឹកស្អាត និងការគ្រប់គ្រងអនាម័យជនបទឱ្យគ្របដណ្តប់១០០ ភាគរយនៅទូទាំងប្រទេសនៅក្នុងឆ្នាំ២០២៥ខាងមុខ ប៉ុន្តែកត្តាពីរដែលអាចជាឧបសគ្គឈាននៅក្នុងការអនុវត្តនូវគោលដៅនេះ គឺបញ្ហាកូវីដ១៩ ដែលកំពុងតែប្រឈមនឹងបញ្ហាដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដូចដែលកម្ពុជាកំពុងតែប្រឈមមុខនឹងបញ្ហាគ្រោះទឹកជំនន់ដែលកំពុងតែជនលិចខេត្ត និងរាជធានីជាច្រើននៅពេលបច្ចុប្បន្ននេះ។

លោកបានបញ្ជាក់ប្រាប់អ្នកសារព័ត៌មានថា កូវីដ១៩ នៅតែជាបញ្ហាមិនច្បាស់លាស់មួយនៅលើសកលលោកដែលកំពុងតែជះឥទ្ធិពលជាច្រើនលើការអភិវឌ្ឍ និងការកំណត់គោលដៅនៃការអភិវឌ្ឍផ្សេងៗ ដូច្នេះវាគឺជាបញ្ហាប្រឈមមួយរបស់កម្ពុជានៅក្នុងការឈានទៅសម្រេចឱ្យបាននូវគោលដៅលើបញ្ហាអនាម័យ និងទឹកស្អាតនៅជនបទនេះផងដែរ។ ដោយឡែករឿងបម្រែបម្រួលអាកាសធាតុក៏ជាបញ្ហាជាក់ស្តែងមួយដែលកំពុងតែកើតមាន។

លោកបានបន្តទៀតថា បម្រែបម្រួលអាកាសធាតុ វាគឺជាបញ្ហាដែលគ្មាននរណាអាចទស្សន៍ទាយបាន ជាក់ស្តែងគ្រោះទឹកជំនន់ដែលកំពុងតែកើតមានវាគឺជាក្តីបារម្ភមួយនៅក្នុងការសម្រេចបាននូវគោលដៅដែលកម្ពុជាបានកំណត់ ដូច្នេះហើយលោកបានជំរុញឱ្យសារព័ត៌មានក៏ដូចជាអ្នកដែលពាក់ព័ន្ធធ្វើយ៉ាងណាជំរុញ និងផ្សព្វផ្សាយក៏ដូចជាអនុវត្តន៍នូវផែនការអនាម័យ និងការជំរុញការយកចិត្តទុកដាក់នឹងបញ្ហាទឹកស្អាត ហើយរឹតតែត្រូវតែយកចិត្តទុកដាក់ថែមទៀតនោះ គឺនៅក្នុងអំឡុងពេលដែលប្រជាពលរដ្ឋកម្ពុជាកំពុងតែប្រឈមជាមួយនឹងបញ្ហាទឹកជំនន់នាពេលថ្មីៗនេះ។

នាឱកាសនោះលោករដ្ឋលេខាធិការ ក៏បានជំរុញឱ្យអ្នកដែលពាក់ព័ន្ធយកចិត្តទុកដាក់លើបញ្ហាអនាម័យជាពិសេស គឺការគ្រប់គ្រងលាមកឱ្យបានត្រឹមត្រូវពីព្រោះលាមកគឺជាប្រភពចម្លងនូវមេរោគមួយដ៏ចំបងជាពិសេស នៅក្នុងអំឡុងពេលនៃគ្រោះទឹកជំនន់ដូចពេលសព្វថ្ងៃនេះ។

លោកបានបញ្ជាក់ថា លាមកជាប្រភពនៃមេរោគ ដោយនៅក្នុងលាមកដែលមនុស្សម្នាក់បន្ទោរបង់មានទម្ងន់ប្រហែល ៣០០ ក្រាមក្នុងមួយថ្ងៃ ហើយនៅក្នុងនោះក្នុងចំណោមលាមក១ក្រាម វាផ្ទុកទៅដោយមេរោគចំនួន១០លាន នៅមានបាក់តេរី ប៉ារ៉ាស៊ីត ។ល។

នាឱកាសនោះដែរ លោក ទ្រី ម៉េង រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទមួយរូបទៀត ក៏បានថ្លែងលើកទឹកចិត្តឱ្យទាំងអស់គ្នាយកចិត្តទុកដាក់លើបញ្ហានេះ។

លោកបានបញ្ជាក់ថា បញ្ហាអនាម័យ និងទឹកស្អាតនេះ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធបានសម្រេចសមិទ្ធិផលច្រើនដែរ ប៉ុន្តែទាំងអស់គ្នាទាមទារបន្តនូវការប្តេជ្ញាចិត្តថែមទៀតដើម្បីឈានទៅសម្រេចតាមគោលដៅដែលបានគ្រោងទុក ហើយឈានឆ្ពោះទៅបន្តកែលំអរ និងលើកកំពស់មួយកម្រិតទៀត។

លោកវេជ្ជបណ្ឌិត ជា សំណាង អ្នកសម្របសម្រួលជាតិ ក្រុមប្រឹក្សាសហប្រតិបត្តិការទឹក និងអនាម័យបានថ្លែងថា មូលហេតុដែលបញ្ហាទឹកស្អាត និងអនាម័យនេះវាគឺជាបញ្ហាអទិភាពរបស់រាជរដ្ឋាភិបាលក៏ដូចជាពិភពលោក គឺដោយសារតែវាជាប្រភពនៃហានិភ័យនៃផលប៉ះពាល់ដល់សុខភាពផ្សេងៗ រាប់តាំងពីជំងឺគ្រិន ជំងឺរាគរូស ដង្កូវព្រូន សើរស្បែកនិងផ្លូវដង្ហើម៕



*លោក ជ្រុន ថេរ៉ាវ៉ាត់ រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ពេលចុះពិនិត្យតំបន់រងគ្រោះដោយទឹកជំនន់នាពេលកន្លងមក។ **រូបភាព៖ សហការី***





# របបរាជានិយម និងរដ្ឋាភិបាលកូនកាត់យោធានៅថៃកំពុងតែស្រអាប់ដោយសារតែកម្លាំងយុវជន

*អត្ថបទ៖ អរិយបុត្រ*

របបរាជានិយមដ៏មានអំណាច និងមានឥទ្ធិពល និងជារដ្ឋាភិបាលកូនកាត់យោធានៅក្នុងសង្គមថៃកំពុងតែស្រអាប់ ដោយសារតែការមិនពេញចិត្តរបស់យុវជន។

របបរាជានិយមនៅក្នុងប្រទេសថៃគឺគ្មាននរណាម្នាក់ហ៊ានប៉ះពាល់ឡើយ ហើយកន្លងមកអ្នកដែលហ៊ានភាគច្រើនត្រូវបានផ្តន្ទាទោសដោយច្បាប់ដ៏តឹងរ៉ឹងបំផុត លើកលែងតែអ្នកដែលគេចខ្លួនទៅនៅបរទេស ប៉ុន្តែនៅប៉ុន្មានខែចុងក្រោយនេះរស្មីនៃរបបរាជានិយមនៅក្នុងប្រទេសនេះកំពុងតែស្រអាប់ ខណៈដែលរាជរដ្ឋាភិបាលស៊ីវិលដែលឡើងកាន់អំណាចតាមការបោះឆ្នោត ប៉ុន្តែមានខ្នងបង្អែក និងសាវតាជាយាធាក្រោយធ្វើរដ្ឋប្រហាររដ្ឋាភិបាលស៊ីវិល ក៏កំពុងតែប្រឈមមុខនឹងរលកនៃការមិនពេញចិត្តនៅក្នុងប្រទេសពីសំណាក់ក្រុមបញ្ញវន្តជាយុវជនជំនាន់ក្រោយ។



*បាតុករជាច្រើននៅតែបន្តទាមទារ និងតវ៉ាប្រឆាំងឱ្យមានការផ្លាស់ប្តូទៅតាមការចង់បានរបស់ពួកគេដែលភាគច្រើនជាយុវជន។ **រូបភាព៖ បរទេស***

ក្រុមអ្នកតវ៉ាវ័យក្មេងរបស់ប្រទេសថៃកំពុងតែបន្តបោះជំហានទៅមុខ ទោះបីជាពួកគេត្រូវបានបំបែកជាបន្តបន្ទាប់ដោយអាជ្ញាធរក្រោយពេលដែលអនុវត្តច្បាប់គ្រាអាសន្នដែលប្រកាសដោយលោក ប្រាយុទ្ធ ចាន់អូ៊ចារ នាយករដ្ឋមន្ត្រីដែលជាអតីតប្រមុខកងទ័ពដែលធ្វើរដ្ឋប្រហារឡើងកាន់អំណាច ហើយបានបន្តដឹកនាំតាមការបោះឆ្នោតដែល ក្រុមយុវជនថៃបានហៅថា ជាការបោះឆ្នោតដែលមានសេណារីយ៉ូរៀបចំទុកដើម្បីរក្សាអំណាច។

បាតុករវ័យក្មេងរាប់ពាន់នាក់បានចេញកាលពីពាក់កណ្តាលខែតុលា ហើយជួបជុំគ្នានៅវិមានជ័យជំនះដែលជារង្វង់មូលធំមួយនៅភាគខាងជើងភាគកណ្តាលទីក្រុងបាងកកជាបន្តបន្ទាប់ ដោយផ្តើននឹងច្បាប់គ្រាអាសន្ន និងច្បាប់ដែលពាក់ព័ន្ធនឹងការប្រមាថស្ថាប័នរាជវាំង និងខ្សែរាជវង្ស។

យុវជននានា ដែលជាសមាជិកនៃក្រុមយុវជនសេរី ដែលជាក្រុមសកម្មជនមួយបានប្រើបណ្តាញសង្គមនាពេលថ្មីៗនេះដើម្បីអំពាវនាវឱ្យមានការធ្វើបាតុកម្មថ្មីនៅទូទាំងទីក្រុងបាងកកជាបន្តបន្ទាប់ ដោយទាមទារឱ្យលោកនាយករដ្ឋមន្ត្រី ប្រាយុទ្ធ ចាន់អូ៊ចារ និងគណៈរដ្ឋមន្ត្រីរបស់លោកផ្លាស់ប្តូររដ្ឋធម្មនុញ្ញដែលព្រាងដោយអ្នកតំណាងប្រជាជន និងធ្វើកំណែទម្រង់ រាជាធិបតេយ្យនៅក្រោមរដ្ឋធម្មនុញ្ញ។

ចលនាប្រឆាំងនឹងរបបយោធា និងការមិនពេញចិត្តនឹងរាជានិយមនៅក្នុងប្រទេសនៅពេលនេះគឺជារលកនៃការទាមទារថ្មីមួយ ដែលត្រូវបានគេដឹងថាផ្តួចផ្តើមឡើងដោយក្រុមយុវជននៃសាកលវិទ្យាល័យធម្មាសាធ ដែលជាសាកលវិទ្យាល័យមួយដែលធ្លាប់មានឈ្មោះបោះសម្លេងតាំងពីដើមរៀងមកទាក់ទងនឹងការប្រឆាំងនឹងរបបនយោបាយមួយដ៏សកម្មនៅក្នុងសង្គមថៃ ជាពិសេសគឺការធ្វើរដ្ឋប្រហារ ប៉ុន្តែនេះគឺជាលើកទីមួយ ដែលពួកយុវជនសម័យថ្មីនាពេលបច្ចុប្បន្ននេះហ៊ានប្រឆាំងនិងធ្វើការរិះគន់ ហើយទាមទាររហូតដល់ធ្វើកំណែទម្រង់របបរាជាធិបតេយ្យរបស់ប្រទេស។




*បាតុករលើកផ្លាកទាមទាររបស់ខ្លួនអំឡុងពេលធ្វើការតវ៉ាក្នុងទីក្រុងបាងកក។ **រូបភាព៖ បរទេស***



*លោក ប្រាយុទ្ធ ចាន់អូ៊ចារ នាយករដ្ឋមន្ត្រីដែលជាអតីតប្រមុខកងទ័ពដែលធ្វើរដ្ឋប្រហារឡើងកាន់អំណាច។ **រូបភាព៖ បរទេស***

ដំណើរការទាមទារ និងការសំដែងនូវការមិនពេញចិត្តរបស់ក្រុមយុវជនវ័យក្មេងនៅក្នុងសង្គមថៃនៅពេលនេះវាមិនអាចនឹងដល់គោលដៅបានយ៉ាងងាយស្រួលនោះទេ ហើយក៏មិនដឹងថា វានឹងជោគជ័យនៅពេលណាឱ្យប្រាកដនោះដែរ ប៉ុន្តែវាគឺជាវិញ្ញាសារមួយសម្រាប់អ្នកនយោបាយ និង អ្នកជំនាញសង្គមនៅក្នុងប្រទេសរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញមួយនេះត្រូវតែដោះស្រាយពីព្រោះសញ្ញានៃការបែកបាក់ និងប្រេះឆា គឺកំពុងតែកើតមាននៅក្នុងសង្គម។

ការជួបប្រជុំតវ៉ារបស់ក្រុមយុវជនដែលប្រឆាំងនេះកាលពីពាក់កណ្តាលខែតុលាមក គឺមានការគាំទ្រពីមហាជនមួយចំនួនធំ ប៉ុន្តែការប្រមូលផ្តុំនេះគឺប្រមូលបានហើយក៏បំបែកវិញ ហើយក៏នៅមិនទាន់បានជួបការបង្ក្រាបដ៏ចាស់ដៃណាមួយពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចនៅឡើយទេ គ្រាន់តែលោក ប្រាយុទ្ធ ចាន់អូ៊ចារ ប្រកាសដាក់ប្រទេសនៅក្នុងស្ថានភាពគ្រាអាសន្ន និងបានព្រមានអំពីការបែកបាក់សាមគ្គីនៅក្នុងសង្គមថៃ ហើយសមត្ថកិច្ចប៉ូលីសបានចាប់ខ្លួនមេដឹកនាំនិងសកម្មជនរបស់ពួកគេមួយចំនួនតែប៉ុណ្ណោះ។

លោក ប្រាយុទ្ធ បានគម្រាមថា សង្គមថៃនឹងអាចជួបប្រទះនូវទស្សនៈនៃការខ្វែងគំនិតគ្នាមួយដ៏អាក្រក់ និងនាំសង្គមឈានដល់គ្រោះថ្នាក់។

លោក ប្រាយុទ្ធ គឺជាមេទ័ព ដែលបានឡើងកាន់អំណាចកាលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ក្រោយពេលដែលលោកបានដឹកនាំធ្វើរដ្ឋប្រហារដ៏ល្បីរជាជនថៃដឹងថា គឺជារដ្ឋប្រហារទី១២ ដ៏លើធ្វើឡើងដោយយោធាតាំងពីរដ្ឋប្រហារដំបូងកាលពីឆ្នាំ១៩៣២ ហើយបានបន្តកាន់ដំណែងជានាយករដ្ឋមន្ត្រី តាមការបោះឆ្នោតមួយដែលកើតចេញពីការពន្យារពេលជាបន្តបន្ទាប់ ហើយមានការកែសម្រួលនូវរដ្ឋធម្មនុញ្ញ តាមរយៈការខិតខំថែរក្សាអំណាចយោធានៅពីក្រោយឆាកនយោបាយនៅក្នុងប្រទេស ជាហេតុដែលបណ្តាលឱ្យមានការមិនពេញចិត្តពីសំណាក់ក្រុមបញ្ញវន្តវ័យក្មេង ដោយឡែកស្ថាប័នរាជវាំងក៏ត្រូវរិះគន់ និងត្រូវបានពួកគេមើលឃើញនូវការកើនឡើងនូវអំណាច និងការខ្ជះខ្ជាយរបស់ស្ថាប័ននេះ។

គួររំលឹកដែរថា ក្រៅពីក្រុមយុវជនរៀបចំឱ្យមានការជួបជុំសម្តែងមតិប្រឆាំងនឹងអាជ្ញាធរ ហើយទាមទារឱ្យនាយករដ្ឋមន្ត្រីដែលមានសាវតាយោធាចេញពីតំណែង និងទាមទារកំណែទម្រង់រាជានិយមក៏ពិតមែន ប៉ុន្តែក៏មានមហាជនមួយក្រុមផ្សេងទៀតចេញមុខសំដែងគំនិត និងមតិប្រឆាំងនឹងក្រុមយុវជន។

ហេតុផលរបស់ក្រុមបាតុករនៅក្នុងក្រុមនេះ គឺអាចមានអង្គការចាត់តាំងនយោបាយមួយដែលបង្កើតឡើងដើម្បីវាយបកនឹងទស្សនៈនយោបាយរបស់ក្រុមយុវជន ហេតុដូច្នេះហើយបានជាគេមិនដឹងថា តើវាសនានៃការតវ៉ា និងសម្តែងមតិដែលផ្តួចផ្តើមដោយក្រុមយុវជននឹងមានវាសនាយ៉ាងណានោះទេ មកដល់ពេលនេះ៕

# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា និងចិនត្រូវបានចុះរួចរាល់

*អត្ថបទ៖ អរិយបុត្រ*

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងចិន ត្រូវបានចុះរួចរាល់កាលពីព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ នៅអំឡុងពេលនៃទស្សនៈកិច្ចរយៈពេលពីរថ្ងៃរបស់លោក វ៉ាង យី ទីប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងការបរទេសចិន។




កិច្ចព្រមព្រៀងនេះ ត្រូវបានចុះដោយលោក ប៉ាន់ សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និង លោក ហ្សុង សាន (Zhong Shan) រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មចិន ប៉ុន្តែរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មចិនមិនបានមកចុះហត្ថលេខានៅកម្ពុជាដោយផ្ទាល់នោះទេដោយធ្វើការចុះហត្ថលេខារួមគ្នាតាមរយៈប្រព័ន្ធវីដេអូនៅចំពោះមុខសម្តេចតេជោ ហ៊ុន សែន និងលោក វ៉ាង យី។

ទាក់ទិននឹងកិច្ចព្រមព្រៀងនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានមានប្រសាសន៍ថា ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅពេលនេះមានសារសំខាន់ខ្លាំងណាស់។

សម្តេចតេជោប្រមុខរាជរដ្ឋាភិបាលបានបញ្ជាក់ថា ៖ «អ៊ីប៊ីអេ (EBA)វាអាចបាត់បង់នៅពេលណាមួយក៏ប៉ុន្តែកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជានិងចិនគឺនៅជារៀងរហូត»។ នេះបើយោងតាមការឱ្យដឹងពីលោក អ៊ាង សុផល្លែត ជំនួយការផ្ទាល់របស់សម្តេចតេជោ ហ៊ុន សែន ថ្លែងប្រាប់អ្នកសារព័ត៌មាន ក្រោយពេលដែលសម្តេចបានទទួលជួបជាមួយនឹងលោក វ៉ាង យី។

នេះគឺជាលើកទី១ហើយដែលកម្ពុជាសម្រេចបានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយបរទេស។ រាជរដ្ឋាភិបាលកម្ពុជារំពឹងថា ក្រោយមានកិច្ចព្រមព្រៀងនេះការនាំចេញរបស់កម្ពុជាទៅចិននឹងមានការកើនឡើង២៥ភាគរយបន្ថែមទៀត។ ក្រៅពីចិន កម្ពុជាបានកំពុងតែធ្វើការជាមួយនឹងកូរ៉េខាងត្បូង លើកិច្ចព្រមព្រៀងដូចគ្នានេះ ដែលពេលនេះទាំងមន្ត្រីក្រសួងពាណិជ្ជកម្ម និង ស្ថានទូតកូរ៉េនៅកម្ពុជាសុទ្ធតែអះអាង អំពីវឌ្ឍនភាពនៃការចរចារ។

សូមបញ្ជាក់ជូនថាកម្ពុជា និងចិនបានបញ្ចប់ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីនឹងគ្នានេះ កាលពីក្នុងអំឡុងខែកក្កដាកន្លងទៅ បន្ទាប់ពីចំណាយពេលជិតមួយឆ្នាំដើម្បីជជែកពិភាក្សាគ្នា។ រាជរដ្ឋាភិបាលកម្ពុជារំពឹងថា ការនាំចេញពីកម្ពុជាទៅចិននឹងមានការកើនឡើងប្រមាណ ២៥ភាគរយបន្ទាប់ពីកិច្ចព្រមព្រៀងនេះចុះហត្ថលេខារួចរាល់។

ក្រសួងពាណិជ្ជកម្មកម្ពុជាបានអះអាងថា ទំនិញកម្ពុជាជាង ៣០០ មុខអាចនាំទៅចិនដោយមិនគិតពន្ធនៅពេលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជាចិនចូលជាធរមាន។ នៅក្នុងចំណោមមុខទំនិញជាង៣០០មុខនេះ គឺផលិតផលកសិកម្ម៩៥ភាគរយត្រូវរួចពន្ធសម្រាប់ការនាំចេញទៅចិន។

ក្រៅពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនេះ សម្តេចតេជោ ហ៊ុន សែន និងលោក វ៉ាង យី ក៏បានអញ្ជើញជាអធិបតីភាពក្នុងពិធីចុះកិច្ចព្រមព្រៀងមួយចំនួនទៀត ដែលរួមមាន កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសសម្រាប់ការផ្តល់ហិរញ្ញប្បទានឥតសំណងរបស់ចិនដល់កម្ពុជា, លិខិតប្តូរសារស្តីពីការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើឱ្យប្រសើរឡើងមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ និងលិខិតប្តូរសារស្តីពីការសិក្សាសមិទ្ធិលទ្ធភាពគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូ និងប្រព្រឹត្តកម្មទឹកកខ្វក់នៅខេត្តព្រះសីហនុ និងពិធីប្រគល់និងទទួលជំនួយបរិក្ខាវេជ្ជសាស្ត្រ៕

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ស្នើដល់តំណាងរោងចក្រ បង្កើនការផលិតសម្ភារៈ បរិក្ខារការពារ កូវីដ១៩

*អត្ថបទ៖ ផល សុផានិត*

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្នើដល់តំណាងរោងចក្រផលិតសម្ភារៈបរិក្ខារការពារជំងឺកូវីដ១៩ បង្កើនការផលិតសម្ភារៈឱ្យបានកាន់តែច្រើន សម្រាប់ផ្គត់ផ្គង់ ឱ្យគ្រប់តម្រូវការទីផ្សារ ខណៈដែលមេរោគនេះនៅតែគំរាមកំហែងពិភពលោកនៅឡើយ។

លោកទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានលើឡើងនៅក្នុងជំនួបពិភាក្សាការងារជាមួយលោក Clement Yang ប្រធានក្រុមហ៊ុនរោងចក្រ MEDTECS Cambodia ថា ក្រុមហ៊ុនរោងចក្រ MEDTECS ជាក្រុមហ៊ុនវិនិយោគទទួលបានជោគជ័យមួយនៅកម្ពុជា មានរយៈពេល២១ ឆ្នាំមកហើយ ក្នុងនោះ ក្រុមហ៊ុនក៏បានរួមចំណែកនៅក្នុងសេដ្ឋកិច្ច ទីផ្សារការងារ និងការទទួលខុសត្រូវនៅក្នុងសង្គមកម្ពុជាផងដែរ ជាក់ស្តែងការចូលរួមឧបត្ថម្ភសម្ភារៈបរិក្ខារការពារ Covid-១៩ គឺជាកាយវិការបង្ហាញនូវទឹកចិត្តដ៏ប្រពៃ ខណៈដែលកម្ពុជាកំពុងជួបប្រទះ។

ពាក់ព័ន្ធរោគរាតត្បាតនៃជំងឺកូវីដ១៩នេះ លោកទេសរដ្ឋមន្ត្រី ក៏បានស្នើដល់លោក Clement Yang ប្រធានក្រុមហ៊ុន MEDTECS បង្កើនការយកចិត្តទុកដាក់ និងជំរុញផលិតសម្ភារៈ បរិក្ខារការពារ កូវីដ១៩ឱ្យបានកាន់តែច្រើនថែមទៀតដូចជាម៉ាស់ និងសំលៀកបំពាក់ពេទ្យជាដើម សម្រាប់ផ្គត់ផ្គង់ឱ្យគ្រប់តម្រូវការទីផ្សារ ចំពោះបញ្ហាទាំងអស់នេះ គឺជាចូលរួមចំណែកដ៏សំខាន់ផងដែរ នៅក្នុងការបង្ការ និងទប់ស្កាត់នៃការរីករាលដាលជំងឺកូវីដ១៩ នេះ៕

# អតីតអ្នកការទូតកម្ពុជា ស្នើឱ្យរុស្ស៊ី ជួយជំរុញឱ្យមាន FTA រវាងកម្ពុជា និងសហព័ន្ធសេដ្ឋកិច្ច អឺរ៉ាស៊ី–អឺរ៉ុប

*អត្ថបទ៖ ផល សុផានិត*

លោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា កម្ពុជា និងរុស្ស៊ី គួរបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ឱ្យកាន់តែមានលក្ខណៈធំធេងថែមទៀតរួមទាំងពាណិជ្ជកម្មនិងការវិនិយោគ។

លោកក៏បានស្នើឱ្យរុស្ស៊ី ជួយជំរុញឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងសហព័ន្ធសេដ្ឋកិច្ចអឺរ៉ាស៊ី-អឺរ៉ុប ឱ្យកើតជារូបរាងផងដែរ។

ការស្នើរបស់លោក ហោ ណាំហុង បែបនេះ បានធ្វើឡើងក្នុងអំឡុងពេលលោកបានអនុញ្ញាតឱ្យលោក អាណាតូលី បូរ៉ូវីក (Anatoly BOROVIK) ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជាចូលជួបសម្តែងការគួរសម នៅទីស្តីការគណៈរដ្ឋមន្ត្រីនាព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២។

លោក ហោ ណាំហុង បានលើកឡើងថា សហព័ន្ធរុស្ស៊ី បានបង្កើតសហព័ន្ធសេដ្ឋកិច្ចអឺរ៉ាស៊ី -អឺរ៉ុប ហើយលោកស្នើឯកអគ្គរដ្ឋទូតរុស្ស៊ីឱ្យជួយធ្វើយ៉ាងណាជំរុញឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA)រវាងកម្ពុជានិងសហព័ន្ធនេះ ដើម្បីកម្ពុជាអាចនាំចេញផលិតផលកសិកម្មនិងឧស្សាហកម្ម ក៏ដូចជាពាណិជ្ជកម្ម ជាមួយសហព័ន្ធដែលមានប្រទេសសមាជិកនៅអាស៊ីចំនួន៤ និងសហព័ន្ធរុស្ស៊ី។

លោកឧបនាយករដ្ឋមន្ត្រី បានបន្ថែមថា នៅឆ្នាំ ២០២០ សហព័ន្ធរុស្ស៊ីជាប្រធានអង្គការកិច្ចសហប្រតិបត្តិការសៀងហៃ (SCO)ដែលមានប្រទេសសមាជិកនៅក្នុងតំបន់អាស៊ីចំនួន៧ និងសហព័ន្ធរុស្ស៊ី ហើយលោកបានស្នើរដ្ឋាភិបាលសហព័ន្ធរុស្ស៊ីជួយឱ្យកម្ពុជាបានក្លាយជាប្រទេសសង្កេតការណ៍និងជាសមាជិកទៅថ្ងៃអនាគត។

ឯកអគ្គរដ្ឋទូតរុស្ស៊ី បានសន្យាថា នឹងរាយការណ៍ទៅរដ្ឋាភិបាលទីក្រុងម៉ូស្គូ អំពីសំណើរបស់លោកហោ ណាំហុង ដែលសុំឱ្យរុស្ស៊ីជួយជំរុញឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជានិងសហព័ន្ធនេះ ហើយឯកអគ្គរដ្ឋទូតរូបនេះក៏បានសន្យាដែរថា នឹងរៀបចំឱ្យមានកិច្ចប្រជុំគណៈកម្មការអន្តររដ្ឋាភិបាលតាមប្រព័ន្ធអនឡាញដើម្បីជាការឆ្លើយតបនឹងសំណើរបស់លោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង។



*លោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងលោក អាណាតូលី បូរ៉ូវីក (Anatoly BOROVIK) ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជាចូលជួបសម្តែងការគួរសម។* ***រូបភាព៖ សហការី***

នៅឆ្នាំ២០២១ ខាងមុខនេះ គឺជាខួបអនុស្សាវរីយ៍លើកទី ៦៥ឆ្នាំ នៃទំនាក់ទំនងការទូតរវាងកម្ពុជា និងសហព័ន្ធរុស្ស៊ី លោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង បានបង្ហាញការយល់ឃើញថា គួររៀបចំខួបនេះឱ្យបានល្អស្របនិងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងប្រទេសទាំងពីរនេះ៕





# កម្ពុជាកំពុងពង្រឹងវិស័យកសិកម្ម ទៅជាកសិឧស្សាហកម្មក្នុង អន្តរកាលជំងឺកូវីដ១៩



*ជ័រកៅស៊ូដែលបានចៀរចេញពីដើមក្នុងចម្ការ។* ***រូបភាព៖ សហការី***

*អត្ថបទ៖ ផល សុផានិត*

វិស័យកសិកម្មនៅតែជាវិស័យនាំមុខមួយ ក្នុងចំណោមវិស័យជាច្រើនដទៃទៀត ដែលបាននឹងកំពុងរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ កំណើនផលទុនជាតិ និងចំណូលផលពីវិស័យកសិកម្ម។

វិស័យនេះក៏បានផ្តល់ការងារ និងផលចំណូលចូលដល់ប្រទេសជាតិ កសិករនៅតាមទីជនបទផងដែរ ជាមួយគ្នានេះ រាជរដ្ឋាភិបាល ក៏បានរៀបចំផែនការយុទ្ធសាស្ត្រ អភិវឌ្ឍដំណាំកៅស៊ូធម្មជាតិ ឆ្ពោះទៅកាន់ឆ្នាំ២០៣០ ដែលមានគោលដៅ បង្កើនផ្ទៃដីដាំដុះកៅស៊ូ បង្កើនផលិតកម្មកៅស៊ូ និងបង្កើនការនាំចេញ។

ក្រុមហ៊ុនឯកជនជាច្រើនកំពុងតែវិនិយោគលើវិស័យកសិកម្មនេះ កំពុងតយែកចិត្តទុកដាក់លើវិស័យកសិឧស្សាហកម្មជាពិសេស ដំណាំកៅស៊ូ ឱ្យកាន់តែច្រើនថែមទៀត។ ក្រុមហ៊ុនទាំងនោះមានទស្សនៈថា ការជ្រើសរើសយកដំណាំកៅស៊ូនេះក៏ព្រោះតែកៅស៊ូជាដំណាំយុទ្ធសាស្ត្រដ៏សំខាន់នៅក្នុងវិស័យកសិកម្ម។

ក្រៅពីមានបំណងលើកស្ទួយវិស័យកសិឧស្សាហកម្ម នៅក្នុងប្រទេសកម្ពុជា ក្រុមហ៊ុនវិនិយោគទាំងនោះ ក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចការសង្គម តាមរយៈការផ្តល់ការងារដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ ឬក៏តំបន់ផ្សេងទៀត ឱ្យទទួលបានប្រាក់ខែសមរម្យ និងការរស់នៅងាយស្រួល។

លោក ហេង សារុំ នាយករងមណ្ឌលព្រះវិហារ បានបញ្ជាក់អោយដឹងថា ៖«រាល់ថ្ងៃនេះបើយើងសរុបពីខេត្តពោធិ៍សាត់ និងព្រះវិហារនេះ កំលាំងដែលគិតលើអាជីវកម្មជៀជ័រកៅស៊ូននេះ ប្រហែលជា១៣០០នាក់ នេះយើងមិនបូកពីកំលាំងពលកម្មដែលធ្វើការលើផ្នែកផ្សេងៗទៀត ដែលសរុបលើផ្ទៃដី៣០០០ហិចតា។ ក្នុងនោះ កំលាំងពលកម្ម មានម៉ៅការ កំលាំងកិច្ចព្រមព្រៀង។ ក្នុងរយៈពេលចុងក្រោយនេះ ប្រទេសលើពិភពលោក ជួបប្រទះនឹងវិបត្តិសេដ្ឋកិច្ច ឬក៏មានក្សូ័ណា មានន័យថា ក្រុមហ៊ុនមួយចំនួនកាត់បន្ថយបុគ្គលិក ឬក៏បន្ថយប្រាក់បៀវត្សបុគ្គលិក តែសម្រាប់កៅស៊ូ គឺមានតែរើសបុគ្គលិកបន្ថែម»។

ការស្នាក់នៅរបស់កម្មករ ក្រុមហ៊ុនដែលវិនិយោគលើចម្ការកៅស៊ូ ក្នុងប្រទេសកម្ពុជា បានធ្វើការសាងសង់ផ្ទះស្នាក់នៅ មានបន្ទប់ទឹក ក៏ដូចជាសេសសល់ដីសម្រាប់កម្មករដាំដំណាំរួមផ្សំសម្រាប់ទ្រទ្រង់ជីវភាព។ ក្រៅពីនេះ ក្រុមហ៊ុនទាំងនោះក៏បានតភ្ជាប់បណ្តាញអគ្គិសនី រៀបចំទឹក ប្រព័ន្ធអគ្គិសនី ផ្តល់ដល់កម្មករមិនគិតថ្លៃ បូកបន្ថែមលើប្រាក់រួមផ្សំ ដែលទាំងនេះក៏មិនចាញ់នឹងការធ្វើការងារនៅក្រៅប្រទេសឡើយ លើផ្នែកកសិឧស្សាហកម្ម។

ក្នុងអន្តរកាលនៃវិបត្តិជំងឺសកល ឬ កូវីដ១៩នេះ ខណៈដែលបណ្តាក្រុមហ៊ុនមួយចំនួន បានកាត់បន្ថយបុគ្គលិក ក្រុមហ៊ុនឯកជនដែលវិនិយោគទាំងនោះ មិនបានកាត់បន្ថយអ្វីទាំងអស់។

លោក ជុំ សៅ ជាកម្មករជៀជ័រកៅស៊ូ បានបញ្ជាក់ថា ៖«ក្រុមហ៊ុនកៅស៊ូរបស់យើង មិនបានរំសាយកម្មករនោះទេ ក្រុមហ៊ុនក្តោបកម្មករ ដើម្បីទប់ស្កាត់ជំងឺនេះ។ ប្រាក់ខែរបស់ខ្ញុំជាង២០០ដុល្លាអាមេរិក ក្នុងមួយខែ ក្នុងនោះរូបខ្ញុំក៏បានស្នាក់នៅ ដោយក្រុមហ៊ុនផ្តល់ផ្ទះស្នាក់នៅ»។

ចំណែកកម្មការិនី មួយរូបទៀត អ្នកស្រី ខាត់ សំអឿន បានឱ្យដឹងថា ៖«ខ្ញុំឡើងជៀជ័រកៅស៊ូ តាំងពីម៉ោង៣ទៀបភ្លឺ និងការងារកាប់ព្រៃមួយចំនួន។ អ្នកមានផ្ទៃពោះ មានប្រាក់បៀវត្សជាប្រចាំខែ នៅពេលឈឺ ឬមានគ្រោះថ្នាក់ មានឡានក្រុមហ៊ុនដឹកទៅកាន់មន្ទីរពេទ្យត្រឹមត្រូវ»។

ទន្ទឹមនឹងការដាំកៅស៊ូ និងការប្រមូលផលកៅស៊ូ ក្រុមហ៊ុនជាច្រើនក្នុងប្រទេសក៏បានបោះទុនបន្ថែម ក្នុងការបង្កើតរោងចក្រកែច្នៃកៅស៊ូ ក្នុងខេត្តព្រះវិហារ។ រោងចក្របានបើកដំណើរការតាំងពីឆ្នាំ ២០១៩ ហើយបច្ចុប្បន្នក៏កំពុងដំណើរការយ៉ាងសកម្ម។ រោងចក្រកែច្នៃជ័រកៅស៊ូនេះ មានសមត្ថភាពកែច្នៃជ័រកៅស៊ូក្រែប ប្រមាណជា៣តោនក្នុងមួយម៉ោង ដែលអាចចាត់ទុកថាជារោងចក្រមួយក្នុងប្រទេសកម្ពុជា ដែលបានរួមចំណែកជំរុញវិស័យឧស្សាហកម្ម។

ក្រៅពីការប្រើប្រាស់ជ័រកៅស៊ូផ្ទាល់ ក្រុមហ៊ុនក៏បានប្រមូលទិញជ័រកៅស៊ូពីប្រជាពលរដ្ឋ ដែលធ្វើការដាំដុះជាលក្ខណៈគ្រួសារ នៅទូទាំងប្រទេសកម្ពុជាផងដែរ។

យោងតាមទិន្នន័យពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រទេសកម្ពុជា បាននាំចេញ កៅស៊ូស្ងួតចំនួន ១៧៩.៦២១ តោនក្នុងរយៈពេល ៩ ខែដំបូងនៃឆ្នាំ ២០២០ ដែលធ្លាក់ចុះ ៣ ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ កៅស៊ូស្ងួតមួយតោនជាមធ្យមមានតម្លៃ ១,២៨៨ ដុល្លារ ក្នុងរយៈពេលនេះគឺទាបជាងកៅស៊ូនៅឆមាសទី១ ឆ្នាំ២០១៩ ប្រហែល ៥១ដុល្លារ៕

# បណ្តារដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន នឹងរួមគ្នា ដោះស្រាយដើម្បីកាត់បន្ថយការធ្លាក់ចុះនៃសេដ្ឋកិច្ច

*អត្ថបទ៖ ផល សុផានិត*

បណ្តារដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាននឹងរួមគ្នាដោះស្រាយនូវបញ្ហាប្រឈម ការកាត់បន្ថយនូវហានិភ័យ ជាពិសេសផលប៉ះពាល់អវិជ្ជមានដែលបង្កឡើងដោយជំងឺកូវីដ១៩ មកលើសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកអាស៊ាន សំដៅកាត់បន្ថយការធ្លាក់ចុះ និងស្តារឡើងវិញនូវកំណើនសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន នៅក្នុងអំឡុងពេល និងក្រោយវិបត្តិជំងឺកូវីដ១៩។

រដ្ឋលេខាធិការប្រចាំការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោក វង្សី វិស្សុត បានដឹកនាំគណៈប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន លើទី២៤ (២៤th AFMM), កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី ៦ (៦th AFMGM) និងកិច្ចប្រជុំពាក់ព័ន្ធ តាមប្រព័ន្ធ Video Conference កាលពីដើមខែតុលា ឆ្នាំ២០២។

បណ្តារដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន បានធ្វើការកត់សម្គាល់លើការធ្វើបទបង្ហាញរបស់បណ្តាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ស្តីពីការវិវត្តនៃស្ថានភាព និងទស្សនៈវិស័យសេដ្ឋកិច្ចពិភពលោក និងតំបន់ នៅក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ១៩, ក្នុងនោះ បណ្តារដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន បានពិភាក្សា និងផ្លាស់ប្តូរយោបល់លើការដាក់ចេញនូវវិធានការ និងគោលនយោបាយនានា សំដៅដោះស្រាយនូវបញ្ហាប្រឈម ក៏ដូចជា កាត់បន្ថយនូវហានិភ័យទាំងនោះ ជាពិសេស ផលប៉ះពាល់អវិជ្ជមានដែលបង្កឡើងដោយជំងឺកូវីដ១៩ មកលើសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកអាស៊ាន សំដៅកាត់បន្ថយការធ្លាក់ចុះ និងស្តារឡើងវិញនូវកំណើនសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន នៅក្នុងអំឡុងពេល និងក្រោយវិបត្តិជំងឺកូវីដ១។

ជុំវិញបញ្ហានេះ រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន បានធ្វើការកត់សម្គាល់ និងវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពដែលសម្រេចបានចាប់តាំងពីកិច្ចប្រជុំលើកទី២៣ ក្រោមកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុរួមមាន មូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ាន កិច្ចសហប្រតិបត្តិការធានារ៉ាប់រង ការអភិវឌ្ឍទីផ្សារមូលបត្រ កិច្ចសហប្រតិបត្តិការគយ និងពន្ធដារ រួមទាំងកិច្ចការពាក់ព័ន្ធនឹងសមាហរណកម្មហិរញ្ញវត្ថុនិង រូបិយវត្ថុអាស៊ានមួយចំនួនទៀត។

ពាក់ព័ន្ធការខ្វះខាតនូវហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជា ការស្តាសេដ្ឋកិច្ចពីវិបត្តិកូវីដ កិច្ចប្រជុំបានស្វាគមន៍លើការបញ្ចប់របាយការណ៍ ស្តីពីការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាពក្នុងតំបន់អាស៊ាន ដែលរបាយការណ៍នេះ គឺជាផែនទីបង្ហាញផ្លូវដ៏សំខាន់សម្រាប់អាស៊ាន ដើម្បីការបង្កើនសមត្ថភាពផ្តល់ហិរញ្ញប្បទាន តាមរយៈការពង្រឹងសមត្ថភាពក្នុងការអភិវឌ្ឍសញ្ញាប័ណ្ណរដ្ឋាភិបាល និងបានបញ្ជាក់អំពីការប្តេជ្ញាក្នុងការរឹតបន្តឹងកិច្ចសហប្រតិបត្តិការបន្ថែម ដោយឈរលើគោលជំហរជួយគ្នាទៅវិញទៅមក ក្នុងការជំរុញការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាពនេះ។

ក្នុងកិច្ចប្រជុំនេះដែរ លោក វង្សី វិស្សុត បានលើកឡើងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ចេញនូវយុទ្ធសាស្ត្រ និងគោលនយោបាយនានា សំដៅធានានូវស្ថេរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផ្តល់បរិយាកាសវិនិយោគល្អប្រសើរ ដើម្បីលើកស្ទួយការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្នរបស់កម្ពុជា ជាពិសេសការដាក់ចេញនូវវិធានការទាំង៦ជុំរបស់រដ្ឋាភិបាល សំដៅជួយរក្សាលំនឹងផលិតកម្ម និងអាជីវកម្ម ចំពោះវិស័យដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជំងឺកូវីដ១៩ និងជួយរក្សាលំនឹងជីវភាពប្រជាជនក្នុងកម្រិតអប្បបរមាមួយ (មិនឱ្យអត់បាយ) ពិសេសសម្រាប់ប្រជាជនក្រីក្រ និងក្រុមជនងាយរងគ្រោះ ព្រមទាំងអ្នកបាត់បង់ការងារ ដើម្បីធ្វើឱ្យពួកគេអាចមានលទ្ធភាពវិលទៅរកជីវភាពជាធម្មតាវិញនៅពេលផុតពីជំងឺនេះ ក៏ដូចជាការស្តារនិងជំរុញកំណើនសេដ្ឋកិច្ច នៅពេលជំងឺកូវីដ១៩ មានការថមថយ និងផុតរលត់៕

## ផ្លូវរត់នៅអាកាសយានដ្ឋាន អន្តរជាតិកងកេង អាចទទួលការ ចុះចតយន្តហោះ ប្រភេទធំបាន

*អត្ថបទ៖ ផល សុផានិត*

អាកាសយានដ្ឋានអន្តរជាតិកងកេងខេត្តព្រះសីហនុ បានពង្រីកផ្លូវរត់យន្តហោះ (Runway) ពី ២.៥០០ម៉ែត្រ រហូតដល់ ៣.៣០០ម៉ែត្រ បន្ថែមពីលើការពង្រឹងផ្លូវយន្តហោះឡើងចុះ (airstrip) បច្ចុប្បន្ន។

ផ្លូវរត់យន្តហោះថ្មីនេះ មានសមត្ថភាពទទួលការចុះចតយន្តហោះប្រភេទធំៗបានដូចជា B-៧៧៧-៣០០ER ឬយន្តហោះ A-៣៥០-១០០០ ដែលធ្វើប្រតិបត្តិការហោះហើរត្រង់រយៈចម្ងាយឆ្ងាយទៅមកពីអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ និងអាកាសយានដ្ឋានអន្តរជាតិក្នុងពិភពលោក។

ថ្លែងក្នុងពិធីសូត្រមន្តបញ្ចប់ការងារពង្រីក និងជួសជុលផ្លូវរត់ នាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ លោក ម៉ៅ ហាវណ្ណាល់ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល បានមានប្រសាសន៍ថា រយៈពេល ៥ឆ្នាំ ចុងក្រោយនេះ ខេត្តព្រះសីហនុ បានក្លាយជាទិសដៅគួរឱ្យទាក់ទាញ តាមរយៈ កំពង់ផែសមុទ្រទឹកជ្រៅ ដែលស្ថិតនៅក្រោមដំណើរការអភិវឌ្ឍន៍ និងឆ្នេរសមុទ្រធម្មជាតិយ៉ាងស្រស់ស្អាត ដែលបានទាក់ទាញវិនិយោគិនធុរៈកិច្ច និងភ្ញៀវទេសចរជាតិ អន្តរជាតិជាច្រើនផងដែរ។

លោកបានបន្តថា ដើម្បីប្រើប្រាស់សក្តានុពលដ៏សំបូរបែបរបស់ខេត្តព្រះសីហនុ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់អាទិភាពទៅលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍បណ្តាញតភ្ជាប់ផ្លូវអាកាស និងដើម្បីឆ្លើយតបនឹងតំរូវការជាក់ស្តែងផងដែរ។

លោកបានបន្តថា ដើម្បីទ្រទ្រង់ការអភិវឌ្ឍន៍ក្រុងព្រះសីហនុ ប្រព័ន្ធអាកាសយានដ្ឋានប្រកបដោយប្រសិទ្ធភាព និងការបង្កើនការតភ្ជាប់អាកាស គឺសំខាន់ណាស់ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពផ្លូវរត់ ផ្តល់នូវឱកាសកំណើនថ្មី ដោយក្រុមហ៊ុនអាកាសចរណ៍ អាចប្រតិបត្តិការយន្តហោះធំជាងមុន ហោះហើរទៅទីផ្សារឆ្ងាយដូចជាអឺរ៉ុប ជាដើម។ល៕

# ប្រជាពលរដ្ឋចំនួន២៥នាក់បាត់បង់ជីវិត រងគ្រោះនិងខូចខាតគេហដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចការអន្តរាគមន៍

*អត្ថបទ៖ អមរិន្ទ្រដានុត*

យោងតាមរបាយការណ៍ចុងក្រោយរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានឱ្យដឹងថា គ្រោះទឹកជំនន់នាពេលកន្លងមកនេះបានធ្វើឱ្យប្រជាពលរដ្ឋស្លាប់ចំនួន២៥នាក់ក្នុងនោះមានក្មេងចំនួន៧នាក់ នៅក្នុងខេត្តចំនួន៥ ខេត្តបន្ទាយមានជ័យដែលមានអ្នកស្លាប់ច្រើនជាងគេរហូតដល់១៥នាក់ និង១០នាក់ទៀត រស់នៅក្នុងខេត្តព្រះសីហនុ ពោធិ៍សាត់ ប៉ៃលិន និងខេត្តកំពង់ធំ។

រាជធានីនិងខេត្តទាំង១៩ដែលរងផលប៉ះពាល់ដោយសារជំនន់ទឹកភ្លៀងក្នុងឆ្នាំនេះ រួមមានភ្នំពេញ ពោធិ៍សាត់ ប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង ស្វាយរៀង ឧត្តមានជ័យ សៀមរាប តាកែវ កំពង់ស្ពឺ មណ្ឌលគិរី ព្រះសីហនុ កោះកុង ព្រះវិហារ ស្ទឹងត្រែង កំពង់ចាម កណ្ដាល កំពង់ធំនិងខេត្តកំពង់ឆ្នាំង


*ទឹកជំនន់ជន់លិចភាគខាងត្បូងរាជធានីភ្នំពេញដែលបណ្ដាលឱ្យមានការជម្លៀសប្រជាជនចេញពីលំនៅដ្ឋានជាបន្ទាន់។* ***ហ្វេសប៊ុកនាយករដ្ឋមន្ត្រី***

## មូលហេតុដែលធ្វើឱ្យមានទឹកជំនន់

សម្ដេចនាយករដ្ឋមន្ត្រីបានប្រកាសនៅចំពោះមុខប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់ក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញថា ទឹកជំនន់នេះមិនមែនដោយសារការលុបបឹងទេ តែជាគ្រោះធម្មជាតិ។

ការលើកឡើងនេះ ក្នុងអំឡុងពេលដែលសម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែនបានចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់ និងកំពុងស្នាក់នៅក្នុងបុរីពិភពថ្មីកូវស្រូវ២ជាបណ្ដោះអាសន្នរង់ចាំទឹកស្រកវិញ។

សម្ដេចតេជោបានមានប្រសាសន៍ថា ៖ «ខ្លះលើកឡើងអំពីបញ្ហាលុបបឹងបានជាវាមានជំនន់ ប៉ុន្តែខ្ញុំចង់សួរត្រលប់ទៅអ្នកដែលនិយាយហ្នឹងវិញថា នៅប្រទេសជប៉ុនឆ្នាំទៅ ជំនន់ទឹកភ្លៀងសម្លាប់ប្រជាជនជប៉ុនអស់យ៉ាងច្រើន។ នៅប្រទេសនៅអឺរ៉ុបទីក្រុងធំៗមួយចំនួនទឹកភ្លៀងក៏បានធ្វើឱ្យលិចលង់ ហើយអឺឡូវតាមព្រែកធ្លោតពីខាងលើមក តើអ្នកណាលុបបឹង?»

សម្ដេចបានបញ្ជាក់ទៀតថា ព្រែក ស្ទឹងពោធិ៍សាត់ ស្ទឹងមង្គលបុរី ស្ទឹងសង្កែ ដែលសុទ្ធសឹងជាស្ទឹង ប៉ុន្តែដោយសារតែទឹកពីលើខ្លាំងជ្រុលហួស ហួសពីសមត្ថភាពស្រូប មិនមែនហួសពីសមត្ថភាពស្រូបនៃលូឬប្រឡាយដែលបានធ្វើទេ សូម្បីតែទន្លេមេគង្គដែលជន់លិច ក៏សមត្ថភាពទន្លេមិនអាចទទួលអស់ជាមួយនឹងទឹកដែលធ្លាក់ពីខាងលើច្រើនហួសដែរ។

សម្ដេចតេជោនាយករដ្ឋមន្ត្រីក៏បានបន្តថា គ្រោះមហន្តរាយធម្មជាតិកើតមានឡើងនៅស្ទើរគ្រប់ប្រទេសក្នុងពិភពលោក។

លោកបានថ្លែងថា ៖ «ដូច្នេះរឿងនេះ ខ្ញុំមិនទាន់ចង់ឆ្លើយតបជាមួយអ្នកណាទេ ក៏ប៉ុន្តែខ្ញុំចង់ពន្យល់ទៅដល់ប្រជាពលរដ្ឋរបស់យើង ដោយសារតែទឹកភ្លៀងពីខាងលើ បើអស់ទឹកភ្លៀងពីលើ ទឹកខាងក្រោមក៏អស់ដែរ ហើយអាចអស់រកទឹកប្រើមិនបានទៀតផង។ ខ្ញុំសូមអំពាវនាវឱ្យប្រជាពលរដ្ឋរបស់យើងប្រុងប្រយ័ត្នគ្រប់ពេលវេលា»។

នៅក្នុងពេលនោះដែរ សម្ដេចតេជោក៏បានបញ្ជាឱ្យអាជ្ញាធរ និងកងកម្លាំងទាំងអស់ ក្នុងរាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តបន្ទាយមានជ័យត្រូវបន្តយកចិត្តទុកដាក់តាមដាននៃដំណើរវិវត្តនៃចរន្តទឹកដែលហូរចូល។ សម្ដេចក៏បានប្រកាសផងដែរថា ៖ «ការខូចខាតមិនទាន់ដឹងនៅឡើយទេ ប៉ុន្តែភារកិច្ចដែលជាអាទិភាពរបស់រាជរដ្ឋាភិបាលនៅពេលនេះគឺជួយសង្គ្រោះប្រជាពលរដ្ឋ នៅគ្រប់ខេត្តគ្រប់តំបន់ដែលរងគ្រោះដោយសារទឹកជំនន់។ យើងត្រូវត្រៀមបម្រុងគ្រប់ខេត្តទាំងអស់ ដើម្បីរំដោះប្រជាពលរដ្ឋចេញពីតំបន់រងគ្រោះ ខណៈប៉ុន្មានថ្ងៃទៀតនឹងជួបព្យុះ និងមិនត្រូវមើលងាយស្ថានការណ៍ពាក់ព័ន្ធស្ថានភាពទឹកជំនន់នេះឡើយ»។

សម្ដេចនាយករដ្ឋមន្ត្រីក៏បានអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់ត្រូវការពារពីជំងឺផ្សេងៗដោយខ្លួនឯងដោយទទួលទានទឹកស្អាត ឆ្អិន កុំទទួលទានទឹកឆៅដែលនាំឱ្យមានការរាគរូស ក្អួត ហើយកន្លែងនីមួយៗដែលមានពលរដ្ឋ ត្រូវមានគ្រូពេទ្យប្រចាំការដើម្បីមើល និងសង្គ្រោះ។ ត្រូវដាក់គ្រូពេទ្យប្រចាំការដើម្បីការពារគ្រោះថ្នាក់ជាយថាហេតុដល់ពលរដ្ឋ។

សម្រាប់គ្រួសារដែលមានសមាជិកបានស្លាប់ដោយសារទឹកជំនន់ សម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែនបានផ្ដល់ថវិកាក្នុងមួយសពចំនួន១០លានរៀល។

លោក គន់ គីម អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានមានប្រសាសន៍ប្រាប់ប្រជាពលរដ្ឋដែលរងការជន់លិចទាំងអ្នកជម្លៀសមកទីទួលសុវត្ថិភាព និងនៅតាមខ្ទង់ផ្ទះថា សម្ដេចតេជោបានតាមដានជាប់ជានិច្ចចំពោះការលំបាករបស់ប្រជាពលរដ្ឋកើតពីជំនន់ទឹកភ្លៀងនេះ។

លោកបានថ្លែងថា ៖ «សម្ដេចតេជោ ហ៊ុន សែន និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត លោកនឹករលឹកដល់បងប្អូនជាប់ជានិច្ច ហើយលោកបានផ្ដាំផ្ញើ និងណែនាំដាច់ណាត់ឱ្យពួកយើងខ្ញុំនេះ យកចិត្តទុកដាក់ចំពោះបងប្អូនធ្វើយ៉ាងណាមិនឱ្យបងប្អូនរងគ្រោះថ្នាក់ដល់អាយុជីវិតពីទឹកជំនន់នេះ»។

## ការផ្ដល់ជំនួយឧបត្ថម្ភពីសប្បុរជនក្នុងស្រុក និងស្ថានទូតនានា

នៅពេលដែលមានគ្រោះភ័យ អាសន្ន ដែលកើតឡើងដូចជាគ្រោះថ្នាក់អ្វីមួយ ជាពិសេសគ្រោះថ្នាក់ដោយគ្រោះធម្មជាតិ តែងតែមានសប្បុរជនជាច្រើន ដោយក្នុងនោះមានចាប់ពីព្រះមហាក្សត្រ ឧញ៉ា មន្ត្រីមានឋានៈខ្ពស់ និងអ្នកមានក្នុងប្រទេសបានជួយផ្ដល់នូវអំណោយជាថវិកា ឬរបស់របរប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគទៅដល់រាជរដ្ឋាភិបាលសម្រាប់ផ្ដល់ជូនជនរងគ្រោះ។ ជាមួយគ្នានេះដែរ កាកបាទក្រហមកម្ពុជាក៏បានចុះជួយដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់នេះផងដែរ។

សម្រាប់គ្រោះធម្មជាតិនៅក្នុងកាលៈទេសៈនេះ រាជរដ្ឋាភិបាលបានទទួលថវិកាចំនួនជាង១លានដុល្លារពីសប្បុរជននានាជាច្រើនដែលក្នុងនោះភាគច្រើនជាឧញ៉ា។

តាមរបាយការណ៍របស់លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ បានឱ្យដឹងថា សម្រាប់ប្រជាពលរដ្ឋនៅក្នុងខណ្ឌដង្កោនេះ មានភូមិចំនួន៤២ និងសង្កាត់ចំនួន១១ ដោយមានផ្ទះចំនួន៤,៩៦៥ខ្នងជន់លិច និងពលរដ្ឋចំនួន៥,៥៨៧គ្រួសារ (ស្មើនឹង២៣,៥២០នាក់) រងគ្រោះដោយសារទឹកជំនន់នេះ។

សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន បានថ្លែងអំណរគុណដល់បណ្ដាសប្បុរសជនទាំងឡាយដែលបានចូលរួមសប្បុរសធម៌ជាមួយនឹងរាជរដ្ឋាភិបាលក៏ដូចជាកាកបាទក្រហមកម្ពុជាកន្លងមកក្នុងការជួយបងប្អូនប្រជាពលរដ្ឋដែលកំពុងរងគ្រោះដោយគ្រោះទឹកជំនន់នាពេលនេះ។

នៅក្នុងឱកាសនោះផងដែរសម្ដេចកិត្តិព្រឹទ្ធបណ្ឌិតក៏បានអំពាវនាវឱ្យបងប្អូនប្រជាពលរដ្ឋត្រូវតែបន្តការយកចិត្តទុកដាក់ថែរក្សាសុខភាព ជាពិសេសរួមគ្នាទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ដែលប្រទេសយើងមិនទាន់រួចផុតនៅឡើយ និងការពារសុវត្ថិភាពផ្ទាល់ខ្លួនក្នុងអំឡុងពេលដែលមានទឹកជំនន់នេះជាពិសេសកូនតូចៗ ជនចាស់ជរា ត្រូវថែរក្សាសុខភាពតាមរយៈការហូបស្អាត ផឹកស្អាតការរស់នៅមានអនាម័យជាពិសេសពេលដែលទឹកស្រកទៅនោះ។

ថវិកាជាអំណោយរបស់សម្ដេចតេជោហ៊ុន សែន និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ក្នុងមួយសព ១០លានរៀល ត្រូវបានប្រគល់ជូនក្រុមគ្រួសារ សាច់ញាតិសពពលរដ្ឋរងគ្រោះដោយទឹកជំនន់។

«រដ្ឋាភិបាលជប៉ុនផ្ដល់ជំនួយសង្គ្រោះបន្ទាន់ដើម្បីឆ្លើយតបនឹងគ្រោះមហន្តរាយទឹកជំនន់នៅកម្ពុជា»

ប្រទេសជប៉ុនតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានសម្រេចផ្ដល់ជំនួយសង្គ្រោះបន្ទាន់ ដល់ប្រជាជនរងគ្រោះដោយសារទឹកជំនន់នៅកម្ពុជាតាមសំណើររបស់រាជរដ្ឋាភិបាលកម្ពុជាដូចខាងក្រោម ។

ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា ក៏បានផ្ដល់នូវជំនួយជាច្រើនផងដែរដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជួយដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់។ ក្នុងនោះមានតង់ចំនួន២០០តង់ ឧបករណ៍ចម្រោះទឹកចំនួន២០ ភួយចំនួន៧៨០ ម៉ាស៊ីនភ្លើងចំនួន៥ កម្រាលផ្លាស្ទិកចំនួន៧០ កម្រាលគេងចំនួន៧៨០ និងធុងទឹកចំនួន២០។ ស្ថានទូតជប៉ុនក៏បានបួងសួងឱ្យប្រជាជនរងគ្រោះមានសុវត្ថិភាព និងឆាប់រួចផុតពីគ្រោះមហន្តរាយនេះ។

ជាមួយគ្នានេះដែរ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ក៏បានផ្ដល់ថវិកា១០ម៉ឺនដុល្លារដល់កម្ពុជាជួយគ្រោះទឹកជំនន់នេះផងដែរ។


*សម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែនបានចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់។* ***ហ្វេសប៊ុកនាយករដ្ឋមន្ត្រី***


*អភិបាលខេត្តកំពង់ធំ នាំយកអំណោយសម្ដេចតេជោ ចែកជូនប្រជាពលរដ្ឋរស់នៅតំបន់ដាច់ស្រយាល ដែលរងគ្រោះដោយទឹកជំនន់។* ***សហការី***

ចាប់តាំងពីឆ្នាំ ២០១៨ ការគាំទ្ររបស់ទីភ្នាក់ងារ USAID បានជួយឱ្យកម្មវិធីស្បៀងអាហារពិភពលោកចាប់ផ្ដើមដំណើរការកម្មវិធីគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយដ៏ទូលំទូលាយជាលើកដំបូង នៅកម្ពុជាដើម្បីពង្រឹងការត្រៀម និងឆ្លើយតបគ្រោះមហន្តរាយ ជួយសង្គ្រោះអាយុជីវិត និងកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចសង្គម។

ទីភ្នាក់ងារ USAID បានផ្ដល់ថវិកាជាង៧លានដុល្លារក្នុងការឆ្លើយតបការត្រៀមរៀបចំ និងជំនួយកាត់បន្ថយគ្រោះមហន្តរាយនៅកម្ពុជាចាប់តាំងពីឆ្នាំ ២០០០។ តាមរយៈការដាក់ដំណើរការថ្មីៗនេះពី «ដៃគូមេគង្គ-សហរដ្ឋអាមេរិក» សហរដ្ឋអាមេរិកកំពុងពង្រឹងការត្រៀមបង្ការនិងការឆ្លើយតបនឹងគ្រោះមហន្តរាយក្នុងតំបន់ តាមរយៈប្រទេសទាំង៥នៃទន្លេមេគង្គក្រោមរួមទាំងប្រទេសកម្ពុជាផងដែរ។

ស្ថានទូតរុស្ស៊ីប្រចាំនៅកម្ពុជាក៏បានឧបត្ថម្ភអង្ករ ២តោន ទឹកសុទ្ធ ២១យួរ និងមីចំនួន៧៥កេស ជូនកាកបាទក្រហមកម្ពុជា សម្រាប់ជួយដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់។

អំណោយខាងលើនេះ គឺជាសក្ខីភាពនៃទឹកចិត្តជ្រះថ្លារបស់បុគ្គលិកនៃស្ថានទូតរុស្ស៊ី និងប្រជាជនរុស្ស៊ី ហើយដែលរឹតតែបង្ហាញអំពីចំណងមិត្តភាពសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដ៏រឹងមាំរវាងប្រទេសនិងប្រជាជនកម្ពុជា-រុស្ស៊ី ជាពិសេសស្មារតីនៃការចែករំលែក ជួយគ្នាក្នុងគ្រាមានអាសន្ន។

## ការត្រៀមថវិកាក្នុងការស្ដារឡើងវិញ

រាជរដ្ឋាភិបាលកម្ពុជាបានត្រៀមថវិកាចំនួន១៦០លានដុល្លារ ដើម្បីស្ដារឡើងវិញ ក្រោយគ្រោះទឹកជំនន់ ដូចជា ការជួសជុលផ្លូវ ស្ពាន និងទំនប់ទឹក ដែលខូចខាតដោយជំនន់ទឹកភ្លៀង។

សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា ៖ «យើងមានថវិកាមួយ ហៅថា ថវិកាមិនទាន់បែងចែក។ នៅក្នុងថវិកាមិនទាន់បែងចែកនេះ ក៏មានថវិកាបម្រុងសម្រាប់គ្រោះមហន្តរាយ។ បើថវិកាហ្នឹងអស់ យើងក៏នឹងបញ្ចេញថវិកាបន្ថែមទៀត ជាមួយនឹងគម្រោងទម្លាក់ថវិកា សាច់ប្រាក់ពលកម្ម ១៦០ លានដុល្លារ។ ជាថវិកាប្រយុទ្ធ ដើម្បីសង្គ្រោះជីវិត លំនឹងសង្គមសេដ្ឋកិច្ច និងជីវភាពប្រជាពលរដ្ឋ ព្រមទាំងតម្រង់ឆ្ពោះទៅរកការស្ដារឡើងវិញ ក្រោយកូវីដ១៩»។


*កងកម្លាំងយោធាជួយសង្គ្រោះក្មេងតូចចេញពីការជន់លិចដោយទឹកជំនន់។* ***ហ្វេសប៊ុកនាយករដ្ឋមន្ត្រី***


*ប្រជាពលរដ្ឋរៀបចំបាវខ្សាច់ទប់ទឹកជំនន់ដែលបានវាយប្រហារខេត្តពោធិសាត់។* ***សារព័ត៌មានដើមអំពិល***

សម្ដេចតេជោ ហ៊ុន សែន ក៏បានបញ្ជាឱ្យរដ្ឋមន្ត្រីក្រសួងកសិកម្ម ក្រសួងសេដ្ឋកិច្ច ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវរួមគ្នាស្ដារឡើងវិញ នូវផ្លូវស្ពាន ទំនប់ទឹក និងផ្ដល់ពូជស្រូវដំណាំនានា ជូនប្រជាកសិករ ដែលរងគ្រោះ ដោយសារជំនន់ទឹកភ្លៀង នាពេលថ្មីៗនេះ។

សម្ដេចបានថ្លែងថា ៖«កុំចាំមន្ទីររាយការណ៍ មកភ្នំពេញ។ យើងចាត់រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការចុះទៅតាមគោលដៅ។ កន្លែងខ្លះ ត្រូវចាត់ច្រើនក្រុមចុះទៅ ពិសេសនៅបាត់ដំបង និងខេត្តបន្ទាយមានជ័យដែលរងគ្រោះធ្ងន់ធ្ងរជាងគេ។ កុំឱ្យប្រជាពលរដ្ឋយើងគាត់លំបាកមួយសាហើយ ដោយសារទឹកលិចពេលនេះ មកលំបាកមួយសាទៀត ក្រោយទឹកស្រក»។

## ការស្ដារនូវដំណាំស្រូវ និងផលដំណាំផ្សេងៗ

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានឱ្យដឹងថា យោងតាមលទ្ធផលនៃការចុះត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពការខូចខាតដំណាំស្រូវដោយសារទឹកជំនន់ទឹកភ្លៀងកន្លងមក របស់លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង ពោធិ៍សាត់ និងបន្ទាយមានជ័យ ដោយសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម បានឱ្យដឹងថា មានទីតាំងមួយចំនួនអាចមានលទ្ធភាពចាប់ផ្ដើមធ្វើការស្ដារការដាំដុះដំណាំស្រូវបាន ជាមួយនឹងលទ្ធភាពប្រភពទឹកគ្រប់គ្រាន់សម្រាប់ស្រូវស្រាល ។

តាមរយៈលទ្ធផលខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តទាំងបី រួមជាមួយនឹងអាជ្ញាធរថ្នាក់ក្រោមជាតិ នឹងបើកយុទ្ធនាការធ្វើការស្ដារជាបឋមលើការដាំដុះដំណាំស្រូវឡើងវិញ តាមកម្មវិធីដូចជា៖ ខេត្តបាត់ដំបង ធ្វើនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២០ នៅភូមិព្រៃក្ដួត ឃុំព្រៃត្រឡាច ស្រុករុក្ខគីរី។ ខេត្តពោធិសាត់ ធ្វើថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ នៅភូមិរបោះរាំង ឃុំអូរតាប៉ោង ស្រុកបាកាន និងខេត្តបន្ទាយមានជ័យៈ ធ្វើនៅសប្ដាហ៍ទី១ ខែវិច្ឆិកា ឆ្នាំ២០២០ នៅក្នុងឃុំរហាត់ទឹក ស្រុកមង្គលបូរី។

លោករដ្ឋមន្ត្រីបានបន្តថា សម្រាប់ការចាប់ផ្ដើមយុទ្ធនាការអន្តរាគមន៍ជាបឋមនេះ ក្រសួងនឹងរៀបចំឱ្យមានត្រាក់ទ័រយ៉ាងតិច៥គ្រឿង គោយន្តពង្រាបដីចំនួន៥គ្រឿង និងម៉ាស៊ីនដាំគ្រាប់ស្រូវចំនួន៣ទៅ៤គ្រឿង នៅលើទីតាំងភូមិនីមួយៗដែលបានកំណត់ខាងលើ ក្នុងខេត្តនីមួយៗ រួមជាមួយការផ្ដល់ពូជស្រូវស្រាល រយៈពេលខ្លី រួមជាមួយនឹងការផ្ដល់គ្រឿងឧបភោគបរិភោគមួយចំនួន សម្រាប់គ្រួសាររងគ្រោះនីមួយៗផងដែរ។

ក្នុងឱកាសចុះជួបជាមួយនឹងប្រជាពលរដ្ឋជួបគ្រោះទឹកជំនន់ក្នុងខេត្តបន្ទាយមានជ័យ សម្ដេចតេជោ ហ៊ុន សែន បានប្រកាសថា រាជរដ្ឋាភិបាល បានគិតរួចជាស្រេចហើយថា ក្រោយទឹកជំនន់ រាជរដ្ឋាភិបាលបានត្រៀមពូជស្រូវចំនួន២,០០០តោន ដែលជាពូជស្រូវមិនប្រកាន់រដូវ ដោយក្នុងមួយគ្រួសារនឹងទទួលបាន១០០គីឡូក្រាម ហើយផ្ដល់ជូនសម្រាប់តែអ្នកដែលខូចខាតតែប៉ុណ្ណោះ។

ជាមួយគ្នានោះ ប្រជាពលរដ្ឋមិនធ្វើស្រូវ តែពួកគាត់ដាំដំណាំនោះ គឺរាជរដ្ឋាភិបាលនឹងផ្ដល់នូវពូជចំនួន០៦មុខដំណាំ ដើម្បីទុកបង្ករបង្កើនផលក្រោយទឹកស្រក់វិញ ថែមទាំងមានគ្រឿងចក្រកសិកម្ម មកបម្រើជូនប្រជាកសិករផងដែរ។

សម្ដេចតេជោ បញ្ជាឱ្យក្រសួងពាក់ព័ន្ធទាំងអស់ត្រូវមានការវាយតម្លៃនៃការខូចខាតរបស់ប្រជាជនក្នុងពេលទឹកជំនន់ ជាពិសេសក្រសួងកសិកម្ម ដោយយើងដោះស្រាយជូនតែអ្នកដែលខូចខាតទេ។

របាយការណ៍បន្តថា ប្រជាជនជាង៩៣០០គ្រួសារក៏ត្រូវបានជម្លៀស និងផ្ទះសម្បែងជាង ៧៣០០០ខ្នងបានរងផលប៉ះពាល់។ សាលារៀនចំនួន៥៦៨កន្លែង និងស្រូវលិចទឹកប្រមាណជាង២១៣.០០០ហិកតាក៏ត្រូវលិចទឹកផងដែរ៕

# ជំរុំទោចផ្ទាល់លឿងនៃសហគមន៍ទេសចរណ៍អណ្ដូងក្រឡឹង

*អត្ថបទ៖ ផល សុផានិត*

សម្លេងស្រែកច្រៀងយ៉ាងទ្រហឹងអឹងកង បន្លឺពីមួយទៅមួយឥតដាច់ ស្នូរសំរឹបជើងមនុស្សពីរបីក្រុម នៅផ្លូវតូចចង្អៀតបន្តគ្នា អមសងខាងផ្លូវដោយរុក្ខជាតិតូចធំ មានវល្លិ៍ឈើ ផ្កាព្រៃបញ្ចេញពិដោរក្រអូបរួមនឹងដំណក់ទឹកធ្លាក់ មកផ្ទៃដី ហាក់ជាតន្ត្រីបែបធម្មជាតិមួយបែប កំដរអារម្មណ៍ទេសចរណ៍ អ្នកដើរព្រៃឱ្យលង់អារម្មណ៍ជាមួយនឹងធម្មជាតិបាននិមិត្ត។

បទចម្រៀងមួយបទរបស់អធិរាជសម្លេងមាស ស៊ិន ស៊ីសាមុត បានបង្ហើរថា ៖«ទោចអើយទោចភ្នំ អ្នកយំរឿងអ្វី ដូចខ្វះចំណី ឬយំព្រោះស្រីជាទីស្នេហា។ ទោចអើយបើយំព្រោះព្រាត់សង្សារ កុំតូចចិត្តណា ព្រោះស្នេហាយើងស្នេហ៍គ្មាននិស្ស័យ....» ហាក់បង្ហាញពីសត្វព្រៃមួយបែប ក្នុងពពួកពានរ នោះគឺទោចផ្ទាល់លឿង។

គេអាចកំណត់សម្គាល់ទោចផ្ទាល់លឿងបានតាមរយៈពណ៌សម្បុររបស់ពួកវា ក្នុងនោះទោចឈ្មោលមានសម្បុរពណ៌ខ្មៅ និងមានរោមនៅថ្ពាល់ពណ៌លឿង ចំណែកញីមានពណ៌លឿងស្វាទុំ មានកញ្ចុំរោមពណ៌ខ្មៅនៅលើក្បាល។

ទោចផ្ទាល់លឿងគ្មានកន្ទុយទេ ចំណែកជើងនិងដៃវែងៗ ដែលជាអំណោយផលពីធម្មជាតិក្នុងការបំលាស់ទី លោតតោងពីដើមឈើមួយទៅដើមឈើមួយទៀត។ ទោចផ្ទាល់លឿង គឺជាប្រភេទសត្វកម្រ និងត្រូវបានជាប់នៅក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទសត្វងាយរងគ្រោះពីពិភពលោក ដោយសារការបាត់បង់ជម្រក និងការបរបាញ់។

ទោចផ្ទាល់លឿង ត្រូវបានគេប្រទះឃើញនៅក្នុងព្រៃស្រោង និងព្រៃពាក់កណ្ដាលស្រោង ជាធម្មតាពួកវារស់នៅជាក្រុម ដែលមានគ្នាពីពីរទៅប្រាំក្បាល ដែលតែងតែបន្លឺសម្លេងស្រែកយំ និងលោតផ្លោះពីដើមឈើមួយទៅដើមឈើមួយ នៅចន្លោះពីម៉ោង៥ទៅ៧ព្រឹក ដែលសម្លេងអាចលឺចន្លោះពី១ទៅ២គីឡូម៉ែត្រ។

> «កាលដែលធ្វើការអភិរក្សនេះ គឺបានផ្ដល់ផលប្រយោជន៍ដោយផ្ទាល់ ដូចជា ទេសចរណ៍ធម្មជាតិ ដូចជានៅតំបន់នេះ ដែលចាហ៊ូខេម ដែលជាផ្នែកមួយនៃ អេកូទេសចណ៍នៃអណ្ដូងក្រឡឹង ដែលបានទាក់ទាញភ្ញៀវទេសចរ»

ចន្លោះពី២ទៅ៣ឆ្នាំទើបសត្វទោចផ្ទាល់លឿងអាចបង្កកំណើតបានម្ដង និងផ្ដល់កំណើតម្ដងបានតែកូនមួយប៉ុណ្ណោះ បន្ទាប់ពីពពោះរយៈពេល៦ខែ។ ក្រុមអ្នកស្រាវជ្រាវបាយរស់នៅរបស់វា នៅភាគខាងកើតទន្លេមេគង្គភាគឥសាន្ត នៃប្រទេសកម្ពុជា និងភាគខាងត្បូងនៃប្រទេសវៀតណាម និងប្រទេសឡាវ។

យោងតាមរបាយការណ៍របស់អង្គការសមាគមន៍អភិរក្សសត្វព្រៃកម្ពុជា WCS បានបង្ហាញថា ស្ថិតិសត្វទោចផ្ទាល់លឿងមានប្រមាណ ១២០០ក្បាល ភាគច្រើនមានវត្តមានក្នុងដែនជម្រកសត្វព្រៃកែវសីម៉ាច្រើនជាងគេ។

ជាភ័ព្វសំណាងរបស់កម្ពុជា មានប្រភេទសត្វកម្របែបនេះរស់នៅច្រើន ជាមួយនឹងការទស្សនាវត្តមានរបស់ពួកវាដោយផ្ទាល់ នៅជំរុំសត្វទោចដែលមានឈ្មោះថា ចាហ៊ូខែម។ ប្រធានគ្រប់គ្រងគម្រោងបានថ្លែងថា លោកពិតជារីករាយណាស់ដែលបានជួយដល់ការការពារធនធានធម្មជាតិ សត្វព្រៃនៅកម្ពុជា។ លោកថា នៅជំរុំសត្វទោចដែលលោកធ្វើការនេះ គឺជាទីតាំងពិសេសដែលមានវត្តមានសត្វព្រៃដ៏សម្បូរបែបរស់នៅ។

លោក Kyle Winney ប្រធានគម្រោង Jahoo (ចាហ៊ូ) Camp បានអោយដឹងថា៖«ខ្ញុំពិតជារីករាយ និងមានមោទនភាព ដែលខ្ញុំបានធ្វើការ និងជួយគាំទ្រការអភិរក្សសត្វព្រៃនៅទីនេះ»។

ចាហ៊ូខេម (Jahoo Camp) ឬហៅជាភាសាខ្មែរថា ជំរុំទោចបានដំណើរការតាំងពីឆ្នាំ២០១៤ ដោយក្រសួងបរិស្ថាន និងមានការជួយគាំទ្រពីអង្គការសមាគមន៍អភិរក្សសត្វព្រៃកម្ពុជា WCS និងអង្គការវើលហូប (World Hope) សត្វទោចនៅទីនេះ ត្រូវបានបន្សាំដោយជោគជ័យ នៅពេលដែលភ្ញៀវទេសចរទៅទស្សនា អ្នកស្រាវជ្រាវសត្វទោចផ្ទាល់លឿងក្នុងសហគមន៍ទេសចរណ៍ ភូមិអណ្ដូងក្រឡឹង និងជាអ្នកនាំភ្ញៀវទេសចរចូលព្រៃ ទស្សនាសត្វព្រៃ បានបញ្ជាក់ថា ដើម្បីអាចទស្សនាសត្វទោចផ្ទាល់លឿងបាន ភ្ញៀវទេសចរត្រូវក្រោកពីព្រលឹមចូលព្រៃ ដើម្បីរងចាំមើលវត្តមានរបស់ពួកវា។

លោក ម្ញើក ហុង ជាអ្នកនាំភ្ញៀវទេសចរមើលសត្វទោច បានបញ្ជាក់ថា៖«បាទ!នៅម៉ោង៥ព្រឹកយើងត្រូវតែមកដល់ចាហ៊ូនៅម៉ោងប៉ុណ្ណោះ ហើយយើងចូលទៅក្នុងព្រៃនៅម៉ោង៦ព្រឹក យើងចាប់ផ្ដើមមើលសត្វ។ បើនិយាយពីទូទៅ វាមានច្រើន បើនិយាយពីការបន្សាំរបស់ពួកខ្ញុំមានច្រើន សម្រាប់បន្សាំអោយសត្វស្លូត»។

បច្ចុប្បន្នគម្រោងអភិរក្សនេះ បានទាក់ទាញភ្ញៀវទេសចរជាតិ និងជាពិសេសទេសចរណ៍អន្តរជាតិមកទស្សនាយ៉ាងច្រើនកុះករ មិនតែប៉ុណ្ណោះតាមរយៈវិស័យទេសរណ៍មួយនេះ ក៏បានរួមចំណែកជួយកាត់បន្ថយ ភាពក្រីក្ររបស់បងប្អូនប្រជាពលរដ្ឋ នៃជនជាតិដើមភាគតិចបានមួយកម្រិត។

បើតាមលោក នេត្រ ភក្ត្រា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងបរិស្ថាន ក៏បានថ្លែងបញ្ជាក់ថា ៖«កាលដែលធ្វើការអភិរក្សនេះ គឺបានផ្ដល់ផលប្រយោជន៍ដោយផ្ទាល់ដូចជាទេសចរណ៍ធម្មជាតិ ដូចជានៅតំបន់នេះ ដែលចាហ៊ូខេម ដែលជាផ្នែកមួយនៃ អេកូទេសចណ៍នៃអណ្ដូងក្រឡឹង ដែលបានទាក់ទាញភ្ញៀវទេសចរ»។

យោងតាមរបាយការណ៍របស់អ្នកគ្រប់គ្រងនៅតំបន់នេះ គឺ២០១៩កន្លងទៅ មានភ្ញៀវទេសចរប្រមាណជា ៤៥០នាក់ មកទស្សនានៅកន្លែងនេះ ហើយទទួលបានចរិការប្រមាណជា១ម៉ឺនដុល្លាអាមេរិកសម្រាប់ភូមិអណ្ដូងក្រឡឹងនេះ»។

ចាហ៊ូខេម (Jahoo Camp) មានទីតាំងស្ថិតនៅភូមិអណ្ដូងក្រឡឹង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ក្នុងដែនជម្រកសត្វព្រៃកែវសីម៉ា។ ជំរុំសត្វទោចផ្ទាល់លឿងនេះ មានចម្ងាយប្រមាណជា ៣១គីឡូម៉ែត្រពីក្រុងសែនមនោរម្យ៕

## ទិវាស្បៀងអាហារពិភពលោក៖ «រួមគ្នាផលិតស្បៀងសម្រាប់មនុស្ស និងនិរន្តរភាពផែនដី»

*អត្ថបទ៖ អមរិន្ទ្រដានុត*

ទិវាស្បៀងអាហារពិភពលោក និងខួបទី៧៥របស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) អំពាវនាវឱ្យមានការផ្លាស់ប្ដូរប្រព័ន្ធស្បៀងអាហារ ដើម្បីធានារបបអាហារប្រកបដោយសុខភាព ខណៈពេលដែលមានការផ្ទុះឡើងនៃជំងឺកូវីដ-១៩។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO in Cambodia) ចេញផ្សាយនៅថ្ងៃសុក្រ ទី១៦ ខែតុលា ឆ្នាំ២០២០នេះ បានឱ្យដឹងថាទិវាស្បៀងអាហារពិភពលោកឆ្នាំនេះ ប្រារព្ធឡើងក្នុងកាលៈទេសៈមួយដែលមិនធ្លាប់មានពីមុនមក។

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) អំពាវនាវឱ្យមានការចូលរួមពីគ្រប់វិស័យទាំងអស់ ដើម្បីធ្វើឱ្យប្រព័ន្ធស្បៀងអាហារកាន់តែរឹងមាំ មានភាពធន់ និងមាននិរន្តរភាព ជាពិសេសដើម្បីធានារបបអាហារប្រកបដោយសុខភាព ហើយប្រជាជនកម្ពុជាទាំងអស់មានលទ្ធភាពទទួលបានជាពិសេសសម្រាប់ជនងាយរងគ្រោះបំផុត។

សេចក្ដីប្រកាសព័ត៌មានបានលើកឡើងថា ៖ «គោលដៅនេះ អាចសម្រេចទៅបានលុះត្រាតែយើងមានប្រព័ន្ធស្បៀងអាហារដែលមានភាពធន់ និងរឹងមាំ។ យើងត្រូវតែផ្លាស់ប្ដូររបៀបនៃការផលិត របៀបនៃការកែច្នៃ ការធ្វើអាជីវកម្ម និងរបៀបនៃការបរិភោគអាហារ ដើម្បីធានាថាយើងអាចបំពេញតម្រូវការរបស់យើងនាពេលអនាគតដោយមិនខ្វះខាត មិនបំផ្លាញជីវៈចម្រុះ និងធនធានធម្មជាតិផ្សេងទៀតដែលយើងពឹងផ្អែកក្នុងការរស់នៅ»។

ក្រោមកិច្ចសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កម្មវិធីស្បៀងអាហារពិភពលោក (WFP) និងដៃគូដទៃទៀត ទិវាស្បៀងអាហារពិភពលោកតែងតែប្រព្រឹត្តិទៅនៅថ្ងៃទី១៦ ខែតុលាជារៀងរាល់ឆ្នាំ។

«ទិវាស្បៀងអាហារពិភពលោកឆ្នាំ២០២០» ប្រារព្ធធ្វើឡើងនៅខេត្តសៀមរាបក្រោមប្រធានបទ "រួមគ្នាផលិតស្បៀងសម្រាប់មនុស្ស និងនិរន្តរភាពផែនដី" ។ ទិវានេះ ជាឱកាសក្នុងការផ្ដោតទៅលើសាមគ្គីភាព និងភាពជាដៃគូដ៏រឹងមាំ រវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងអ្នកគ្រប់គ្នាទាំងអស់ ដើម្បីធ្វើឱ្យប្រាកដថា ប្រព័ន្ធស្បៀងអាហាររបស់យើងផលិតចំណីអាហារចម្រុះ ដើម្បីទ្រទ្រង់សុខភាពប្រជាជនដែលកំពុងតែកើនឡើង និងធានាទ្រទ្រង់ជីវិតលើផែនដីប្រកបដោយនិរន្តរភាព។

នៅជុំវិញពិភពលោកជំងឺរាតត្បាតនេះ បានបង្ហាញឱ្យឃើញពីភាពផុយស្រួយនៃប្រព័ន្ធស្បៀងអាហារ ហើយវាបានគំរាមកំហែង និងធ្វើឱ្យមនុស្សរាប់លាននាក់ផ្សេងទៀតធ្លាក់ចូលក្នុងវិបត្តិនៃភាពអត់ឃ្លាន។

ភាពអត់ឃ្លាន ជំងឺលើសទម្ងន់ ការសឹករិចរិលនៃបរិស្ថាន និងការបាត់បង់ប្រព័ន្ធជីវចម្រុះ ការបាត់បង់ និងការខ្ជះខ្ជាយស្បៀងអាហារ ព្រមទាំងហានិភ័យផ្សេងៗដែលប៉ះពាល់ដល់កម្មករ និងកសិករនៅក្នុងខ្សែច្រវាក់អាហារ គឺជាបញ្ហាមួយចំនួនដែលបង្ហាញអំពីអតុល្យភាពស្បៀងនេះ។

សូម្បីតែមុនពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩ មនុស្សប្រមាណជាង២ពាន់លាននាក់គ្មានលទ្ធភាពទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងអាហារូបត្ថម្ភគ្រប់គ្រាន់ជាទៀងទាត់ឡើយ។ មនុស្សប្រមាណជិត៧០០លាននាក់ផ្សេងទៀត ចូលគេងទាំងមានការស្រេកឃ្លាននៅទូទាំងពិភពលោក នេះបើយោងតាមរបាយការណ៍ស្ដីពី ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងពិភពលោកឆ្នាំ២០២០។

ជំងឺកូវីដ-១៩ បានបន្ថែមបញ្ហាប្រឈមថែមទៀត។ របាយការណ៍ដដែល បានបង្ហាញថាការរំខានខាងសេដ្ឋកិច្ចបណ្ដាលមកពីជំងឺរាតត្បាតនេះ អាចនឹងរុញច្រានឱ្យប្រជាជនប្រមាណ ១៣០លាននាក់ផ្សេងទៀតនៅទូទាំងពិភពលោកឱ្យធ្លាក់ក្នុងភាពអត់ឃ្លាននាចុងឆ្នាំនេះ។

នៅកម្ពុជា ទោះបីមានការរីកចម្រើនគួរឱ្យកត់សម្គាល់យ៉ាងណាក៏ដោយ កង្វះអាហារូបត្ថម្ភ នៅតែជាបញ្ហាដែលគួរឱ្យព្រួយបារម្ភ ដោយមានកុមារអាយុក្រោមប្រាំឆ្នាំប្រមាណ ៣២ភាគរយ មានជំងឺក្រិះក្រិន ហើយ១០ភាគរយផ្សេងទៀតមានបញ្ហាស្គមស្គាំង។

ប្រជាជនកម្ពុជាភាគច្រើនរស់នៅតាមទីជនបទ ហើយពួកគេងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ។ ជាញឹកញាប់ ទឹកជំនន់ និងគ្រោះរាំងស្ងួតតែងគំរាមកំហែងដល់ប្រព័ន្ធស្បៀងអាហារ ហើយវានឹងមានការកើនឡើងកាន់តែញឹកញាប់នាពេលអនាគត។ កម្ពុជា ស្ថិតក្នុងចំណាត់ថ្នាក់ទី៩នៅលើពិភពលោក ជាប្រទេសដែលងាយរងគ្រោះបំផុត បើយោងទៅតាមសន្ទស្សន៍ហានិភ័យគ្រោះមហន្តរាយពិភពលោកឆ្នាំ២០១៩។ នេះ សបញ្ជាក់ពីភាពចាំបាច់ក្នុងការកសាងភាពធន់របស់សហគមន៍ចំពោះការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ និងធានាថាពួកគេអាចទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងអាហារូបត្ថម្ភគ្រប់គ្រាន់ពេញមួយឆ្នាំ។

លោក Alexandre Huynh តំណាងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ប្រចាំនៅកម្ពុជាបានមានប្រសាសន៍ថា ទិន្នន័យ ប្រព័ន្ធបច្ចេកវិទ្យា និងការច្នៃប្រឌិត រួមជាមួយនឹងការសម្របសម្រួលយ៉ាងស្វាហាប់ និងការវិនិយោគប្រកបដោយការទទួលខុសត្រូវ គឺចាំបាច់ណាស់ក្នុងការសម្រេចបានកាន់តែប្រសើរថែមទៀតនូវផលិតកម្មកសិកម្ម អាហារូបត្ថម្ភ បរិស្ថាន និងជីវភាពរស់នៅ។

លោកបានបន្ថែមថា ៖ «ការធានាឱ្យទទួលបាននូវអាហារសុវត្ថិភាព និងអាហារូបត្ថម្ភ គឺមានសារសំខាន់ណាស់ ហើយប្រការនេះ គឺចាំបាច់ និងបន្តនៅតែចាំបាច់ក្នុងការឆ្លើយតបទៅនឹងវិបត្តិជំងឺកូវីត-១៩ ជាពិសេសសម្រាប់សហគមន៍ក្រីក្រ និងងាយរងគ្រោះ ដែលជាក្រុមទទួលរងផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរបំផុតដោយសារតែវិបត្តិមួយនេះ»។

អង្គការ FAO និងដៃគូនានា បានត្រៀមខ្លួនជាស្រេចដើម្បីគាំទ្ររាជរដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងវិបត្តិជំងឺកូវីដ-១៩ និងធានាឱ្យបាននូវប្រព័ន្ធស្បៀងអាហារប្រកបដោយនិរន្តរភាព។ អង្គការ FAO ក៏កំពុងជួយដល់ប្រទេសកម្ពុជាក្នុងការផលិតទិន្នន័យកសិកម្មថ្មីៗ និងអាចជឿទុកចិត្តបាន ដើម្បីជាជំនួយដល់ការរៀបចំគោលនយោបាយ និងការសម្រេចចិត្តនានា ព្រមទាំងការគាំទ្រដល់ការកសាងសមត្ថភាពជាតិក្នុងការផ្លាស់ប្ដូរវិស័យកសិកម្មកម្ពុជាប្រកបដោយបរិយាបន្ន ការប្រកួតប្រជែង ភាពធន់ និងនិរន្តរភាព៕





# គណបក្សប្រជាជនកម្ពុជា ផ្អាករៀបចំកម្មវិធីសំខាន់ៗ ដោយសារកូវីដ-១៩



អគារថ្មីនៃទីស្នាក់ការកណ្ដាលគណបក្សប្រជាជនកម្ពុជា។ **រូបភាព៖ Freshnews**

*អត្ថបទ៖ ផល សុផានិត*

គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាច បានសម្រេចផ្អាកការរៀបចំសន្និបាតគណៈកម្មាធិការកណ្ដាលនៅដំណាច់ឆ្នាំ២០២០ និងខួបអនុស្សាវរីយ៍លើកទី៤២ នៃទិវាជ័យជម្នះ៧មករា ដោយសារតែការរីករាលដាលជំងឺកូវីដ១៩។

ការសម្រេចនេះត្រូវបានប្រកាសដល់ថ្នាក់ដឹកនាំ និងសមាជិកគ្រប់ជាន់ថ្នាក់របស់ខ្លួន កាលពីថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០។

បើយោងតាមលិខិតរបស់គណបក្សប្រជាជនកម្ពុជា ដែលចុះហត្ថលេខាដោយសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ អនុប្រធានគណបក្សប្រជាជនកម្ពុជា បានបញ្ជាក់ឱ្យដឹងថា យោងសភាពការណ៍នៃជំងឺកូវីដ១៩ ដែលនៅតែបន្តឆ្លងរាលដាលខ្លាំងពាសពេញពិភពលោក និងតម្រូវឱ្យកម្ពុជា ត្រូវតែបន្តប្រុងប្រយ័ត្នក្នុងកម្រិតខ្ពស់ជាប់ជានិច្ចនោះ គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ត្រូវផ្អាកការធ្វើសន្និបាតគណៈកម្មាធិការកណ្ដាល នៅដំណាច់ឆ្នាំ២០២០នេះសិន។

សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ បានបញ្ជាក់ថា ៖ «សូមសមាជិក សមាជិកា គណៈកម្មាធិការកណ្ដាល ទាំងអស់ និងគណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ ជ្រាបអំពីការប្រារព្ធពិធីប្រចាំឆ្នាំរបស់គណបក្ស នៅពេលខាងមុខនេះថា ការធ្វើសន្និបាតគណៈកម្មាធិការកណ្ដាល នៅដំណាច់ឆ្នាំ២០២០នេះត្រូវផ្អាកសិន ប៉ុន្តែនៅពេលនោះគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល នឹងរៀបចំនូវឯកសារ របាយការណ៍ស្ដីពីសភាពការណ៍ទូទៅ និងការងារគណបក្សឆ្នាំ២០២០ និងទិសដៅភារកិច្ចឆ្នាំ២០២១ ដើម្បីផ្ញើជូនឱ្យគណបក្សគ្រប់ថ្នាក់ ចាត់ចែង រៀនសូត្រ ផ្សព្វផ្សាយ និងអនុវត្តភារកិច្ចបន្តទៀត»។

លោកបានបន្ថែមថា ត្រូវផ្អាកការជួបប្រជុំមន្ទិញ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤២ នៃទិវាជ័យជម្នះ៧មករា ដែលត្រូវធ្វើនៅថ្ងៃទី៧ ខែមករា ឆ្នាំ២០២១ នេះសិន ប៉ុន្តែគ្រប់ថ្នាក់ត្រូវត្រៀមរៀបចំបដាពាក្យស្លោក។ល។ ដាក់តាំងនៅតាមទីតាំងនានា ដើម្បីអបអរសាទរដូចដែលធ្លាប់បានធ្វើជារៀងរាល់ឆ្នាំកន្លងមក៕

## តម្បាញហូលពិតានខ្មែរនៅសៀមរាប ប្ដេជ្ញាផ្ទេរចំណេះដឹងដល់អ្នកជំនាន់ក្រោយ

*អត្ថបទ៖ ផល សុផានិត*

ក្រណាត់ធ្វើអំពីសូត្រ លើកជាក្បាច់គោមផ្សេងៗ ឬ រូបសត្វ ក្នុងពុទ្ធសាសនា ឬ រូបពុទ្ធប្រវត្តិ ឬ រឿងជាតក ដែលប្រជាជនកម្ពុជា និយមប្រើជាវត្ថុសក្ការបូជា ដើម្បីដាក់ចងជាពិតានលើព្រះពុទ្ធបដិមា នៅក្នុងវត្តអារាម ហៅថាហូលពិតាន។

បច្ចុប្បន្នសហគមន៍តម្បាញហូលពិតានខ្មែរ នៅខេត្តសៀមរាប កំពុងផលិតតាមធម្មជាតិ និងបណ្ដុះបណ្ដាលជូនកូនខ្មែរជំនាន់ក្រោយ ដើម្បីចូលរួមអភិរក្ស។

បើតាមកញ្ញា រិន រដ្ឋា បុគ្គលិកវិទ្យាស្ថានវាយនភណ្ឌសូត្រប្រពៃណីខ្មែរនាំមកនូវគំនិតថ្មី ខេត្តសៀមរាប ហៅកាត់ថា អង្គការ អាយខេធីធី បាននិយាយថា មានប្រជាពលរដ្ឋមួយចំនួនតូចមិនបានដឹងថា នៅក្នុងខេត្តសៀមរាប មានអ្នកផលិតក្រណាត់ធ្វើអំពីសូត្រ ពណ៌ធម្មជាតិ ដែលរក្សាទុកតាំងពីសម័យដើម ដោយអនុវត្តន៍ឡើងតាមលំនាំក្នុងសៀវ ភៅលំនាំចេញពីសំពត់ចាស់ៗ ដែលបន្សល់ទុកពីចាស់ទុំ បុរាណ បានចងជាឯកសារទុក។

កញ្ញាបានបន្តថា ការជ្រលក់ពណ៌ប្រើដោយធម្មជាតិ ការត្បាញ ស្រាវសូត្រ គឺធ្វើដោយដៃ គ្មានប្រើប្រាស់ឧបករណ៍ដោយម៉ាស៊ីននោះទេ។ សព្វថ្ងៃ អង្គការ បានដាំមន និងចិញ្ចឹមកូននាង មានបុគ្គលិកប្រមាណជាង១០០នាក់ កំពុងបំពេញការងារនេះ។

អ្នកស្រី ប៉ៅ ប៉ាក់ អ្នកផលិតហូលពិតាន រស់នៅខេត្តសៀមរាប បានឱ្យដឹងដែរថា សព្វថ្ងៃ ចំពោះការផលិតហូលពិតាន មានការលំបាក ព្រោះនៅពេលធ្វើហូលពិតាន ត្រូវមានអារម្មណ៍ស្រស់ថ្លា ប្រសិនបើមានអារម្មណ៍មិនល្អ ឆេវឆាវ ធ្វើមិនល្អនោះទេ។

អ្នកស្រី ប៉ៅ ប៉ាក់ បានបញ្ជាក់ទៀតថា គ្រប់ហូលពិតានទាំងអស់ រាល់ការជាវរបស់អតិថិជនគ្រប់រូបត្រូវតែយកទៅដាក់តាំងលើជញ្ជាំង ឬក៏ប្រគេនព្រះសង្ឃតាមទីវត្តអារាម ហាមផ្ដាច់យកមកធ្វើជាសំលៀកបំពាក់ ដោយមានជំនឿពីបុរាណមកថា ប្រសិនបើយើងយកមកធ្វើជាសំលៀកបំពាក់ គឺអ្នកដែលស្លៀកនោះ នឹងទទួលផលបាប។

សិល្បៈតម្បាញសូត្រ សង្កេតឃើញថា មានសហគមន៍តម្បាញសូត្រមួយចំនួន នៅខេត្តតាកែវ និងខេត្តសៀមរាប កំពុងបន្តថែរក្សារហូតមកដល់សព្វថ្ងៃនេះ៕



ពិព័រណ៍ហូលពិតានខ្មែរ កាលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ មានភ្ញៀវកិត្តិយសចូលរួមយ៉ាងច្រើនកុះករដើម្បីលើកទឹកចិត្ត និងចូលរួមអភិរក្សថែរក្សាសិល្បៈតម្បាញ ហូលពិតានខ្មែរ។ **រូបភាព៖ ទូរទស្សន៍ភីអិនអិន**

## ជនរងគ្រោះដោយសារគ្រឿងផ្ទុះ ក្នុងរយៈពេល៩ខែមានការថយចុះ



(ខាងលើ) គោយន្តដែលបានកិនមីនបណ្ដាលឱ្យស្លាប់អ្នកបើកបរ និង គ្រាប់មីនដែលត្រូវបានស៊ីម៉ាក់ដោះបាន ត្រៀមកំទេចចោល។ **រូបភាព៖ សហការី**

*អត្ថបទ៖ អមរិន្ទ្រ ដានុត*

យ៉ាងហោចណាស់មនុស្សចំនួន៥៥នាក់រងគ្រោះដោយសារយុទ្ធភ័ណ្ឌគ្រឿងផ្ទុះក្នុងរយៈពេល៩ខែដើមឆ្នាំ២០២០នេះ។ នេះបើយោងតាមរបាយការណ៍របស់អាជ្ញាធរមីន នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០នេះ។

របាយការណ៍បានបន្តថា ចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២០ មានជនរងគ្រោះចំនួន ៥៥នាក់ ក្នុងនោះរងគ្រោះដោយសារមីនប្រឆាំងមនុស្សចំនួន១៤នាក់ មីនតោនចំនួន៩នាក់ និងសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន៣២នាក់ ដោយក្នុងនោះមានអ្នកស្លាប់ចំនួន១៦នាក់។

តួលេខនេះមានការថយចុះ ១៧ភាគរយ ប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៩ ដែលមានជនរងគ្រោះចំនួន៦៦នាក់។

ខេត្តដែលមានជនរងគ្រោះដោយសារយុទ្ធភ័ណ្ឌគ្រឿងផ្ទុះនេះ មាននៅខេត្តបាត់ដំបង ដែលមានជនរងគ្រោះច្រើនជាងគេដែលមានចំនួន១៦នាក់ ក្នុងនោះពិការ៦នាក់ របួស៦នាក់ និងស្លាប់៤នាក់ ខេត្តបន្ទាប់មានខេត្តពោធិ៍សាត់ មាន១០នាក់រងគ្រោះ ខេត្តព្រះវិហារមាន៨នាក់រងគ្រោះ ខេត្តបន្ទាយមានជ័យ មាន៧នាក់រងគ្រោះ ខេត្តកំពង់ធំ ក្រចេះ ប៉ៃលិន ត្បូងឃ្មុំ ឧត្តរមានជ័យ មណ្ឌលគិរី ស្ទឹងត្រែង និងខេត្តកណ្ដាល។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវចក្ខុវិស័យ និងគោលដៅយ៉ាងច្បាស់លាស់ ក្នុងការបញ្ចប់ការគម្រាមកំហែងដោយមីនឱ្យអស់ត្រឹមឆ្នាំ២០២៥ និងការកាត់បន្ថយអត្រាគ្រោះដោយសារមីនអោយបានជាអតិបរមា៕

# គ្រូអប់រំជំនឿទទួលព្រះពរ និងបេសកកម្ម សម្រាប់ដំណាក់កាលថ្មីក្នុងរដូវកាលកូវីដ១៩

*អត្ថបទ៖ ស៊ីអេសស៊ី*

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានបើកសកម្មភាពអប់រំជំនឿកាតូលិករបស់ខ្លួនឡើងវិញ សម្រាប់ឆ្នាំ២០២០-២០២១ ក្រោមអធិបតីភាពរបស់លោកអភិបាល អូលីវីយេ ផ្មិតហស្លេរ រយៈពេល២ថ្ងៃគឺពីថ្ងៃទី៣និងទី៤ ខែតុលា ឆ្នាំ២០២០កន្លងទៅនេះ។

ពិធីនេះបានប្រារព្ធធ្វើនៅព្រះវិហារសន្តសិលា និងសន្តប៉ូល ភ្នំពេញថ្មី។



*លោកអភិបាល អូលីវីយេ ផ្មិតហស្លេរ មានប្រសាសន៍ និងលើកទឹកចិត្តដល់គ្រូអប់រំជំនឿក្នុងឱកាសបានបើកសកម្មភាពអប់រំជំនឿកាតូលិកឡើងវិញ។ **រូបភាព៖ ស៊ីអេសស៊ី***

ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា បានផ្អាកការជួបជុំបែបសាសនាមួយរយៈដោយគោរពតាមសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលដើម្បីចូលរួមប្រយុទ្ធនឹងជំងឺកូវីដ១៩ តាំងពីពាក់កណ្តាលខែមីនា ឆ្នាំ២០២។ សកម្មភាពដែលបានផ្អាក ក្នុងនោះមានសកម្មភាពអប់រំជំនឿ សម្រាប់អ្នកឈ្វេងយល់អំពីព្រះយេស៊ូ ដូចជាក្រុមមនុស្សពេញវ័យ យុវជនជំទង់ និងកុមារ ប៉ុន្តែនៅចុងខែកញ្ញា ឆ្នាំ២០២០ ក្រសួងសុខាភិបាលក៏បានអនុញ្ញាតការជួបជុំបែបសាសនាឡើងវិញ ដោយប្រើវិធានសុវត្ថិភាព និងការកាត់បន្ថយការជួបជុំមានសមាជិកច្រើន។

ដូនជីកាតូលិក បងស្រី ធារី អ្នកសម្របសម្រួលការិយាល័យអប់រំជំនឿ និងគម្ពីរភូមិភាគភ្នំពេញបានឱ្យដឹងថា ការប្រារព្ធកម្មវិធីបើកវគ្គអប់រំជំនឿសម្រាប់ឆ្នាំថ្មី មិនអាចជួបជុំរួមគ្នាទាំង៩មណ្ឌលសកម្មភាពនោះឡើយ គឺធ្វើតាមដំណាក់កាល។ សម្រាប់ថ្ងៃទី៣-៤ ខែតុលា ប្រារព្ធសម្រាប់គ្រូអប់រំជំនឿនៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង ភ្នំពេញខាងជើង តាខ្មៅ និងមណ្ឌលសកម្មភាពភ្នំពេញថ្មី ដែលមានអ្នកចូលរួមប្រមាណ៤០នាក់។

បងស្រីធារីបានបន្តថា ការជួបជុំពីរថ្ងៃនេះ គ្រូទាំងអស់ បានចែករំលែក និងស្តាប់បទពិសោធន៍អប់រំបន្តជំនឿទៅវិញទៅមក ស្តាប់ការណែនាំ និងលើកទឹកចិត្តពីលោកអភិបាល និងទទួលផែនការពីការិយាល័យអប់រំជំនឿ និងគម្ពីរភូមិភាគភ្នំពេញ។

បងស្រីថ្លែងថា ៖ «ក្នុងកម្មវិធីនោះ លោកអភិបាល អូលីវីយេ បានប្រទានពរ និងចាត់ឱ្យគេឱ្យទៅក្នុងបេសកកម្មជាគ្រូអប់រំជំនឿ។ ពិធីនេះជួយឱ្យគ្រូអប់រំជំនឿ យកចិត្តទុកដាក់អំពីបេសកកម្មរបស់គេ»។

ក្នុងធម្មទេសនា លោកអភិបាលអូលីវីយេ បានមានប្រសាសន៍និងលើកទឹកចិត្តដល់គ្រូអប់រំជំនឿថា៖ «បេសកកម្មរបស់គ្រូអប់រំជំនឿ គឺជាបេសកកម្មដែលព្រះសហគមន៍ប្រគល់ឱ្យគ្រូអប់រំជំនឿ ដោយមានព្រះវិញ្ញាណគង់នៅ»។

នាឱកាសនោះផងដែរ លោកអភិបាលក៏បានរំឭកឱ្យគ្រូម្នាក់ៗយកចិត្តទុកដាក់ដូចជា រៀបចំមេរៀន និងទីកន្លែងបង្រៀនឱ្យហ្មត់ចត់ ត្រូវតែរៀនបន្ថែម និងពង្រឹងជំនឿខ្លួនឯងដោយចូលរួមសិក្ខាសាលា ឬការណែនាំរបស់ព្រះសហគមន៍ ផ្តល់សក្ខីភាព និងត្រូវធ្វើដំណើររួមជាមួយអ្នកឈ្វេងយល់ និងត្រូវណែនាំឱ្យពួកគាត់មានបទពិសោធន៍ផ្ទាល់និងរស់នៅយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ដោយយកព្រះសហគមន៍ជាទីពឹង។

ពិតមែន! ការអប់រំនឿ គឺត្រូវអប់រំអំពីជំនឿ ហេតុនេះមិនគ្រាន់តែប្រើចំណេះដឹងប៉ុណ្ណោះទេ គឺត្រូវពឹងលើជំនឿ ដោយភ្ជាប់នឹងជីវិតផ្ទាល់ខ្លួន។ នេះជាការបញ្ជាក់ពីលោកដួង សាវង់ ប្រធានការិយាល័យអប់រំជំនឿព្រះសហគមន៍កាតូលិកកម្ពុជា។

លោកមានប្រសាសន៍ថា ៖ «គ្រូអប់រំត្រូវយកចិត្តទុកដាក់ជាមួយបងប្អូនដែលមកទទួលការអប់រំជំនឿ។ ជាពិសេសឱ្យបងប្អូនយកចិត្តទុកដាក់អំពីការអធិដ្ឋាន អំពីព្រះបន្ទូល ដោយក្នុងជីវិតរស់នៅប្រចាំថ្ងៃ»។

លោកបន្តថា ជំនឿមិនមែនចំណេះដឹងផ្សេងពីការរស់នៅ ដូច្នេះការអប់រំជំនឿគឺត្រូវប្រែក្លាយជីវិតរស់នៅរបស់បងប្អូនផ្ទាល់។

លោក កាន់ ប៊ុយ ជាសមាជិកគណៈកម្មការព្រះគម្ពីរកាតូលិកកម្ពុជាក៏បានលើកឡើងក្នុងឱកាសនោះដែរថា ការអប់រំជំនឿ គ្រូទាំងអស់ក៏ត្រូវយកចិត្តទុកដាក់ជាមួយព្រះគម្ពីរ អានព្រះបន្ទូលជាប្រចាំ។

លោកថា ព្រះគម្ពីរមានសារៈសំខាន់ សម្រាប់កម្មវិធីអប់រំជំនឿដោយមានគរុកោសល្យឈ្វេងយល់អំពីព្រះបន្ទូល ដែលព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់យើង។ ឱ្យយើងមានវិធីសាស្រ្តនាំព្រះបន្ទូល ហើយព្រះបន្ទូលទាំងអស់នោះហើយដែលជួយឱ្យយើងយល់ពីអាថ៌កំបាំងនៃដំណឹងល្អ អំពីការសង្គ្រោះសម្រាប់យើងផ្ទាល់ជាអ្នកណែនាំ និងសម្រាប់បងប្អូនដែលមកទទួលការជំនឿ៕





*សកម្មភាពអប់រំជំនឿកាតូលិករបស់ខ្លួនឡើងវិញ សម្រាប់ឆ្នាំ២០២០-២០២១ ក្រោមអធិបតីភាពរបស់លោកអភិបាល អូលីវីយេ ផ្មិតហស្លេរ។ **រូបភាព៖ ស៊ីអេសស៊ី***





# លោក សែ សាត ទទួលបន្ទុកលើព្រះវិហារចំនួន៨



*លោកប្រ៊ុយណូ កូសម៌ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម បានជ្រើសតាំងលោក បូជាចារ្យ ស្ទេផាន សែ សាត។ **រូបភាព៖ ស៊ីអេសស៊ី***

*អត្ថបទ៖ ស៊ីអេសស៊ី*

លោកប្រ៊ុយណូ កូសម៌ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម បានជ្រើសតាំងលោកបូជាចារ្យ ស្ទេផាន សែ សាត ឱ្យមើលការខុសត្រូវលើព្រះសហគមន៍កំពង់ចាម កោះរការ ព្រែក ពោធិ៍ ចម្លាក់ ភូមិថ្មី រលៀក បុសខ្នុរ និងព្រៃទទឹង។

នេះបើតាមខ្លឹមសារលើលិខិតដែលលោកបូជាចារ្យទទួលបាន កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២។

ក្នុងលិខិតដដែលនេះ លោកអភិបាល ប្រ៊ុយណូ បានបញ្ជាក់ថា មុខងារថ្មីរបស់លោក សែ សាត ត្រូវអនុវត្តចាប់តាំងពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ដោយមានប្រសិទ្ធភាពរយៈពេលប្រាំមួយឆ្នាំ លើកលែងតែករណីលោកអភិបាលបញ្ឈប់ការងារ ឬផ្លាស់ប្តូរទីកន្លែងស្របតាមច្បាប់ព្រះសហគមន៍ ឬការសុំលាឈប់ពីការងារតាមសំណូមពររបស់លោកបូជាចារ្យផ្ទាល់។

លិខិតបានបន្តថា ៖ «ក្នុងនាមជាសមាជិកក្រុមបូជាចារ្យប្រចាំភូមិភាគកំពង់ចាម សូមលោកបូជាចារ្យជួយរំលែកបន្ទុក មើលខុសត្រូវរបស់លោកអភិបាល ក្នុងមុខងារប្រមៃប្រមូលអប់រំជំនឿគ្រីស្តបរិស័ទ និងសរសើរតម្កើងព្រះជាម្ចាស់ នៅតាមបណ្តាព្រះសហគមន៍ដែលលោកអភិបាលបានប្រគល់ជូនលោកមើលខុសត្រូវ។ សូមលោកសហការជាមួយបូជាចារ្យ បងប្រុស បងស្រី រួមជាមួយគណៈកម្មការនានានៅតាមបណ្តាព្រះសហគមន៍ទាំងនោះផង»។

លោកមានមុខងារ ជាអ្នកប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងប្រារព្ធពិធីអគ្គសញ្ញានានា។ លោកក៏មានបន្ទុកថែបំប៉នខាងផ្លូវវិញ្ញាណ និងការបង្រួបបង្រួមគ្រីស្តបរិស័ទឱ្យរួបរួមជាធ្លុងតែមួយ នៅតាមបណ្តាព្រះសហគមន៍ដែលលោកទទួលបន្ទុក។

នៅក្នុងលិខិតនេះលោកអភិបាលក៏បានកំណត់កិច្ចការជាអាទិភាពសម្រាប់លោក សែ សាត គឺការអប់រំជំនឿកុមារ យុវជន និងមនុស្សពេញវ័យ។ លោកក៏ត្រូវយកចិត្តទុកដាក់ចំពោះអ្នករងការឈឺចាប់ទាំងខាងរូបកាយ ទាំងខាងផ្លូវចិត្តផងដែរ។ លោកត្រូវជួយជំរុញគ្រីស្តបរិស័ទឱ្យមានគំនិត ការយល់ដឹងអំពីការប្រកាសដំណឹងល្អ ដោយចិត្តខ្នះខ្នែង និងក្នុងសេចក្តីស្រឡាញ់។

ជាមួយគ្នានេះ លិខិតដដែលបានបន្ថែមថា អនុញ្ញាតឱ្យលោកមានសិទ្ធិប្រារព្ធអគ្គសញ្ញាលើកលែងទោសរំដោះបាបឱ្យគ្រីស្តបរិស័ទ នៅក្នុងភូមិភាគកំពង់ចាម លើកលែងតែករណីបាបធ្ងន់ដែល

# សម្តេចប៉ាបចុះហត្ថលេខាលើសេចក្តីអំពាវនាវ នាទីក្រុងរ៉ូមឆ្នាំ ២០២០ ដើម្បីសន្តិភាព

*អត្ថបទ៖ បរទេស*

ការអំពាវនាវដើម្បីសន្តិភាពជាសាកលមួយត្រូវបានចុះហត្ថលេខានៅទីក្រុងរ៉ូមដោយសម្តេចប៉ាបហ្វ្រង់ស៊ីស្វ និងបណ្តាមេដឹកនាំសាសនានានាលើពិភពលោកដែលបានមកជួបជុំគ្នានៅកិច្ចប្រជុំអធិដ្ឋានអន្តរជាតិដើម្បីសន្តិភាព ក្រោមប្រធានបទ «គ្មាននរណាម្នាក់ត្រូវបានសង្គ្រោះតែឯង -សន្តិភាព និងភាតរភាព»។

វ៉ាទីកង់ញូវបានរាយការណ៍ថា ការចុះហត្ថលេខានេះ គឺត្រូវបានធ្វើដោយបណ្តាមេដឹកនាំសាសនាធំៗ ក្រោមកិច្ចប្រជុំដែលរៀបចំឡើងកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ដោយក្រុមបព្វជិតា អេជីឌីអូ (Egidio)។

បណ្តាមេដឹកនាំសាសនានានា បានអំពាវនាវឱ្យគ្រប់គ្នាចងចាំពីស្នាមរបួសរបស់មនុស្សជាតិ ហើយគួរតែរួបរួមគ្នាដើម្បីសន្តិភាព។



*លោកអភិបាល អូលីវីយេ ផ្មិតហស្លេរ មានប្រសាសន៍ និងលើកទឹកចិត្តដល់គ្រូអប់រំជំនឿក្នុងឱកាសបានបើកសកម្មភាពអប់រំជំនឿកាតូលិកឡើងវិញ។ **រូបភាព៖ ស៊ីអេសស៊ី***

បណ្តាមេដឹកនាំសាសនាទាំងអស់នោះ បានលើកឡើងថា សព្វថ្ងៃនេះពិភពលោកគឺកំពុងតែស្ថិតនៅក្នុងគ្រាលំបាកសព្វយ៉ាង ដោយរួមទាំងការតស៊ូជំនះនឹងរោគរាតត្បាតកូវីដ១៩ និងបញ្ហាជាច្រើនដែលគំរាមកំហែងដល់សន្តិភាព ហើយកំពុងតែធ្វើឱ្យសង្គមពោរពេញទៅដោយវិសមភាព និងការភ័យខ្លាចកាន់តែធ្ងន់ធ្ងរ។ ដូច្នេះមេដឹកនាំសាសនាទាំងអស់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ បានបញ្ជាក់នូវជំហរយ៉ាងម៉ឺងម៉ាត់ថា គ្មាននរណាម្នាក់អាចត្រូវបានសង្គ្រោះតែម្នាក់ឯងបានទេ គឺត្រូវតែសង្គ្រោះជាសហគមន៍។

សង្គ្រាម និងសន្តិភាព ជំងឺរាតត្បាត និងការថែរក្សាសុខភាពភាព អត់ឃ្លាន និងការទទួលបានស្បៀងអាហារ ការកើនឡើងកម្តៅពិភពលោក និងការអភិវឌ្ឍប្រកបដោយចីរភាព ការផ្លាស់ទីលំនៅរបស់ប្រជាជន ការលុបបំបាត់ ការគំរាមកំហែងនុយក្លេអ៊ែរ និងការកាត់បន្ថយវិសមភាព ទាំងនេះមិនមែនជាបញ្ហារបស់ប្រទេសនីមួយៗតែម្នាក់ឯងនោះទេ។ សព្វថ្ងៃនេះយើងយល់ពីបញ្ហានេះកាន់តែប្រសើរនៅក្នុងពិភពលោកដែលមានទំនាក់ទំនងគ្នាយ៉ាងល្អប្រសើរ តែជាញឹកញាប់ខ្វះនូវអារម្មណ៍ភាតរភាព៕

# អត្ថន័យថ្ងៃអាទិត្យនៃបេសកកម្មពិភពលោក
# WORLD MISSION SUNDAY



*អត្ថបទ៖ Fr. Roueng Chatsirey*

*នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ ជាអាទិត្យទី៣ក្នុងខែតុលា ជាថ្ងៃអាទិត្យនៃបេសកកម្មពិភពលោក (World Mission Sunday) តើថ្ងៃនោះជាថ្ងៃអ្វី?*

អត្ថន័យនៃថ្ងៃអាទិត្យបេសកកម្ម (World Mission Sunday)៖ នៅឆ្នាំ១៩២៦ សម្ដេចប៉ាបពីយ៉ូសទី ១១ បានបង្កើតថ្ងៃអាទិត្យបេសកកម្មសម្រាប់ព្រះសហគមន៍ទាំងមូល ដើម្បីប្រមូលវិភាគទាន ដែលចាប់ផ្ដើមនៅខែតុលា ឆ្នាំ១៩២៧។ នៅថ្ងៃនេះ ជាការប្រារព្ធពិធីបុណ្យ សម្រាប់ព្រះសហគមន៍មូលដ្ឋានទូទាំងពិភពលោក ដើម្បីបញ្ជាក់លក្ខណៈជាកាតូលិកនិងភាតរភាពសាកល។ នៅថ្ងៃនេះ ជាការរំលឹកគ្រីស្តបរិស័ទកាតូលិកទាំងអស់ ឱ្យយកចិត្តទុកដាក់និងទទួលខុសត្រូវ កិច្ចការប្រកាសដំណឹងល្អនៅទូទាំងពិភពលោក និងបង្ហាញសេចក្ដីស្រឡាញ់ចំពោះគ្រួសារកាតូលិកសកល។

កិច្ចការដែលគ្រីស្តបរិស័ទត្រូវចូលរួមគឺការចូលជាវិភាគទានដើម្បីគាំទ្របេសកកម្មរបស់ព្រះសហគមន៍ សកល ដូចជាកិច្ចការខាងមន្ទីរពេទ្យ សាលារៀន ឬការត្រាស់ហៅ ជាពិសេសសម្រាប់ប្រទេសដែលព្រះសហគមន៍នៅក្មេងខ្ចីនិងក្រីក្រ។



*លោកបូជាចារ្យ រឿន ឆត្រ័សិរី ជាបូជាចារ្យមានទំនួលខុសត្រូវព្រះសហគមន៍ផ្សារតូច នៃមណ្ឌលសកម្មភាពភ្នំពេញខាងជើងនៃភូមិភាគភ្នំពេញ។ **រូបភាព៖ ស៊ីអេសស៊ី***

ឆ្នាំនេះ ខ្ញុំសូមផ្ញើលិខិតមួយជូនបងប្អូន ដោយសង្ខេបសមណលិខិតសម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ នៅថ្ងៃបេសកកម្ម ឆ្នាំ ២០២០ នេះ ដើម្បីជួយយើងរិះគិតគឺ៖ ឆ្នាំ២០២០នេះ សម្ដេចប៉ាបបានផ្ញើលិខិតថ្ងៃអាទិត្យនៃបេសកកម្មពិភពលោក ដោយយកព្រះបន្ទូល "ទូលបង្គំនៅទីនេះស្រាប់ហើយ! សូមព្រះអង្គចាត់ទូលបង្គំចុះ!"(អស ៦,៨)។ សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ ឱ្យយើង ជាគ្រីស្តបរិស័ទយកចិត្តទុកដាក់លើបេសកកម្មរបស់ខ្លួន ទោះបីមានបញ្ហាជំងឺកូវីដ តែយើងដូចនៅក្នុងទូកតែមួយត្រូវជួយគ្នា និងលើកទឹកចិត្តគ្នា។

សូមឱ្យយើងសម្លឹងមើលការបូជាព្រះជន្មរបស់ព្រះយេស៊ូនៅលើឈើឆ្កាង។ ព្រះអង្គចង់ឱ្យសេចក្ដីស្រឡាញ់របស់ព្រះអង្គពេញបរិបូរណ៍ ដោយចាត់យើងឱ្យទៅ ដូចព្រះយេស៊ូជាទូតរបស់ព្រះបិតា។ បេសកកម្មនេះ មិនគ្រាន់តែជាគម្រោងការរបស់យើង តែជាបេសកកម្មដែលព្រះយេស៊ូប្រទានឱ្យយើង ដោយមានព្រះវិញ្ញាណជួយជម្រុញគាំទ្រយើង។ យើងត្រូវដឹងខ្លួនថា ការប្រកាសដំណឹងល្អ គឺជាការត្រាស់ហៅនៃការប្រកាសសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើងដែរ មិនថាមានគ្រួសារ ឬនៅលីវ ដើម្បីព្រះរាជ្យរបស់ព្រះជាម្ចាស់។

សម្ដេចប៉ាបឱ្យយើងមានទំនាក់ទំនងផ្ទាល់ជាមួយព្រះយេស៊ូ ផ្ចង់ចិត្តស្ដាប់សំឡេងរបស់ព្រះអង្គ ហើយ ឆ្លើយតប ដោយចេញទៅគ្រប់ទីកន្លែង ដើម្បីជាសាក្សីនៃជំនឿរបស់យើង ដូច្នេះយើងត្រូវបើកចិត្តរបស់យើង ដូចព្រះនាងម៉ារី (យោង លក ១,៣៨)។

សម្ដេចប៉ាបឱ្យយើងមើលជនក្រីក្រ ជនរងគ្រោះក្នុងសង្គម។ ការអធិដ្ឋាន ជួយឱ្យយើងបើកចិត្តសម្រាប់ ពួកគាត់។ សុំពិចារណាសំណួរព្រះជាម្ចាស់ "តើយើងនឹងចាត់នរណាឱ្យទៅ?" ព្រះអង្គកំពុងស្វែងរកមនុស្ស ដែលមានចិត្តសប្បុរស និងធ្វើជាសាក្សីនៃសេចក្ដីស្រឡាញ់របស់ព្រះអង្គ។

ក្នុងទិវាបេសកកម្មនេះ កិច្ចការដែលបងប្អូនធ្វើបានគឺ ការអធិដ្ឋាន ការរិះគិតព្រះបន្ទូលថ្ងៃនេះនឹងជីវិតយើង និងការជួយជាវិភាគទានដល់បេសកកម្មរបស់ព្រះសហគមន៍។ ជាពិសេសវិភាគទាន នៅថ្ងៃអាទិត្យទី៣ នៃខែតុលានេះ តាមរយៈកិច្ចការ "សមាគមរបស់សន្តអាសនៈដើម្បីកិច្ចការសាសនទូត"(PMS) សមាគមនេះនឹងជាឧបករណ៍ ដែលសម្ដេចប៉ាបអាចឆ្លើយតបបេសកកម្មទាំងនេះបាន ទាំងខាងផ្លូវកាយ និងផ្លូវវិញ្ញាណ។

*សូមព្រះនាងម៉ារី ដែលជាសាសនទូតនិងសាវិការបស់ព្រះយេស៊ូដែរ ជួយអង្វរព្រះជាអម្ចាស់ដើម្បីបងប្អូនទាំងអស់គ្នា!*









*សកម្មភាពគណៈកម្មការនិងគ្រីស្តបរិស័ទនៃព្រះសហគមន៍មណ្ឌលគិរីជួបជុំគ្នារិះគិតអំពី ផែនការសកម្មភាពសម្រាប់ឆ្នាំ២០២១។ **រូបភាព៖ ព្រះសហគមន៍មណ្ឌលគិរី***

# ព្រះសហគមន៍មណ្ឌលគិរី លើកផែនការធំៗសម្រាប់ឆ្នាំ២០២១

*អត្ថបទ៖ ស៊ីអេសស៊ី*

គណៈកម្មការនិងគ្រីស្តបរិស័ទនៃព្រះសហគមន៍មណ្ឌលគិរី បានជួបជុំគ្នារិះគិតអំពី ផែនការសកម្មភាពសម្រាប់ឆ្នាំ២០២១ខាងមុខនេះ នៅខេត្តរតនគិរី ដែលដឹកនាំដោយលោកបូជាចារ្យហ្វ្រង់ស្វ័រ អេមេដាល្ស និងលោកបូជាចារ្យផាន បូរី ដែលធ្វើឡើងកាលពីថ្ងៃទី២០-២២ ខែតុលា ឆ្នាំ២០២០។

លោកបូជាចារ្យហ្វ្រង់ស្វ័រ អ្នកទទួលខុសត្រូវព្រះសហគមន៍មណ្ឌលគិរីមានប្រសាសន៍ថា យើងរិះគិតអំពី ទិសដៅព្រះសហគមន៍ ដូចជាបុណ្យព្រះយេស៊ូប្រសូត ការអប់រំនៅសាលានិងមណ្ឌល ការសាងសង់ព្រះវិហារថ្មី ការផ្សព្វផ្សាយអំពីព្រះសហគមន៍លើបណ្ដាញសង្គម និងអំពីប្រាក់ជង្វាយ។

លោកមានប្រសាសន៍ថា៖«ព្រះសហគមន៍តែងគិតថា លោកពុក (បូជាចារ្យ) សំខាន់ តែលោកពុកមិនអាចធ្វើការតែម្នាក់ឯងទេ គឺត្រូវការគ្រីស្តបរិស័ទជួយ»។



*សកម្មភាពគណៈកម្មការនិងគ្រីស្តបរិស័ទនៃព្រះសហគមន៍មណ្ឌលគិរីជួបជុំគ្នារិះគិតអំពី ផែនការសកម្មភាពសម្រាប់ឆ្នាំ២០២១។ **រូបភាព៖ ព្រះសហគមន៍មណ្ឌលគិរី***

លោកបូជាចារ្យពន្យល់ថា បុណ្យព្រះយេស៊ូប្រសូតនាពេលខាងមុខនេះ យើងនឹងធ្វើនៅតាមព្រះសហគមន៍នីមួយៗតាមវេនរៀងៗខ្លួន គឺចាប់ពីថ្ងៃទី២៣ទៅ។ រីឯការអប់រំព្រះសហគមន៍យើងមានកម្រិតពី មត្តេយ្យសិក្សា មណ្ឌលយុវជនស្រីនិងប្រុសដែលកំពុងរៀននៅអនុវិទ្យាល័យនិងវិទ្យាល័យ និងរៀនបំប៉នតាមភូមិ ដោយព្រះសហគមន៍បានជួលគ្រូបង្រៀនម្នាក់នៅតាមព្រះសហគមន៍ (ប៊ូស្រា



និងដាក់ដាំ) បង្រៀនពីថ្នាក់ទី១-៥ ។ ម្យ៉ាងវិញទៀតក្នុងឆ្នាំថ្មីនេះ ដោយសារព្រះសហគមន៍មានគ្រីស្តបរិស័ទកាន់តែច្រើនឡើង គឺនៅប៊ូស្រាចំនួន១០០នាក់ និងកែវសីម៉ាចំនួន១០០នាក់ យើងនឹងសង់ព្រះវិហារថ្មី។ លោកបូជាចារ្យសង្កត់ធ្ងន់ថា យើងកំពុងសិក្សាលើគម្រោងនេះ មិនទាន់ដឹងច្បាស់ថានឹងរួចរាល់ពេលណាទេ។

ចំណុចចុងក្រោយដែលបានលើកឡើងក្នុងកិច្ចប្រជុំប្រចាំឆ្នាំនោះ គឺប្រាក់ជង្វាយសម្រាប់ជួយអ្នកក្រីក្រនិងអ្នកជំងឺ ជាកិច្ចការដែលព្រះសហគមន៍តែងជម្រុញឱ្យគ្រីស្តបរិស័ទចូលរួមក្នុងការសម្ដែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។

ក្នុងកម្មវិធីនេះ ក៏មានការអធិដ្ឋាន រិះគិតអំពីព្រះបន្ទូលនិងដំណើរកំសាន្តជាក្រុមផងដែរ៕





*ក្រោយកិច្ចប្រជុំលើកផែនការធំៗសម្រាប់ឆ្នាំ២០២១ ក៏មានដំណើរកំសាន្តជាក្រុមផងដែរ។ **រូបភាព៖ ព្រះសហគមន៍មណ្ឌលគិរី***



*ដីនិងផ្ទះដើម្បីរៀបចំធ្វើជាព្រះសហគមន៍និងវិហារ។ **ព្រះសហគមន៍មណ្ឌលគិរី***

## ព្រះសហគមន៍មណ្ឌលគិរីពង្រីកសកម្មភាពដល់កោះញែក

នៅក្នុងតំបន់កោះញែក មានគ្រីស្តបរិស័ទម្នាក់កំពុងរស់នៅទីនោះ ហើយភាគច្រើនប្រជាជនខ្មែរមួយចំនួនចង់ឈ្វេងយល់អំពីព្រះយេស៊ូផងនោះ លោកបូជាចារ្យហ្វ្រង់ស្វ័រ បានរិះគិតជាមួយគណៈកម្មការព្រះសហគមន៍ទិញដីនិងផ្ទះមួយ ដើម្បីរៀបចំធ្វើជាព្រះសហគមន៍និងវិហារ។ ដែលព្រះសហគមន៍នេះ នឹងស្ថិតនៅក្នុងភូមិអូរយ៉េះ ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី នឹងមានមណ្ឌលនិងព្រះវិហារ។

លោកបូជាចារ្យហ្វ្រង់ស្វ័រអេមេដាល្ស ជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍តំបន់មណ្ឌលគិរី មានប្រសាសន៍ថា នៅតំបន់កោះញែកនេះ «មានបងប្អូននៅតាមភូមិ គេចង់ក្លាយគ្រីស្តបរិស័ទ ហើយនៅទីនេះមានគ្រីស្តបរិស័ទម្នាក់ជានាយករងវិទ្យាល័យនៅកោះញែក»។ លោកបូជាចារ្យសង្ឃឹមថា ច្បាប់អនុញ្ញាតឱ្យបើកព្រះវិហារនឹងមានក្នុងខែមករាឆ្នាំ២០២១ខាងមុខនេះ៕



# ព្រះសហគមន៍ភូមិភាគភ្នំពេញ យកចិត្តទុកដាក់លើសិល្បៈ




*ការិយាល័យសិល្បៈនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រៀបចំសិក្ខាសាលាស្ដីអំពី សិល្បៈ និងតន្ត្រី នៅភូមិចំការទៀង ក្នុងព្រះវិហារសន្តីម៉ារីញញឹម។ **រូបភាព៖ ស៊ីអេសស៊ី***

*អត្ថបទ៖ ស៊ីអេសស៊ី*

ការិយាល័យសិល្បៈនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រៀបចំសិក្ខាសាលាស្ដីអំពី សិល្បៈ និងតន្ត្រី រយៈពេល៤ថ្ងៃ គិតចាប់ពីថ្ងៃទី២៩ តុលា ដល់ថ្ងៃ១ វិច្ឆិកា ២០២០ ដើម្បីជួយលើកកម្ពស់វប្បធម៌ខ្មែរនៅតាមព្រះសហគមន៍ និងអាចប្រកាសដំណឹងល្អតាមរយៈសិល្បៈ។

អង្គសិក្ខាសាលានេះ ប្រព្រឹត្តទៅនៅភូមិចំការទៀង ក្នុងព្រះវិហារសន្តីម៉ារីញញឹម នៃមណ្ឌលសកម្មភាពតាកែវ ដោយមានសិក្ខាកាមសរុបចំនួន៦៧នាក់ មកពីមណ្ឌលសកម្មភាពទាំង ៩ នៃព្រះសហគមន៍ភូមិភាគភ្នំពេញ។

ក្នុងឱកាសនេះដែរ លោកអូលីវីយេ ជ្មិតហស្លេរ៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍នៅក្នុងពិធីបិទសិក្ខាសាលានេះថា សូមឱ្យសិក្ខាកាមទាំងអស់ឱ្យយកចិត្តទុកដាក់ប្រកាសដំណឹងល្អតាមរយៈសិល្បៈ ព្រោះសិល្បៈបានចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តប្រជាជនខ្មែរ។

ក្នុងនោះ លោកអភិបាលបានណែនាំ២ចំណុចដល់សិក្ខាកាម និងគ្រីស្តបរិស័ទទាំងអស់ ឱ្យចេះទទួលយកសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ និងចែករំលែកដល់បងប្អូនឯទៀតៗឱ្យដូចទុយោបង្ហូរទឹក ហើយចេះរស់នៅក្នុងសេចក្ដីសង្ឃឹម ដោយជម្រះចិត្តគំនិតរបស់ខ្លួនដោយយកព្រះគ្រីស្តជាគំរូ និងរស់នៅដោយស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូបានស្រឡាញ់មនុស្សលោក។

លោក អ៊ុំ សាមាន ជាប្រធានការិយាល័យសិល្បៈភូមិភាគភ្នំពេញ បានឱ្យដឹងថា ទិសដៅនៃការធ្វើសិក្ខាសាលាសិល្បៈនេះគឺ ចង់ឱ្យព្រះសហគមន៍ទាំងអស់នៅភូមិភាគភ្នំពេញ ជាពិសេសគឺក្រុមយុវជនចេះរបាំបុរាណប្រពៃណី និងយីកេ។

លោកបញ្ជាក់ថា យើងសម្រេចជ្រើសរើសយីកេមកបង្ហាត់ រីឯរបាំប្រជាប្រិយ៍ យើងបានលើកយករបាំនេសាទមកបង្ហាត់ ហើយរបាំបុរាណយើងមានរបាំជូនពរ និងចុងក្រោយគឺរបាំឱ!ដួងចន្ទ។ លោកសាមានបន្ថែមថា ដោយសារនៅក្នុងឆ្នាំនេះទាំងព្រះសហគមន៍ និងក្រសួងសិល្បៈផ្ដោតទៅលើល្ខោនយីកេ។

លោកសង្ឃឹមថាសិក្ខាកាមនឹងអាចបង្រៀនបន្តនូវចំណេះដឹងនេះដល់យុវជនដទៃទៀត និងសង្ឃឹមថាគ្រប់សកម្មភាពដែលបានធ្វើ នឹងជួយពួកគាត់ឱ្យចេះនិងចាំគ្រប់ក្បាច់បាត ក្បាច់ធំៗ ជាពិសេសអាចបំបែកក្បាច់បន្ថែម តាមអ្វីដែលពួកគាត់ចង់សម្ដែង ដូចជារឿងព្រះយេស៊ូប្រសូតជាដើម។

លោកក៏សូមអរគុណយ៉ាងជ្រាលជ្រៅដល់លោកអភិបាលអូលីវីយេ ដែលតែងតែយកចិត្តទុកដាក់ក្នុងការបង្កើតឱ្យមានសិក្ខាសាលានេះ និងជំរុញឱ្យមានការថែរក្សាសម្បត្តិវប្បធម៌របស់ខ្មែរ ជាពិសេសយើងអាចបង្ហាញសេចក្ដីស្រឡាញ់ និងប្រកាសដំណឹងល្អតាមរយៈសិល្បៈផងដែរ៕

# កញ្ញា ឆាន ស្រីអែម៖ «ខ្ញុំស្រលាញ់មហាគ្រួសារនេះណាស់»

*អត្ថបទ៖ ឆាក លាំង*

«ខ្ញុំមានអំណរសប្បាយ ហើយខ្ញុំស្រលាញ់មហាគ្រួសារនេះណាស់» នេះគឺជាសម្ដីរបស់កញ្ញា ឆាន ស្រីអែម ជាកូនស្រីទីមួយ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៩នាក់ មានស្រុកកំណើតនៅ ភូមិក្ដុលលើ ស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ។

កញ្ញា ស្រីអែម បានស្គាល់ព្រះសហគមន៍កាតូលិកតាំងពីនៅតូច ក្នុងតំបន់ដែលនាងរស់នៅ គឺតាមរយៈលោកបូជាចារ្យ និងបងស្រី ក្នុងសកម្មភាពការងារមនុស្សធម៌ ក៏ដូចជាកម្មវិធីអធិដ្ឋាន ហាត់របាំ និងកម្មវិធីកុមារផ្សេងៗដែលព្រះសហគមន៍បានបង្កើតឡើង។

កញ្ញា ស្រីអែម បានប្រាប់ថា ៖ «សកម្មភាពរបស់ព្រះសហគមន៍ ធ្វើឱ្យខ្ញុំចង់រស់នៅក្នុងជីវិតជាគ្រីស្តបរិស័ទ»។

បច្ចុប្បន្ន គ្រីស្តបរិស័ទរូបនេះ កំពុងបំពេញការងារជាគ្រូសាលាមតេយ្យរបស់ព្រះសហគមន៍មួយកន្លែងក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើង នាភូមិភាគភ្នំពេញ។ កញ្ញាបានទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំ២០០០នៅព្រះសហគមន៍ក្ដុលលើ ភូមិភាគកំពង់ចាម។ ក្រោយពីទទួលអគ្គសញ្ញាជ្រមុជទឹក បានធ្វើឱ្យកញ្ញាមានអំណរសប្បាយ។

កញ្ញាបានបន្ថឺឡើងថា ៖ «យើងរីករាយក្នុងការជួយគ្នាទៅវិញទៅមក ហើយខ្ញុំស្រលាញ់មហាគ្រួសារនេះណាស់»។

កញ្ញា ស្រីអែម បានរៀបរាប់ប្រាប់ក្រុមការងាររបស់កម្មវិធីវិទ្យុ វើរីតាស អាស៊ី តាមសារអេឡិចត្រូនិចថា ក្នុងជីវិតជាគ្រីស្តបរិស័ទរយៈពេលប៉ុន្មានឆ្នាំមកនេះ គឺបានជួបរឿងលំបាកជាច្រើន តែព្រះបន្ទូលជួយបំភ្លឺ និងធ្វើឱ្យគ្រប់យ៉ាងបានប្រសើរឡើងវិញ។ នាងថា អ្នកផ្សេងមិនចូលចិត្តនាង ដោយសារតែនាងមានជំនឿខុសពីគេ ដោយគេបាននិយាយឱ្យនាងថា នាងមិនចេះគោរពឪពុកម្ដាយជាដើម។

ជីវិតជាគ្រីស្តបរិស័ទ កញ្ញា ស្រីអែម បានគូសបញ្ជាក់យ៉ាងម៉ុតមាំថា៖ «សព្វថ្ងៃនេះខ្ញុំរស់ក្នុងសេចក្ដីអំណរជាមួយបងប្អូនផ្សេងៗទៀត ទោះជាមានជំនឿខុសគ្នាក៏ដោយ។ ហើយថ្ងៃអនាគតខ្ញុំនឹងចូលរួមប្រកាសដំណឹងល្អទៅមនុស្សដែលមិនបានស្គាល់ព្រះយេស៊ូ»៕

# អ្នកគ្រូ ចែម ផល្លា៖ «ខ្ញុំចង់ចូលរួមប្រកាសដំណឹងល្អទៅមនុស្សទូទៅ»

*អត្ថបទ៖ ឆាក លាំង*

នេះគឺជាសម្ដីរបស់កញ្ញា ចែម ផល្លា ជាកូនស្រីទីមួយ ក្នុងចំណោមបងប្អូនប្រុសស្រី៣នាក់ នៃគ្រួសារគ្រីស្តបរិស័ទមួយរស់នៅភូមិព្រៃកប្រស់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

កញ្ញា ផល្លា គឺជាកូនស្រីអ្នកនេសាទម្នាក់ក្នុងភូមិឃុំខាងលើ ដែលកញ្ញាបានស្គាល់ព្រះសហគមន៍កាតូលិកក្នុងអំឡុងឆ្នាំ២០០៤ តាមរយៈឪពុករបស់នាង។ ដោយកិច្ចការមនុស្សធម៌របស់ព្រះសហគមន៍បានជួយយកម្ដាយរបស់គាត់ទៅព្យាបាល ពេលមានជំងឺឱ្យបានជាសះស្បើយ តាំងពីពេលនោះមក គ្រួសារទាំងមូលបានចាប់អារម្មណ៍ និងមានជំនឿលើសាសនាកាតូលិក។

កញ្ញា ចែម ផល្លា បានឱ្យដឹងថា ៖ «កិច្ចការមនុស្សធម៌របស់ព្រះសហគមន៍បានធ្វើឱ្យខ្ញុំសម្រេចចិត្តផ្លាស់ប្ដូរជំនឿ»។

គ្រីស្តបរិស័ទវ័យ៣៦ឆ្នាំរូបនេះដែលសព្វថ្ងៃកញ្ញាកំពុងតែបំពេញការងារជាគ្រូមតេយ្យរបស់ព្រះសហគមន៍កាតូលិកមួយកន្លែងក្នុងមណ្ឌលសកម្មភាពព្រះសីហនុបានបន្តថា ខ្លួនបានសិក្សាស្វែងយល់អំពីដំណើរជីវិតរបស់ព្រះយេស៊ូ តាមរយៈលោកបូជាចារ្យ បងប្រុសបងស្រី គ្រីស្តបរិស័ទចាស់ៗ និងក្រុមគ្រូអប់រំជំនឿជាច្រើនឆ្នាំ។

ព្រះបន្ទូលជួយបំភ្លឺជារៀងរាល់ថ្ងៃ ធ្វើឱ្យជំនឿរីកធំធាត់បន្តិចម្ដងៗ ហើយក៏បានទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំ២០១១ នៅព្រះវិហារសន្តសិលព្រៃកប្រស់។ ក្រោយពីទទួលអគ្គសញ្ញាជ្រមុជទឹក ធ្វើឱ្យជីវិតមានការផ្លាស់ប្ដូរ «ខ្ញុំមានសេចក្ដីក្លាហានជាងមុន ចេះជួយអ្នកដទៃ និងចេះចូលរួមក្នុងកិច្ចសង្គមជាដើម»។

កញ្ញា ចែម ផល្លា បានរស់នៅក្នុងជីវិតជាគ្រីស្តបរិស័ទ ដែលតែងតែមានព្រះបន្ទូលរបស់ជាម្ចាស់ជួយបំភ្លឺ និងមានទំនាក់ទំនងល្អជាមួយមនុស្សនៅជុំវិញខ្លួន។ អ្នកគ្រូ ផល្លា បានរៀបរាប់ប្រាប់ក្រុមការងារវិទ្យុវើរីតាសអាស៊ីថា ក្នុងជីវិតជាគ្រីស្តបរិស័ទកន្លងមកបានជួបការលំបាកខ្លះៗដែរ ដោយត្រូវគេមើលងាយគេរើសអើង តែកញ្ញាមិនដែលចាប់អារម្មណ៍នោះទេ ព្រោះក្នុងព្រះគម្ពីរបានកត់ត្រា អំពីព្យាការីផ្សេងៗ ដែលត្រូវគេបៀតបៀន ដោយសារតែជឿលើព្រះយេស៊ូ។

កញ្ញា ចែម ផល្លា បានគូសបញ្ជាក់យ៉ាងមុតមាំថា សម្រាប់គោលដៅរបស់ខ្លួននាពេលអនាគត គឺចង់ចូលរួមប្រកាសដំណឹងល្អទៅបងប្អូននៅជុំវិញខ្លួន ឱ្យបានស្គាល់ពីព្រះជាម្ចាស់ ដើម្បីឱ្យពួកគាត់បានចូលរួមកសាងព្រះសហគមន៍ឱ្យមានការរីកចំរើន និងរស់រវើក៕





# អង្គការការីតាសកម្ពុជាបានប្រគល់សម្ភារៈចាំបាច់ ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

*អត្ថបទ៖ ស៊ីអេសស៊ី*

អង្គការការីតាសកម្ពុជាបានប្រគល់នូវសម្ភារៈចាំបាច់មួយចំនួនដល់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នាថ្ងៃអង្គារ ទី១៣ ខែតុលា ឆ្នាំ២០២០ ក្នុងខេត្តពោធិ៍សាត់។

ពិធីប្រគល់-ទទួលនេះត្រូវបានធ្វើឡើងក្រោមអធិបតីភាពរបស់ លោក គន់ គីម អនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ លោក ម៉ៅ ធនិន អភិបាលខេត្តពោធិ៍សាត់ លោក គីម រតនា ប្រធានអង្គការការីតាសកម្ពុជា និងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀត។



*លោក គន់ គីម និងតំណាងអង្គការការីតាសកម្ពុជា នៅក្នុងពិធីប្រគល់-ទទួលសម្ភារៈចាំបាច់ទប់ទល់គ្រោះទឹកជំនន់។ **ព្រះសហគមន៍***

លោក គន់ គីម បានមានប្រសាសន៍នៅក្នុងឱកាសប្រគល់-ទទួលសម្ភារៈនេះថា អង្គការការីតាសបានផ្ដល់នូវសម្ភារៈចាំបាច់ដល់គណៈកម្មាធិការជាតិនូវ ទូកចំនួន២០គ្រឿង ដែលទូកនេះជិះបាន៤នាក់ ៦នាក់ ៨នាក់ និងជិះបាន១០នាក់ដែលជាទូកចាំបាច់សម្រាប់ជួយប្រជាជនរងគ្រោះ។

លោកបានថ្លែងបន្ថែមថា ៖ «ក្រៅពីការផ្ដល់ជូននូវទូកនេះហើយ អង្គការការីតាសក៏បានឧបត្ថម្ភបន្ថែមនូវ តង់ចំនួន៥០០តង់ មុងចំនួន៥០០មុង ភួយចំនួន៥០០ភួយ សម្រាប់ផ្ដល់ជូនប្រជាពលរដ្ឋដែលឡើងមកលើទីទួលសុវត្ថិភាព។ អង្គការការីតាស និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយតែងតែធ្វើកិច្ចព្រមព្រៀងគ្នាសម្រាប់ការជួយដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់ក្ដី ឬមហន្តរាយដោយធម្មជាតិក្ដី ខាងអង្គការនេះតែងតែបានជួយឧបត្ថម្ភគាំទ្រជារៀងរហូតមក»។



លោក គន់ គីម បានបញ្ជាក់ទៀតថា អង្គការការីតាសតែងតែបានជួយទៅដល់គ្រប់២៥ខេត្ត-ក្រុងនូវសម្ភារៈសង្គ្រោះនូវសម្ភារៈចាំបាច់ដូចជាភួយ មុង តង់ ពោង និងទូកជាដើម សម្រាប់ជួយដោះស្រាយនូវការលំបាក ហើយក្រៅពីនេះក៏មាននូវស្បៀងអាហារផងដែរ។

លោកបានថ្លែងថា ៖ «ខ្ញុំចាំនូវកិច្ចការរបស់អង្គការនេះគឺពួកគាត់បានចូលរួមជួយក្នុងកិច្ចការងារសង្គ្រោះប្រជាជនច្រើនមែនទែន។ ក្នុងនាមសម្ដេចតេជោនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ខ្ញុំក៏សូមសម្ដែងនូវការអរគុណចំពោះអង្គការការីតាសដែលជានិច្ចកាលតែងតែបានជួយប្រជាជននៅទូទាំងប្រទេស នូវអ្វីដែលជាការខ្វះខាតចាំបាច់បន្ទាន់ៗ គឺក្រុមអង្គការនេះចុះមកផ្ទាល់ដើម្បីធ្វើការដោះស្រាយជូនដល់ប្រជាជនទៀតផង»។

អនុប្រធានទី១នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយរូបនេះបានសម្ដែងនូវការគោរព ថ្លែងអំណរគុណ និងកោតសរសើរចំពោះទឹកចិត្ត និងការខិតខំរបស់អង្គការការីតាសក្នុងការរួមសហការជាមួយនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដើម្បីដោះស្រាយនូវកង្វល់ប្រជាពលរដ្ឋនៅតាមបណ្ដាមូលដ្ឋាន។

ចំពោះសម្ភារៈដែលទទួលបាននេះ លោក គន់ គីម នឹងធ្វើការចែកជូនពាក់កណ្ដាលទៅខេត្តបន្ទាយមានជ័យ។ មានន័យថា មុងចំនួន២៥០មុង ភួយចំនួន២៥០ភួយ និងតង់ចំនួន២៥០តង់នឹងត្រូវបានផ្ដល់ទៅចែកបន្តដល់ប្រជាពលរដ្ឋកំពុងរងគ្រោះក្នុងខេត្តបន្ទាយមានជ័យ ដោយសារខេត្តបន្ទាយមានជ័យទឹកកំពុងជន់ខ្លាំងហើយមិនដឹងថាថ្ងៃណាស្រក។

លោកក៏បានមានប្រសាសន៍ថា៖ «សម្ភារៈទាំងនេះនឹងផ្ដល់ជូនប្រជាពលរដ្ឋដែលកំពុងរស់នៅលើទីទួលសុវត្ថិភាព។ ក្រៅពីកិច្ចការងារនេះ ដូចជាថ្នាំពេទ្យ និងការការពារសុខភាព ខាងក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលខេត្ត-ស្រុក ឃុំបានរួមគ្នាធ្វើការដោះស្រាយក្នុងការព្យាបាលជូនប្រជាពលរដ្ឋហើយ»។

ក្នុងឱកាសនោះដែរ លោក គីម រតនា ក៏បានលើកឡើងផងដែរថា អង្គការការីតាមមានមោទនភាពក្នុងការចូលរួមជាមួយសកម្មភាពយ៉ាងសកម្មរបស់រាជរដ្ឋាភិបាលទាំងថ្នាក់ជាតិនិងខេត្តដើម្បីជួយដល់ប្រជាពលរដ្ឋដែលកំពុងរងគ្រោះ។

លោកបានថ្លែងថា ៖ «អង្គការការីតាស ក្នុងនាមជាដៃគូអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំបន្ថែមទៀតក្នុងការជួយសង្គ្រោះក្នុងគ្រោះមហន្តរាយ ទាំងការងារឆ្លើយតបគ្រប់គ្រងគ្រោះមហន្ត និងចូលរួមបន្តដើម្បីស្តារជីវភាព និងអភិវឌ្ឍន៍បន្តទៀត»។

លោក គីម រតនាបានបន្ថែមថា អង្គការការីតាសនឹងបន្តលទ្ធភាពដើម្បីសហការជាមួយនឹងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដើម្បីជួយដល់គ្រួសារអ្នករងគ្រោះដោយទឹកជំនន់ក្នុងតំណាក់កាលនេះហើយនិងតំណាក់កាលដែលទឹកស្រកវិញដើម្បីផ្សារភ្ជាប់នឹងការងាររបស់រាជរដ្ឋាភិបាល។

គួរបញ្ជាក់ផងដែរថា មកដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ មានខេត្តចំនួន១៩ខេត្តទទួលរងគ្រោះពីទឹកជំនន់ ដែលមានដូចជា ពោធិ៍សាត់ ប៉ៃលិន បន្ទាយមានជ័យ ភ្នំពេញ បាត់ដំបង ស្វាយរៀង ឧត្តរមានជ័យ សៀមរាប តាកែវ កំពង់ស្ពឺ មណ្ឌលគីរី ព្រះសីហនុ កោះកុង កណ្ដាល កំពង់ឆ្នាំង កំពង់ធំ ព្រះវិហារ ស្ទឹងត្រែង និងខេត្តកំពង់ចាម។

ក្នុងនោះ ប៉ះពាល់ស្រុកចំនួន៦០ និងឃុំ២០៤ឃុំ និងមានប្រជាពលរដ្ឋចំនួន៣៤,៣៧៨គ្រួសាររងការប៉ះពាល់ គ្រួសារចំនួន២២៦៨គ្រួសារត្រូវបានជម្លៀសមកទីទួលសុវត្ថិភាព និងមានអ្នកស្លាប់ចំនួន១១នាក់៕

# ព្រះសហគមន៍ផ្ដល់អំណោយ សម្រាប់គ្រោះទឹកជំនន់

*អត្ថបទ៖ ស៊ីអេសស៊ី*

ព្រះសហគមន៍កាតូលិកបាត់ដំបងក្រុង (ពេទ្យឃាយជី) បានចែកនូវគ្រឿងឧបភោគបរិភោគមួយចំនួនដល់បុគ្គលិក និងគណៈកម្មការព្រះសហគមន៍ ក្នុងអំឡុងពេលមានទឹកជំនន់ ដែលធ្វើឱ្យពួកគាត់ទាំងអស់គ្នារងនូវផលប៉ះពាល់មួយចំនួន។

កម្មវិធីនេះ បានធ្វើឡើងនៅក្នុងបរិវេនព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ក្នុងទីរួមខេត្តបាត់ដំបង កាលព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដឹកនាំដោយលោកបូជាចារ្យ ម៉ានុច និងមានការចូលរួមដោយលោកអភិបាលទេព ច័ន្ទពិសិដ្ឋ។

បុគ្គលិក និងគណៈកម្មការចំនួន៤០នាក់នៃព្រះសហគមន៍នេះ ក្នុងម្នាក់បានទទួលអង្ករចំនួន១ការ៉ុងទំងន់២០គីឡូក្រាម មីចំនួន១កេះតូច និងត្រីខកំប៉ុងចំនួន១យួរ ស្មើ១០កំប៉ុងផងដែរ។

ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានទទួលអំណោយពីអង្គការការីតាសកម្ពុជា នូវអង្ករ២០,០០០គីឡូក្រាម មីចំនួន១,០០០កេះ និងត្រីខកំប៉ុងចំនួន១,០០០យួរ សម្រាប់ចែកជូនដល់ព្រះសហគមន៍ក្នុងភូមិភាគ មណ្ឌលព្រះសហគមន៍ផ្សេងៗ បុគ្គលិករបស់ព្រះសហគមន៍ ព្រះសង្ឃ អ្នកជាប់ឃុំនៅពន្ធនាគារ និងគ្រួសារក្រីក្រនៅក្នុងភូមិភាគបាត់ដំបង ដែលកំពុងជួបនូវការខ្វះខាតស្បៀងអាហារដោយសារគ្រោះទឹកជំនន់៕



*លោកអភិបាលទេព ច័ន្ទពិសិដ្ឋ (ឆ្វេងទី២) ក្នុងការចែកគ្រឿងឧបភោគបរិភោគមួយចំនួនដល់បុគ្គលិក និងគណៈកម្មការព្រះសហគមន៍ ក្នុងអំឡុងពេលមានទឹកជំនន់។ **ព្រះសហគមន៍***





# អភិបាលភូមិភាគបាត់ដំបង អញ្ជើញសួរសុខទុក្ខ និងប្រគេនគ្រឿងបរិភោគដល់ប្រធានសាខា ពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ បាត់ដំបង





*អត្ថបទ៖ ព្រះសហគមន៍*

កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ ព្រះសហគមន៍កាតូលិកបាត់ដំបង ដឹកនាំដោយលោកអភិបាលទេព ច័ន្ទពិសិដ្ឋ (គីគេ) និងក្រុមការងារ បានអញ្ជើញទៅសួរសុខទុក្ខ និងនាំយកគ្រឿងឧបភោគបរិភោគមួយចំនួនដូចជា អង្ករ ត្រីខកំប៉ុង និងមីប្រគេនជូនដល់ប្រធានសាខា ពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជបាត់ដំបង (ពសសបប) ។

នៅក្នុងពិធីសំណេះសំណាលនាពេលនោះ លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានមានប្រសាសន៍ថា ការប្រគេនអំណោយដល់ពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជបាត់ដំបង ដើម្បីបង្ហាញក្តីស្រលាញ់ លើកទឹកចិត្ត និងចូលរួមចំណែកជួយដល់ប្រជាជនកម្ពុជាដែលកំពុងជួបនូវបញ្ហាគ្រោះធម្មជាតិ និងកូវីដ១៩ នាពេលបច្ចុប្បន្ន។

លោកបានបន្តទៀតថា៖ ស្របតាមលិខិតរបស់សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ "យើងទាំងអស់គ្នាជាបងប្អូន" សូមអោយយើងសហការគ្នា លើកទឹកចិត្តគ្នា យើងត្រូវចេញទៅរកបងប្អូនដែលមានឧបសគ្គ បញ្ហា ឬបងប្អូនដែលមានមធ្យោបាយ ដើម្បីរួមគ្នាដោះស្រាយឧបសគ្គដែលយើងមាន" ។

នាឱកាសនោះដែរ ព្រះតេជគុណ វី សុវិជ្ជា ប្រធានសាខា ពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជបាត់ដំបង បានមានសង្ឃដីកាថា៖ «ការផ្តល់អំណោយរបស់លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ជូនដល់សាខាពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជបាត់ដំបងនេះ ដើម្បឱ្យចាត់ចែកមនុស្សធម៌បន្ត គឺជាផ្នែកមួយនៃទំនាក់ទំនងអន្តរសាសនាផង ហើយក៏ជាផ្នែកមួយនៃមិត្តភាពរវាងសាខាពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជបាត់ដំបង និងព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង»។

លោកមានដីកាបន្ថែមថា ក្នុងនាមជាអ្នកប្រតិបត្តិសាសនានៅក្នុងប្រទេសកម្ពុជា យើងធ្វើកិច្ចការងាររួមគ្នាដើម្បីមនុស្សធម៌ ឆ្លើយតបទៅនឹងអ្វីដែលកំពុងកើតឡើងក្នុងប្រទេសកម្ពុជា ក៏ដូចជាក្នុងពិភពលោក។



ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ក្នុងអំឡុងពេលនៃការឆ្លងរីករាលដាលនៃមេរោគឆ្លង កូវីដ១៩ បានយកចិត្តទុកដាក់យ៉ាងខ្លាំងដើម្បីប្រយុទ្ធប្រឆាំងនឹងមេរោគឆ្លងនេះ ដោយបានចូលរួមផ្សព្វផ្សាយ ក៏ដូចជាឆ្លើយតបបន្ទាន់ ក្នុងកិច្ចការមនុស្សធម៌ ជួយដល់បងប្អូនក្រីក្រក្នុងសហគមន៍ដែលរងផលប៉ះពាល់ពីឥទ្ធិពលនៃមេរោគឆ្លងនេះ។ ក្រៅពីនេះក៏បានឆ្លើយតបបន្ទាន់ផងដែរ នូវការឧបត្ថម្ភដល់គ្រួសារប្រជាពលរដ្ឋ ដែលរងគ្រោះដោយជំនន់ទឹកភ្លៀង៕







## សូមអបអរសាទរ

លោកបូជាចារ្យ ផាន បូរី ទទួលខុសត្រូវលើព្រះសហគមន៍កាតូលិក ដាក់ដាំ កែវសីមា និងក្រុងសែនមនោរម្យ និងលោកបូជាចារ្យ ហ្វ្រង់ស័រ អេមេល្យដាល ជាសមាជិកនៃក្រុមសាសនាទូតក្រៅប្រទេសនៃទីក្រុងប៉ារីស (Mep) ទទួលខុសត្រូវលើព្រះសហគមន៍កាតូលិក ប៊ូស្រា កោះញែក និងមេម៉ង ដែលការទទួលខុសត្រូវនេះ មានរយៈពេល៦ឆ្នាំចាត់តាំង ដោយលោក ប្រ៊ុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។

## សូមអបអរសាទរ

លោកបូជាចារ្យ
លីឆាងវ៉ុន ដានីញ៉ែល
ជាសមាជិកនៃក្រុមសាសនទូតកូរ៉េ ទទួលខុសត្រូវព្រះសហគមន៍ចំនួន៤រួមមាន៖ ក្តុលលើ ក្រចេះ ឆ្លូង និង ឱ្យរឹម ចាត់តាំង ដោយលោកប្រ៊ុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។




អបអរសាទរលោកបូជាចារ្យប៉ូល
រឿង ឆ័ត្រសិរី
ត្រូវបានសម្តេចប៉ាបជ្រើសតាំងជា
នាយកសមាគមនៃបេសកកម្ម
របស់សន្តអាសនៈ ឡាវ-កម្ពុជា
កាលពីខែតុលា
ឆ្នាំ២០២០
Congratulations


អបអរសាទរលោកបូជាចារ្យ
កាង អ៊ីនហ្គីន យ៉ូសែប
ត្រូវបានសម្តេចប៉ាបជ្រើសតាំងជា
ទីប្រឹក្សានៃក្រសួងដើម្បីកិច្ចការ
ទំនាក់ទំនងអន្តរសាសនា
កាលពីខែតុលា
ឆ្នាំ២០២០
Congratulations